**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ**
**និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**


## របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា

# ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

កម្មសិក្សាពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧

ឈ្មោះស្ថាប័ន៖ **ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក**


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **លឹម ម៉ាន់សូដានី**

**ទ្រី ច័ន្ទសី**

សាស្ត្រាចារ្យណែនាំ

លោក **ឈាង ហ៊ុយ**


ថ្នាក់បរិញ្ញាបត្រ ធនាគារ និងហិរញ្ញវត្ថុ

ជំនាន់ទី ១០

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេររបាយការណ៍ ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំឈ្មោះ លឹម វ៉ាន់សូដានី និងទ្រីច័ន្ទសី ជានិស្សិតថ្នាក់បរិញ្ញាបត្រជំនាញធនាគារ និងហិរញ្ញវត្ថុជំនាន់ទី ១០ ក្រុមB4B1 នៃសាកលវិទ្យាល័យនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះ៖

- មាតាបិតា ដែលជាអ្នកមានគុណដ៏លើសលុប ដែលលោកទាំងពីរបានផ្តល់កំណើត ព្រមទាំងបានចិញ្ចឹមបីបាច់ថែរក្សា ដាស់តឿន ប្រៀនប្រដៅ ផ្តល់កម្លាំងកាយចិត្ត និងជម្រុញកូនឱ្យខំសិក្សារៀនសូត្រ ដើម្បីទទួលបានចំណេះវិជ្ជា សម្រាប់ជាស្ពានចម្លងទៅកាន់ភាពជោគជ័យនាពេលអនាគត។
- ឯកឧត្តមសាកលវិទ្យាធិការ លោកសាកលវិទ្យាធិការរង លោក-លោកស្រីព្រឹទ្ធបុរស ព្រឹទ្ធបុរសរង លោក-លោកស្រីប្រធាន និងអនុប្រធានការិយាល័យ ដេប៉ាតឺម៉ង់ និងលោក-លោកស្រីសាស្រ្តាចារ្យទាំងអស់ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច ដែលបានយកចិត្តទុកដាក់ និងចំណាយពេលវេលាដ៏មានតម្លៃ ដោយព្យាយាមអស់កម្លាំងកាយចិត្ត ក្នុងការបង្រៀន និងជួយតម្រង់ទិសដល់សិស្សនិស្សិតទាំងអស់រួមទាំងយើងខ្ញុំទាំងពីរនាក់ផងដែរ។
- លោកសាស្រ្តាចារ្យ ឃាង ហ៊ុយ ដែលជាសាស្រ្តាចារ្យណែនាំក្នុងគម្រោងការសរសេររបាយការណ៍កម្មសិក្សានេះ ដោយលោកបានចំណាយពេលវេលាដ៏មានតម្លៃក្នុងការបង្ហាត់បង្ហាញ ណែនាំ និងផ្តល់ជាមតិយោបល់ល្អៗ ព្រមទាំងជួយកែសម្រួលនូវរាល់កំហុសឆ្គង ដែលបានកើតមានក្នុងកំឡុងពេលនៃរៀបរៀងរបាយការណ៍កម្មសិក្សាមួយនេះ។
- លោក កាន ស៊ីវ ដែលជានាយកប្រតិបត្តិ និងលោក កូវ ធីរ៉ា ដែលជាប្រធានផ្នែកឥណទាន ព្រមទាំងបុគ្គលិកទាំងអស់នៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ដែលបានរួមចំណែកជាជំនួយដល់របាយការណ៍កម្មសិក្សា ដោយការស្វាគមន៍យ៉ាងកក់ក្តៅ ការជួយក្នុងការស្វែងរកឯកសារ សៀវភៅផ្សេងៗ និងការពន្យល់ណែនាំយ៉ាងក្បោះក្បាយ។

ជាចុងក្រោយ យើងខ្ញុំសូមប្រសិទ្ធិពរជ័យសិរីវិបុលសុខ សុភមង្គល មហាប្រសើរ រួមទាំងពុទ្ធពរទាំងបួនប្រការ សូមអោយកើតមានឡើងចំពោះ លោកអ្នកមានគុណទាំងអស់កុំបីឃ្លាងឃ្លៀតឡើយ។

# អារម្ភកថា

ការសរសេររបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា គឺជាការផ្តល់ឱកាសដ៏ប្រពៃមួយដល់និស្សិតដើម្បីស្វែងរកបទពិសោធន៍ជាក់ស្តែងនៅក្នុងការងារ ព្រមទាំងអាចអោយនិស្សិតមានលទ្ធភាពក្នុងការស្វែងយល់ និងប្រៀបធៀបពីលក្ខណៈដូច និងខុសគ្នារវាងទ្រឹស្តី និងការអនុវត្តជាក់ស្តែងផងដែរ។

ដើម្បីឱ្យស្របទៅតាមជំនាញដែលបានសិក្សានាពេលកន្លងមក យើងខ្ញុំសម្រេចជ្រើសយក "ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក" ធ្វើជាប្រធានបទក្នុងការតាក់តែងរបាយការណ៍កម្មសិក្សា ក្នុងគោលបំណងស្វែងយល់ឱ្យបានច្បាស់ពីចរិតលក្ខណៈឥណទានខ្នាតមធ្យម ការគ្រប់គ្រងឥណទាននេះ រួមទាំងលក្ខខណ្ឌមួយចំនួនដែលពាក់ព័ន្ធទៅនឹងឥណទានខ្នាតមធ្យមនេះ។ ក្រៅពីនេះ យើងនឹងធ្វើការវិភាគវាយតម្លៃតាមព័ត៌មាន និងស្ថានភាពជាក់ស្តែងដែលយើងទទួលបាន។

ជាការពិត របាយការណ៍កម្មសិក្សាមួយនេះ ប្រាកដជាមាននូវកំហុសឆ្គងមួយចំនួន ដែលកើតឡើងដោយអចេតនា ដូចជាកំហុសអក្ខរាវិរុទ្ធ និងការខ្វះចន្លោះនៅក្នុងផ្នែកអត្ថន័យ ជាអាទ៍។ ហេតុនេះ យើងខ្ញុំលំឱនទាំងចិត្តកាយសូមអភ័យទោសទុកជាមុនចំពោះរាល់កំហុសឆ្គងដែលកើតមាននេះ យើងខ្ញុំនឹងស្វាគមន៍ដោយក្តីរីករាយនូវរាល់មតិរិះគន់ និងការកែលម្អ ពីសំណាក់ លោក-លោកស្រីសាស្ត្រាចារ្យ និងមិត្តនិស្សិតទាំងអស់ដែលមានចំនេះដឹងដ៏ខ្ពង់ខ្ពស់ ក្នុងវិស័យនេះ។

ជាចុងក្រោយ យើងខ្ញុំសង្ឃឹមថា របាយការណ៍កម្មសិក្សាមួយនេះ នឹងអាចជាជំនួយ និងរួមចំនែកក្នុងការចែករំលែកនូវចំនេះដឹង និងបទពិសោធន៍ខ្លះៗទាក់ទងនឹងផ្នែកហិរញ្ញវត្ថុ និងធនាគារ ជាពិសេសគឺផ្នែកឥណទាននៅតាមបណ្តាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ឬធនាគារណាមួយដែលមាននៅក្នុងប្រទេសកម្ពុជា។

# មាតិកា


បញ្ជីអក្សរកាត់ ........ vii
បញ្ជីតារាង ........ viii
បញ្ជីក្រាប ........ ix
បញ្ជីរូបភាព ........ x
បញ្ជីរូបមន្ត ........ xi
បញ្ជីឧបសម្ព័ន្ធ ........ xii


## សេចក្ដីផ្ដើម


១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១
២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ២
៣.គោលបំណងនៃការស្រាវជ្រាវ ........ ២
៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ ........ ៣
៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣
៦.វិធីសាស្ត្រក្នុងការស្រាវជ្រាវ ........ ៣
៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៤


## ជំពូកទី១
## រំលឹកទ្រឹស្ដី


១.១.លក្ខណៈទូទៅរបស់ធនាគារ ........ ៦
១.១.១.ប្រវត្តិនៃការកកើតធនាគារ ........ ៦
១.១.២.និយមន័យនៃធនាគារពាណិជ្ជ ........ ៦
១.១.៣.តួនាទីរបស់ធនាគារពាណិជ្ជ ........ ៧
១.១.៤.សារៈសំខាន់របស់ធនាគារពាណិជ្ជ ........ ៧
១.២.លក្ខណៈទូទៅរបស់ឥណទាន ........ ៨
១.២.១.និយមន័យ ........ ៨
១.២.២.ប្រភេទនៃឥណទាន ........ ៨
១.២.២.១.ឥណទានឯកជន ........ ៨
១.២.២.២.ឥណទានសាធារណៈ ........ ៩

១.២.៣.រយៈពេលឥណទាន ........ ៩
១.៣.គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ឥណទាន ........ ៩
១.៣.១.គុណសម្បត្តិ ........ ៩
១.៣.២.គុណវិបត្តិ ........ ១១
១.៤.ដំណើរការនៃការគ្រប់គ្រងឥណទាន ........ ១១
១.៤.១.ការជ្រើសរើសសំណើរសុំឥណទាន ........ ១១
១.៤.២.ការស៊ើបអង្កេតឥណទាន ........ ១២
១.៤.៣.ការម្រេចចិត្តផ្តល់ឥណទាន ........ ១២
១.៤.៤.ការត្រួតពិនិត្យលើគណនី ........ ១៣
១.៤.៥.ការទារប្រមូលឥណទាន ........ ១៣
១.៥.ការវាយតម្លៃឥណទាន ........ ១៣
១.៥.១.ការវាយតម្លៃតាម ៦ C’s ........ ១៣
១.៥.២.ការវាយតម្លៃតាម ៤ R’s ........ ១៤
១.៦.វិធីសាស្ត្រក្នុងការសងបំណុល ........ ១៥
១.៦.១.កម្ចីអប្បហាពិត ........ ១៥
១.៦.២.កម្ចីសងតែការប្រាក់ ........ ១៥
១.៦.៣.កម្ចីសងរំលស់ ........ ១៥
១.៧.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ........ ១៧
១.៧.១.ចំណាត់ថ្នាក់ឥណទាន ........ ១៧
១.៧.២.សំវិធានធន ........ ១៨
១.៨.ហានិភ័យឥណទាន ........ ១៩
១.៨.១.និយមន័យ ........ ១៩
១.៨.២.ហានិភ័យរបស់គ្រឹះស្ថានហិរញ្ញវត្ថុ ........ ១៩
១.៨.៣.មូលហេតុដែលបណ្តាលឱ្យមានហានិភ័យឥណទាន ........ ២០
១.៨.៤.វិធីសាស្ត្រទប់ស្កាត់ហានិភ័យឥណទាន ........ ២១
១.៨.៥.ដំណោះស្រាយឥណទានមានបញ្ហា ........ ២១
១.៩.តួនាទីឥណទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ........ ២២
១.៩.១.ការគ្រប់គ្រងហានិភ័យ ........ ២២

១.៩.២.បុគ្គល ........ ២២
១.៩.៣.ជំនួញ ........ ២៣
១.៩.៤.ការចំណាយរបស់រដ្ឋាភិបាល ........ ២៣

# ជំពូកទី២
# ស្ថានភាពទូទៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

២.១.លក្ខណៈទូទៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ........ ២៤
២.១.១.ប្រវត្តិរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ........ ២៤
២.១.២.ទស្សនៈវិស័យ ........ ២៤
២.១.៣.បេសកកម្ម ........ ២៥
២.១.៤.គោលដៅ ........ ២៥
២.១.៥.វប្បធម៌ការងារ ........ ២៥
២.១.៦.អភិបាលកិច្ចសាជីវកម្ម ........ ២៥
២.២.អត្តសញ្ញាណរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ........ ២៦
២.៣.ទីតាំងភូមិសាស្ត្រការិយាល័យកណ្ដាលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ........ ២៦
២.៤.បណ្ដាញប្រតិបត្តិការរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ........ ២៧
២.៤.១.ទីតាំងភូមិសាស្ត្ររបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ........ ២៧
២.៤.២.ប្រវត្តិរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ........ ២៨
២.៤.៣.ភាគទុនិក ........ ២៨
២.៤.៤.អង្គការលេខរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ........ ២៩
២.៥.ផលិតផល និងសេវាកម្មរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ........ ២៩
២.៥.១.ផលិតផលឥណទាន ........ ២៩
២.៥.១.១.ឥណទានខ្នាតតូចបំផុត ........ ២៩
២.៥.១.២.ឥណទានខ្នាតតូច ........ ៣០
២.៥.១.៣. ឥណទានខ្នាតមធ្យម ........ ៣០
២.៥.១.៤.ឥណទានកសិកម្ម ........ ៣០
២.៥.១.៥.ឥណទានមិនមែនកសិកម្ម ........ ៣០
២.៥.១.៦.ឥណទានវិបារូបរ៍ ........ ៣១
២.៥.១.៧.ឥណទានគេហដ្ឋាន ........ ៣២

២.៥.១.៨.ឥណទានគ្មានទ្រព្យធានា .......... ៣២
២.៥.១.៩.ឥណទានយានយន្ត .......... ៣២
២.៥.២.ផលិតផលបញ្ញើសន្សំ .......... ៣៣
២.៥.២.១.គណនីបញ្ញើសំចៃ .......... ៣៣
២.៥.២.២.គណនីសន្សំ វីអាយភី .......... ៣៣
២.៥.២.៣.គណនីចរន្ត .......... ៣៤
២.៥.២.៤.គណនីចរន្ត វីអាយភី .......... ៣៤
២.៥.២.៥.គណនីរីករាយ .......... ៣៤
២.៥.២.៦.គណនីបញ្ញើមានកាលកំណត់ .......... ៣៤
២.៥.២.៧.គណនីសន្សំ/ចរន្តបានការប្រាក់ខ្ពស់ .......... ៣៥
២.៥.២.៨.គណនី Trust សម្រាប់អចលនទ្រព្យ .......... ៣៥
២.៥.៣.សេវាផ្សេងៗ .......... ៣៥
២.៥.៣.១.សេវាផ្ទេរប្រាក់ .......... ៣៦
២.៥.៣.២.សេវាទូទាត់រហ័ស .......... ៣៦
២.៥.៣.៣.សេវាផ្ទេរប្រាក់ក្នុងប្រទេស .......... ៣៦
២.៥.៣.៤.សេវាផ្ទេរប្រាក់ក្រៅប្រទេស .......... ៣៧
២.៥.៣.៥. សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក .......... ៣៧

## ជំពូកទី៣

## ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

៣.១.គោលបំណងនៃផលិតផលឥណទានខ្នាតមធ្យម .......... ៣៩
៣.២.លក្ខណៈទូទៅរបស់ឥណទានខ្នាតមធ្យម .......... ៣៩
៣.២.១.និយមន័យ .......... ៣៩
៣.២.២.អតិថិជនគោលដៅ .......... ៣៩
៣.៣.គោលការណ៍នៃការផ្តល់ឥណទានខ្នាតមធ្យម .......... ៤០
៣.៣.១.លក្ខណៈសម្បត្តិដែលអាចទទួលឥណទាន .......... ៤០
៣.៣.២.លក្ខណៈសម្បត្តិដែលមិនអាចទទួលបានឥណទាន .......... ៤១
៣.៣.៣.លក្ខណៈសម្បត្តិរបស់អ្នកធានា .......... ៤២

៣.៣.៤.ប្រភេទរូបិយប័ណ្ណ ទំហំឥណទាន រយៈពេលខ្ចី អត្រាការប្រាក់
និងសោហ៊ុយឥណទាន......................................................................................៤២
៣.៣.៥.ការកំណត់ទំហំឥណទាន ......................................................................................៤៤
៣.៣.៦.ឯកសារឥណទាន ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន..........................៤៤
៣.៣.៦.១.ឯកសារឥណទាន..............................................................................................៤៤
៣.៣.៦.២.ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន .................................................៤៥
៣.៤.នីតិវិធីក្នុងការផ្តល់ឥណទានខ្នាតមធ្យម.....................................................................៤៥
៣.៥.ការវាយតម្លៃប្រាក់កម្ចី ..................................................................................................៥២
៣.៦.ទ្រព្យធានា ...................................................................................................................៥៣
៣.៦.១.កម្រិតសុវត្ថិភាព.......................................................................................................៥៤
៣.៦.២.ការវាយតម្លៃទ្រព្យធានា ...........................................................................................៥៤
៣.៧.ការតាមដានត្រួតពិនត្យឥណទាន ...............................................................................៥៤
៣.៧.១.ដំណើរការត្រួតពិនិត្យ ................................................................................................៥៤
៣.៧.២.ប្រព័ន្ធត្រួតពិនិត្យឥណទាន .........................................................................................៥៥
៣.៧.៣.ត្រួតពិនិត្យឥណទាន ..................................................................................................៥៥
៣.៨.គោលការណ៍នៃការសងត្រលប់....................................................................................៥៦
៣.៨.១.របៀបសងប្រាក់..........................................................................................................៥៦
៣.៨.២.ឥណទានបង់ផ្តាច់ ......................................................................................................៥៧
៣.៨.៣.ការផ្តល់ឥណទានបន្ថែម ............................................................................................៥៧
៣.៩.ការខកខាន និងការពិន័យ............................................................................................៥៧
៣.៩.១.ការខកខាន..................................................................................................................៥៧
៣.៩.២.ការពិន័យ ....................................................................................................................៥៨
៣.៩.២.១.ការគណនាប្រាក់ពិន័យ.............................................................................................៥៨
៣.៩.២.២.ការលើកលែងប្រាក់ពិន័យ.......................................................................................៥៨
៣.១០.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន ...........................................................៥៩
៣.១០.១.ការធ្វើចំណាត់ថ្នាក់ឥណទាន...................................................................................៥៩
៣.១០.២.ការធ្វើសំវិធានធន....................................................................................................៦៣
៣.១១.វិធីសាស្ត្រដោះស្រាយឥណទានមានបញ្ហា....................................................................៦៤

៣.១១.១.ផែនការសកម្មភាពដោះស្រាយបំណុល............................................................................៦៥
៣.១១.២.ដោះស្រាយតាមប្រព័ន្ធតុលាការ ..................................................................................៦៨
៣.១១.២.១.ដំណាក់កាលដោះស្រាយនៅសាលាដំបូង ឬតុលាការខេត្ត/រាជធានី.............៦៩
៣.១១.២.២.ដំណាក់កាលដោះស្រាយនៅសាលាឧទ្ធរណ៍ ........................................... ៧០
៣.១១.២.៣.ដំណាក់កាលដោះស្រាយនៅតុលាការកំពូល........................................... ៧១
៣.១២.ការវាស់វែងគុណភាពឥណទាន.................................................................................... ៧១
៣.១២.១.អត្រាហានិភ័យឥណទាន.......................................................................................... ៧១
៣.១២.២.អត្រានៃការសងត្រឡប់មកវិញនៃឥណទាន ....................................................... ៧២
៣.១២.៣.បំណុលលុបចេញពីបញ្ជី (Write-off) ................................................................ ៧២
៣.១៣.លទ្ធផលនៃការស្រាវជ្រាវ...........................................................................................៧៣
៣.១៣.១.សមតុល្យសរុបរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ចាប់ពីឆ្នាំ២០១៥ ដល់ ២០១៦...........................................................................................៧៣
៣.១៣.២.ឥណទានដែលបានលុបចេញពីបញ្ជីរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ចាប់ពីឆ្នាំ២០១៥ ដល់ ២០១៧ ................................................... ៧៦
៣.១៣.៣.ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ..........................................................៧៧
៣.១៣.៣.១.ចំណុចខ្លាំង...............................................................................................៧៧
៣.១៣.៣.២.ចំណុចខ្សោយ ..........................................................................................៧៧

## សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

១.សេចក្តីសន្និដ្ឋាន................................................................................................................ ៧៨
២.ការផ្តល់អនុសាសន៍ ............................................................................................................ ៧៩

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

- CIHP : Canadia Investmnt Holding PLC
- FFH : Fullerton Financial Holding
- MPT : Ministry of Post and Telecomunications
- PLC : Public Limited Company
- SWIFT : Society for Worldwide Interbank Financial Telecommunication
- VIP : Very Important Person
- ATM : Automated Teller Machine
- USD : United State Dollars
- THB : Thai Baht
- KHR : Khmer Riel
- MIS : Management Information System
- PAR : Portfolio at Risk
- WOR : Write-Off Rate

# បញ្ជីតារាង

តារាងទី ១.១ ៖ វិលស់ប្រាក់ដើម........................................................................................................១៦
តារាងទី ១.២ ៖ វិលស់សំណងថេរ ...................................................................................................... ១៧
តារាងទី ២.១ ៖ ភាគទុនិករបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ..............................................................២៨
តារាងទី ៣.១៖ តារាងរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការដែលបានអនុញ្ញាតបញ្ចេញឥណទាន
តាមសាខា........................................................................................................................ ៤៣
តារាងទី ៣.២ ៖ តារាងទំហំឥណទានសម្រាប់ប្រភេទរូបិយប័ណ្ណនីមួយៗ................................................ ៤៣
តារាងទី ៣.៣ ៖ តារាងអត្រាការប្រាក់................................................................................................. ៤៣
តារាងទី ៣.៤៖ ចំណាត់ថ្នាក់ឥណទាន ................................................................................................៦០
តារាងទី ៣.៥ ៖ ផែនការសកម្មភាពដោះស្រាយបំណុល ..........................................................................៦៥
តារាងទី ៣.៦៖ ការបញ្ចេញឥណទានខ្នាតមធ្យមក្នុងឆ្នាំ ២០១៥-២០១៦ ..................................................៧៣
តារាងទី ៣.៧៖ ចំនួនអតិថិជននៃឥណទានខ្នាតមធ្យមក្នុងឆ្នាំ ២០១៥-២០១៦......................... ៧៥

# បញ្ជីក្រាប

ក្រាបទី ៣.១ ៖ ការបញ្ចេញឥណទានខ្នាតមធ្យមក្នុងឆ្នាំ ២០១៥-២០១៦ ................................. ៧៤
ក្រាបទី ៣.២ ៖ ចំនួនអតិថិជននៃឥណទានខ្នាតមធ្យមក្នុងឆ្នាំ ២០១៥-២០១៦ .......................... ៧៥

# បញ្ជីរូបភាព


រូបភាពទី ២.១ ៖ និមិត្តសញ្ញារបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ........................................២៦

រូបភាពទី ២.២ ៖ រូបភាពរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក........................២៨

រូបភាពទី ២.៣ ៖ រូបភាពអង្គការលេខរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ............................២៩

# បញ្ជីរូបមន្ត


រូបមន្តទី ១.១ ៖ រំលស់សំណាងថេរ ........................................................................ ១៦

រូបមន្តទី ៣.១ ៖ ការគណនាប្រាក់ពិន័យ........................................................................ ៥៨

រូបមន្តទី ៣.២ ៖ ការគណនាអត្រាហានិភ័យ ................................................................ ៧១

រូបមន្តទី ៣.៣ ៖ ការគណនាអត្រានៃការសងត្រលប់មកវិញ .............................................. ៧២

រូបមន្តទី ៣.៤ ៖ ការគណនាអត្រាបំណុលលុបចេញពីបញ្ជី ................................................៧៣

# បញ្ជីឧបសម្ព័ន្ធ


## ឧបសម្ព័ន្ធ ១ ៖ ទម្រង់ប្រើប្រាស់របស់សេវាឥណទាន

ឧបសម្ព័ន្ធ ១.១ ៖ ពាក្យស្នើសុំឥណទាន

ឧបសម្ព័ន្ធ ១.២៖ សម្រង់ព័ត៌មាន និងគម្រោងជំនួញ

ឧបសម្ព័ន្ធ ១.៣ ៖ កំណត់ហេតុស្ដីពីការចុះត្រួតពិនិត្យ និងវាយតម្លៃទ្រព្យ

ឧបសម្ព័ន្ធ ១.៤ ៖ កិច្ចសន្យាដាក់បញ្ចាំ

ឧបសម្ព័ន្ធ ១.៥ ៖ កិច្ចសន្យាបង្កើតហ៊ីប៉ូតែក

ឧបសម្ព័ន្ធ ១.៦ ៖ កិច្ចសន្យាខ្ចីប្រាក់

ឧបសម្ព័ន្ធ ១.៧ ៖ កិច្ចសន្យាធានា

ឧបសម្ព័ន្ធ ១.៨ ៖ Risk Acceptance Criteria Checklist

ឧបសម្ព័ន្ធ ១.៩ ៖ របាយការណ៍ត្រួតពិនិត្យឥណទាន

ឧបសម្ព័ន្ធ ១.១០ ៖ លិខិតបញ្ជាក់ទីលំនៅ

ឧបសម្ព័ន្ធ ១.១១ ៖ លិខិតបញ្ជាក់ទទួលស្គាល់ឈ្មោះ

ឧបសម្ព័ន្ធ ១.១២ ៖ លិខិតបញ្ជាក់លើការកោសលុបលើឯកសារកម្មសិទ្ធ

ឧបសម្ព័ន្ធ ១.១៣ ៖ លិខិតបញ្ជាក់មរណភាព

ឧបសម្ព័ន្ធ ១.១៤ ៖ លិខិតបញ្ជាក់ភាពមេម៉ាយ/ពោះម៉ាយ

ឧបសម្ព័ន្ធ ១.១៥ ៖ លិខិតបញ្ជាក់ស្នាមមេដៃ

ឧបសម្ព័ន្ធ ១.១៦ ៖ លិខិតសុំជួយទប់ស្កាត់ការផ្ទេរកម្មសិទ្ធ ដាក់បញ្ចាំ និងបញ្ជាក់កម្មសិទ្ធ

ឧបសម្ព័ន្ធ ១.១៧ ៖ បញ្ជីត្រួតពិនិត្យឯកសារឥណទានអតិថិជន

ឧបសម្ព័ន្ធ ១.១៨ ៖ ការត្រួតពិនិត្យចំណុចសំខាន់នៅក្នុងទម្រង់គំរូឥណទាន

ឧបសម្ព័ន្ធ ១.១៩ ៖ បញ្ជីព័ត៌មានឥណទានសម្រាប់បញ្ចូលក្នុងប្រព័ន្ធ T24

ឧបសម្ព័ន្ធ ១.២០ ៖ ការកំណត់ប្រភេទជំនួញ និងម្ចាស់កម្មសិទ្ធក្នុងវិស័យសេដ្ឋកិច្ច

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ជាប្រទេសមួយក្នុងចំណោមប្រទេសទាំង១០ ដែលមានកំណើនសេដ្ឋកិច្ចលឿនជាងគេគួរឱ្យកត់សម្គាល់[1]។ នាកំឡុងពេល២០ឆ្នាំនេះ សេដ្ឋកិច្ចប្រទេសកម្ពុជាបានបន្តការរីកចម្រើនយ៉ាងរឹងមាំ ដោយស្របទៅតាមគោលដៅយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨។ ទន្ទឹមនឹងការរីកចម្រើននៃសេដ្ឋកិច្ច និងស្ថេរភាពហិរញ្ញវត្ថុ វិនិយោគិនក្នុងស្រុក និងក្រៅស្រុក បានពង្រីកការវិនិយោគរបស់ខ្លួនមកលើវិស័យធនាគារដែលមានភាពរឹងមាំ និងភាពធន។ កត្តានេះ ជម្រុញអោយវិស័យធនាគារដើរតួនាទីសំខាន់នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ តាមរយៈការផ្តល់សេវាហិរញ្ញវត្ថុឱ្យកាន់តែទូលំទូលាយទូទាំងប្រទេស។

គិតត្រឹមដំណាច់ឆ្នាំ២០១៦ ប្រតិបត្តិការរបស់គ្រឹះស្ថានធនាគារមានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដែលឆ្លុះបញ្ចាំងតាមរយៈ កំណើនទ្រព្យសកម្មដល់ ៩៦ ទ្រីលានរៀល (ប្រមាណ ២៣,៧ ប៊ីលានដុល្លារអាមេរិក កើន១៩%) កំណើនមូលនិធិភាគទុនិក ដល់ ១៧,២ ទ្រីលានរៀល (ប្រមាណ ៤,២ ប៊ីលានដុល្លារអាមេរិក កើន ១៨%) កំណើនប្រាក់កម្ចីពីប្រភពផ្សេងៗ ដល់ ៤ ទ្រីលានរៀល (ប្រមាណ ១ ប៊ីលានដុល្លារអាមេរិក កើន ៦៥%) កំណើនប្រាក់បញ្ញើដល់ ៥៥,១ ទ្រីលានរៀល (ប្រមាណ ១៣,៦ ប៊ីលានដុល្លារអាមេរិក កើន ១៩%) និងកំណើនឥណទានដល់ ៥៦,៣ ទ្រីលានរៀល (ប្រមាណ ១៣,៩ ប៊ីលានដុល្លារអាមេរិក កើន ១៨%)។ ទន្ទឹមនឹងនេះ ចំនួនអិថិជនដាក់ប្រាក់បញ្ញើបានកើនឡើង ១៤% ដល់ ៣ លានអតិថិជន និងអតិថិជនដែលទទួលបានឥណទានបានកើនឡើង ៤៩% ដល់ ០,៨ លានអតិថិជន។ រីឯចំនួនសាខារបស់គ្រឹះស្ថានធនាគារបានកើនឡើងដល់ ៨១០ សាខា និងម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិបានកើនឡើង ដល់ ១,២៥៥ ម៉ាស៊ីន។ ឥណទានរបស់គ្រឹះស្ថានធនាគារដើរតួនាទីយ៉ាងសកម្មក្នុងការជម្រុញការពង្រីកអាជីវកម្ម និងការប្រើប្រាស់ក្នុងស្រុក។ កំណើនឥណទានត្រូវបានបែងចែកទៅតាមវិស័យផ្សេងៗនៃសេដ្ឋកិច្ច រួមមាន ការជួញដូររាយ ១៧% ការជួញដូរដុំ ១៥% កសិកម្មរុក្ខាប្រមាញ់និងនេសាទ ១១% សេវាផ្សេងៗដែលមិនមែនហិរញ្ញវត្ថុ ៨% និងឥណទានផ្ទែកសំណង់ ៨% នៃសំពៀតឥណទានសរុប[2]។

[1] http://www.imf.org/en/News/Articles/2017/06/06/sp060717-the-cambodian-economy-outlook-risks-and-reforms, (Retrieved date: May 13, 2017)

[2] ធនាគារជាតិនៃកម្ពុជា, របាយការណ៍ប្រចាំឆ្នាំ២០១៦, ទំព័រទី៤៥

បច្ចុប្បន្ននេះ ស្ថាប័នហិរញ្ញវត្ថុទាំងនោះកំពុងតែពង្រឹង និងអភិវឌ្ឍន៍ផលិតផលឥណទានរបស់ខ្លួនទៅឱ្យអតិថិជន ក្នុងគោលបំណងជួយសម្រួលជីវភាពរបស់ពួកគាត់ ឱ្យកាន់តែប្រសើរឡើង។ ទន្ទឹមនឹងនេះ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ជាស្ថាប័នហិរញ្ញវត្ថុមួយដែលកំពុងតែទទួលបានការគាំទ្រខ្លាំងលើផលិតផល និងសេវាកម្ម ពីសំណាក់ប្រជាជនទូទាំងខេត្តក្រុង ក្នុងប្រទេសកម្ពុជា ក្នុងនោះដែរមាន សេវាបញ្ញើសន្សំ ផលិតផលឥណទាន និងផលិតផលផ្សេងៗ។ ដើម្បីស្វែងយល់ឱ្យកាន់តែច្បាស់ ពីផលិតផលឥណទានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក្រុមយើងខ្ញុំបានលើកយក "ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក" មកធ្វើជាប្រធានបទរបាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយសារតែឥណទានបានចូលរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ វាទាមទារឱ្យមានការយកចិត្តទុកដាក់ខ្លាំងក្នុងការគ្រប់គ្រង និងប្រើប្រាស់វាឱ្យមានប្រសិទ្ធិភាព។ ហេតុនេះហើយទើបការស្រាវជ្រាវមួយនេះសង្កត់ធ្ងន់លើចំណុចមួយចំនួនដូចខាងក្រោម ៖

- តើធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានគោលការណ៍ក្នុងការគ្រប់គ្រងឥណទាន យ៉ាងដូចម្ដេច?
- តើធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានវិធីសាស្ត្រដូចម្ដេចក្នុងការដោះស្រាយឥណទានមានបញ្ហា ?
- តើការផ្តល់ឥណទានខ្នាតមធ្យមរបស់ធនាគារមានប្រសិទ្ធិភាពកម្រិតណា ?

## ៣.គោលបំណងនៃការស្រាវជ្រាវ

ការស្រាវជ្រាវនេះត្រូវបានធ្វើឡើងដោយមានកម្មវត្ថុមួយចំនួន ដូចខាងក្រោម៖

- ស្វែងយល់ពីស្ថានភាពទូទៅរបស់ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក
- ស្វែងយល់ពីគោលបំណងនៃឥណទានខ្នាតមធ្យម
- ស្វែងយល់ពីគោលការណ៍ និងនីតិវិធីនៃការផ្តល់ឥណទានខ្នាតមធ្យម
- ស្វែងយល់ពីការត្រួតពិនិត្យឥណទានខ្នាតមធ្យម
- ស្វែងយល់ពីការសងត្រលប់នៃឥណទានខ្នាតមធ្យម
- ស្វែងយល់ពីការខកខាន និងការពិន័យរបស់ឥណទានខ្នាតមធ្យម
- ស្វែងយល់ពីវិធីសាស្ត្រដោះស្រាយឥណទានខ្នាតមធ្យម។

## ៤.ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានការិយាល័យប្រតិបត្តិនៅតាមបណ្តារាជធានី ខេត្ត ផ្សេងៗជាច្រើននៅទូទាំង ២៥ខេត្ត ក្រុង ដែលកំពុងធ្វើប្រតិបត្តិការផ្តល់សេវាកម្មហិរញ្ញវត្ថុ។

យ៉ាងណាមិញ ការស្រាវជ្រាវនេះ យើងខ្ញុំបានកំណត់ត្រឹមតែនៅក្នុងធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក និងផលិតផលឥណទានខ្នាតមធ្យមក្នុងឆ្នាំ២០១៦-២០១៧ តែប៉ុណ្ណោះ ដោយមិនលំអិតលើផ្នែកសេវាកម្មហិរញ្ញវត្ថុដទៃទៀតរបស់សាខានេះឡើយ។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាលើប្រធានបទមួយនេះ វានឹងផ្តល់នូវសារៈសំខាន់ដូចខាងក្រោម៖

- សម្រាប់សិស្ស និស្សិតជំនាន់ក្រោយ អាចទុកជាឯកសារ ដើម្បីធ្វើការស្រាវជ្រាវ និងស្វែងយល់អំពីការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក
- ជាការឆ្លុះបញ្ចាំងរវាងការសិក្សាផ្នែកទ្រឹស្តី និងការអនុវត្តជាក់ស្តែង
- តាមរយៈការស្រាវជ្រាវនេះ ធនាគារអាចផ្សព្វផ្សាយអំពីផលិតផលរបស់ខ្លួនទៅកាន់អ្នកអាន
- ធនាគារអាចស្វែងយល់ពីភាពខ្លាំង និងភាពខ្សោយរបស់ខ្លួន ដែលធ្វើឱ្យអ្នកគ្រប់គ្រងអាចរកឃើញដំណោះស្រាយ កែប្រែភាពខ្សោយរបស់ខ្លួន និងបង្កើនភាពខ្លាំងដើម្បីធ្វើឱ្យការគ្រប់គ្រងឥណទានកាន់តែមានប្រសិទ្ធិភាព។

## ៦.វិធីសាស្ត្រក្នុងការស្រាវជ្រាវ

តាមរយៈការស្រាវជ្រាវនេះ រាល់ទិន្នន័យដែលយើងខ្ញុំទទួលបានមាន២ប្រភេទ៖

- **ទិន្នន័យចំបង៖** ជាទិន្នន័យដែលទទួលបានតាមរយៈការសាកសួរផ្ទាល់មាត់ជាមួយលោកប្រធានគ្រប់គ្រងសាខា ប្រធានមន្ត្រីឥណទាន និងបុគ្គលិកទាំងឡាយដែលធ្វើការពាក់ព័ន្ធនឹងផ្នែកឥណទាន។
- **ទិន្នន័យបន្ទាប់បន្សំ៖** ជាព័ត៌មានទាំងឡាយដែលទទួលបានតាមរយៈឯកសារនានាដែលទាក់ទងជាមួយទ្រឹស្តីដើម្បីគាំទ្រ និងផ្សារភ្ជាប់ជាមួយការអនុវត្តជាក់ស្តែង។ ទិន្នន័យទាំងនោះបានមកពី៖
  - ឯកសារដែលទទួលបានពីលោកប្រធានសាខាអូឡាំពិក និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ដែលផ្តល់ដោយនាយកដ្ឋានឥណទាន។
  - ប្រភពពីគេហទំព័រផ្លូវការរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

- ជំពូកទី១៖ សេចក្តីផ្តើម

នៅក្នុងជំពូកនេះ នឹងបង្ហាញអំពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ វិធីសាស្ត្រនៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

- ជំពូកទី២៖ រំលឹកទ្រឹស្តី

នៅក្នុងជំពូកនេះ នឹងបង្ហាញអំពីទ្រឹស្តីផ្សេងៗ ដែលទាក់ទងទៅនឹងប្រធានបទ។

- ជំពូកទី៣៖ ស្ថានភាពទូទៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

នៅក្នុងជំពូកនេះ នឹងបង្ហាញអំពី លក្ខណៈទូទៅរបស់ធនាគារ អត្តសញ្ញាណ ទីតាំងភូមិសាស្ត្រ បណ្តាញប្រតិបត្តិការ ភាគទុនិក ព្រមទាំងផលិតផល និង សេវាកម្មរបស់ធនាគារនេះផងដែរ។

- ជំពូកទី៤៖ ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

នៅជំពូកនេះ នឹងបង្ហាញអំពី គោលបំណង លក្ខណៈទូទៅ គោលការណ៍នៃការផ្តល់ឥណទាន នីតិវិធីក្នុងការផ្តល់ឥណទាន ការត្រួតពិនិត្យ គោលការណ៍នៃការសងត្រលប់មកវិញ ការខកខាន និងការពិន័យ ការធ្វើចំណាត់ថ្នាក់ និងសំវិធានធន វិធីសាស្ត្រដោះស្រាយឥណទានមានបញ្ហា គុណភាពឥណទាន និងលទ្ធផលនៃការស្រាវជ្រាវ។

- ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងអនុសាសន៍

នៅក្នុងជំពូកនេះ នឹងបង្ហាញពីការធ្វើសេចក្តីសន្និដ្ឋានរួមលើរបាយការណ៍ទាំងមូល និងផ្តល់ជាអនុសាសន៍ខ្លះៗសម្រាប់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ដើម្បីអនុវត្តទិសដៅបន្ត។

# រចនាសម្ព័ន្ធនៃការស្រាវជ្រាវ



# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១.លក្ខណៈទូទៅរបស់ធនាគារ

### ១.១.១.ប្រវត្តិនៃការកកើតធនាគារ

ដំបូងធនាគារកើតឡើងពីពាណិជ្ជករនៅសម័យបុរាណ ដែលបង្កើតឱ្យមានប្រាក់កម្ចី សម្រាប់កសិករ ពាណិជ្ជករ ដែលបានដឹកជញ្ជូនទំនិញ ពីទីក្រុងមួយទៅទីក្រុងមួយ។ សកម្មភាពបែបនេះមានតាំងពី២០០០ឆ្នាំ មុនគ.ស នៅតំបន់ Assyria និង Babylonia។ បន្ទាប់មក នៅប្រទេសក្រិចសម័យបុរាណ និងសម័យរ៉ូម៉ាំង ឬចក្រភពរ៉ូម អ្នកផ្តល់កម្ចីដែលមានមូលដ្ឋាននៅព្រះវិហារ បានបង្កើតប្រាក់កម្ចី ហើយក៏បាន បន្ថែមនូវការបង្កើតថ្មីសំខាន់ៗចំនួនពីរ គឺការទទួលដាក់ប្រាក់ និងការដូររូបិយវត្ថុ។ នៅសម័យនោះ ក៏មានភស្តុតាងស្រដៀងគ្នានៃការអភិវឌ្ឍ ភាពឯករាជ្យនៃការខ្ចីប្រាក់នៅសម័យចិនបុរាណ និងសម័យឥណ្ឌាបុរាណ។

នៅក្នុងគំនិតថ្មី ធនាគារត្រូវបានរកឃើញនៅមជ្ឈឹមសម័យ និងដើមសម័យនៃការរីកចម្រើនរបស់អ៊ីតាលី នៅក្នុងទីក្រុងអ្នកមាននៅភាគខាងជើង ដូចជា Florence, Venice និង Genoa។ គ្រួសាររបស់ Bardi និង Peruzzi បានគ្រប់គ្រងធនាគារនៅក្នុងសតវត្សទី១៤ នៃតំបន់ Florence និងបង្កើតសាខា នៅក្នុងផ្នែកផ្សេងៗទៀតនៅទ្វីបអឺរ៉ុប។ ធនាគារ Bardici ជាធនាគារដែលល្បីជាងគេរបស់អ៊ីតាលី ដែលបានបង្កើតឡើងដោយ Giovanni Madici នៅឆ្នាំ ១៣៩៧។

ការរីកចម្រើនរបស់ធនាគារបានរីករាលដាលពាសពេញទ្វីបអឺរ៉ុប ហើយមានការបង្កើតឡើងនូវធនាគារថ្មីសំខាន់ៗមួយចំនួនទៀត នៅទីក្រុង Amsterdam នៅសម័យសាធារណៈរដ្ឋហូឡង់ ក្នុងសតវត្សទី១៧។ អំឡុងសតវត្សទី២០ ការអភិវឌ្ឍក្នុងផ្នែកទូរគមនាគមន៍ និងកុំព្យូទ័រ បានផ្តល់ជាលទ្ធផល យ៉ាងសំខាន់ក្នុងការផ្លាស់ប្តូរ នៃការរៀបចំធនាគារ ហើយក៏មានការធ្វើឱ្យកើនឡើង ទាំងទំហំ និងការប្រើប្រាស់តាមតំបន់នានានៅចុងឆ្នាំ២០០០ វិបត្តិហិរញ្ញវត្ថុបានធ្វើឱ្យធនាគារខ្លះបរាជ័យ ដែលរួមមានធនាគារធំៗរបស់ពិភពលោកផងដែរ[3]។

### ១.១.២.និយមន័យនៃធនាគារពាណិជ្ជ

ធនាគារពាណិជ្ជ ជានីតិបុគ្គលដែលមានសម្បទាពិសេសក្នុងការរើសយកប្រតិបត្តិការធនាគារជាមុខរបរប្រក្រតី។ ធនាគារពាណិជ្ជអនុវត្តន៍នូវសកម្មភាពរបស់វាដូចជា៖

[3] https://en.wikipedia.org/wiki/History_of_banking, (Retrieved date: June 9, 2017)

- ទទួលប្រាក់បញ្ញើពីសាធារណៈជន តាមរយៈការប្រមូលទុនដែលនៅទំនេរនៅក្នុងសេដ្ឋកិច្ច។
- ផ្តល់ឥណទានគ្រប់ប្រភេទចំពោះសាធារណៈជនដោយទទួលបានកម្រៃ ទៅតាមមុខសញ្ញាដែលបានកំណត់ដោយ នយោបាយរូបិយវត្ថុ។
- ប្រព្រឹត្តកម្ម និងការដាក់ឱ្យអតិថិជនប្រើប្រាស់នូវមធ្យោបាយទូទាត់ជារូបិយវត្ថុ មូលប្បទានប័ត្រ ប័ណ្ណឥណទានដើម្បីឱ្យមានដំណើរការរលូន និងមានប្រសិទ្ធិភាពសម្រាប់បម្រើសេចក្តីត្រូវការនៅក្នុងសេដ្ឋកិច្ច[4]។

### ១.១.៣.តួនាទីរបស់ធនាគារពាណិជ្ជ

ធនាគារពាណិជ្ជ មានតួនាទីសំខាន់ៗដូចជា៖

- អន្តរការីហិរញ្ញវត្ថុ៖ បង្វិលប្រាក់សន្សំដែល ទទួលបានពីអង្គភាព គ្រួសារឱ្យទៅជាឥណទានសម្រាប់អ្នកដែលត្រូវការមូលនិធិ ដូចជា បុគ្គល ក្រុមហ៊ុនជំនួញ និងក្រុមហ៊ុនផ្សេងៗយកទៅវិនិយោគ។
- តួនាទីទូទាត់៖ ធ្វើការទូទាត់ទំនិញ និងសេវាជូសអតិថិជនរបស់ខ្លួន (តាមរយៈការចេញផ្សាយ និងទូទាត់មូលប្បទានប័ត្រ ការផ្ទេរក្នុង ឬក្រៅប្រទេស និងផ្តល់សេវាទូទាត់អេឡិចត្រូនិក...)។
- តួនាទីជាអ្នកធានា៖ ធានាសងបំណុលជូសឱ្យអតិថិជន នៅពេលអតិថិជនមិនអាចសងបាន (ដូចជា តាមរយៈការចេញផ្សាយលិខិតឥណទានជាដើម)។
- តួនាទីជាភ្នាក់ងារ៖ ចាត់ចែង និងការពារទ្រព្យសម្បត្តិរបស់អតិថិជន ឬចេញផ្សាយ និងទទួលទូទាត់សងវិញនូវមូលប័ត្រជំនួសឱ្យអតិថិជន។
- តួនាទីនយោបាយ៖ ធ្វើជាឧបករណ៍សម្រាប់នយោបាយ ជួយរដ្ឋាភិបាលក្នុងការគ្រប់គ្រងកំណើនសេដ្ឋកិច្ច និងសម្រេចគោលដៅសង្គម[5]។

### ១.១.៤.សារៈសំខាន់របស់ធនាគារពាណិជ្ជ

ធនាគារពាណិជ្ជ ដើរតួនាទីយ៉ាងសំខាន់ក្នុងការរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងកាត់បន្ថយភាពក្រីក្រ។ ធនាគារពាណិជ្ជតភ្ជាប់អតិថិជន ដែលមានឱនភាពមូលធន (កង្វះខាតប្រាក់) ទៅនឹងអតិថិជនដែលមានអតិរេកមូលធន (សល់ប្រាក់)។ ធនាគារពាណិជ្ជជួយក្នុងការជម្រុញឱ្យ

[4] ងួន ហេង, រូបិយវត្ថុ និងធនាគារ, ២០១៤, ទំព័រទី៧៩

[5] ទេព ធីតា, ទស្សនៈទូទៅស្តីអំពីវិស័យធនាគារ និងសេវាហិរញ្ញវត្ថុ, ២០១៦, ទំព័រទី៥,៦

សាច់ប្រាក់មានចរាចរណ៍នៅក្នុងសេដ្ឋកិច្ច ព្រមទាំងធ្វើឱ្យគោលនយោបាយរូបិយវត្ថុ ដែលចេញដោយរដ្ឋាភិបាលមានប្រសិទ្ធិភាព។

## **១.២.លក្ខណៈទូទៅរបស់ឥណទាន**

### **១.២.១.និយមន័យ**

ឥណទានត្រូវបានគេឱ្យនិយមន័យជាច្រើន ដោយផ្អែកលើ តម្រូវការ និងគោលបំណងសម្រាប់ប្រើប្រាស់៖

- ឥណទាន គឺជាការផ្តល់ ឬសន្យាផ្តល់ឱ្យនូវមូលនិធិសម្រាប់ជាទុនអាជីវកម្ម តែត្រូវសងវិញដោយមានការប្រាក់ ឬជាការធានាតាមហត្ថលេខាដើម្បីសងជូសកូនបំណុលចំពោះម្ចាស់បំណុល[6]។
- ឥណទាន គឺជាមធ្យោបាយដោះដូរ ជាមួយនឹងការទទួលយកអ្នកខ្ចី ដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយត្រូវទូទាត់សំណងតាមកិច្ចសន្យានាពេលអនាគត។ ឥណទានក៏ជាការផ្តល់ហិរញ្ញវត្ថុ ឱ្យដល់អ្នកដែលខ្វះខាតហិរញ្ញវត្ថុ ហើយសន្យាសងតាមកិច្ចសន្យានៅពេលអនាគត[7]។
- ឥណទាន គឺជាមធ្យោបាយដោះដូរ ជាមួយការយល់ព្រមលើចំនួនជំពាក់ ដែលមានពេលវេលាកំណត់ ដោយត្រូវបង់ជាអត្រាការប្រាក់[8]។

### **១.២.២.ប្រភេទនៃឥណទាន**

ធនាគារឱ្យអតិថិជនខ្ចីប្រាក់ សម្រាប់គោលបំណងផ្សេងៗគ្នា ក្នុងនោះមានដូចជាការវិនិយោគ ការទិញរថយន្ត ទិញលំនៅដ្ឋាន សម្រាប់ការសិក្សានៅមហាវិទ្យាល័យជាដើម។ ប្រភេទនៃការខ្ចីអាចបែងចែកប្រភេទទៅតាមគោលបំណងនៃការប្រើប្រាស់កម្ចីរបស់អតិថិជន។ ដែលក្នុងនោះប្រភេទឥណទានមានដូចជា៖

#### **១.២.២.១.ឥណទានឯកជន**

ឥណទានឯកជន គឺជាឥណទានដែលបានប្រើប្រាស់ដោយបុគ្គល គ្រួសារ សហគ្រាស ឬធុរកិច្ចជាច្រើន ដែលនាំឱ្យមានការដោះដូរទំនិញ/សេវាកម្ម និងមូលនិធិនៅក្នុងផ្នែកឯកជន។

ឥណទានឯកជនរួមមាន៖

- ឥណទានអ្នកប្រើប្រាស់

[6] ងួន ហេង, រូបិយវត្ថុ និងធនាគារ, ២០១៤, ទំព័រទី៩៩

[7] ទុំ សុវណ្ណ, គ្រប់គ្រងឥណទាន, ២០១៥, ទំព័រទី៣

[8] http://www.investopedia.com/terms/l/loan.asp, (Retrieved date: June 9, 2017)

- ឥណទានរាយ
  - ឥណទានសងរំលស់រាយ
  - ឥណទានសេវា
- ឥណទានសាច់ប្រាក់
  - កម្ចីសងរំលស់
  - កម្ចីសងតែម្តង
  - ប័ណ្ណឥណទាន
  - ឥណទានអចលនវត្ថុ

➢ ឥណទានធុរកិច្ច
- ឥណទានទំនិញ
- ឥណទានអាជីវកម្ម។

**១.២.២.២.ឥណទានសាធារណៈ**

ឥណទានសាធារណៈ គឺជាឥណទានដែលប្រើប្រាស់ផ្ទាល់ដោយរដ្ឋាភិបាលគ្រប់កម្រិត។ រដ្ឋាភិបាលខ្ចីមូលនិធិសម្រាប់យកមកប្រើប្រាស់ក្នុងកម្មវិធីអភិវឌ្ឍរបស់ខ្លួនដូចជា៖ ការកសាង ផ្លូវ ថ្នល់ ស្ពាន សាលារៀន មន្ទីរពេទ្យ និងទីកំសាន្ត ព្រមទាំងសម្រាប់ចំណាយប្រតិបត្តិការបន្ទាន់ផ្សេងៗទៀត។ រដ្ឋាភិបាលអាចប្រើប្រាស់ប័ណ្ណបំណុលដូចជា៖ សញ្ញាប័ណ្ណ ប័ណ្ណរតនាគារ សម្រាប់ប្រមូលមូលនិធិពីអ្នកឱ្យខ្ចី។

**១.២.៣.រយៈពេលឥណទាន**

រយៈពេលនៃឥណទាន ត្រូវបានបែងចែកជា ៣ប្រភេទគឺ៖

- ឥណទានរយៈពេលខ្លី មានរយៈពេលតិចជាងមួយឆ្នាំ ឬមួយឆ្នាំ។
- ឥណទានរយៈពេលមធ្យម មានរយៈពេលចន្លោះពីមួយឆ្នាំ ទៅបីឆ្នាំ។
- ឥណទានរយៈពេលវែង មានរយៈពេលលើសពីបីឆ្នាំឡើងទៅ[៩]។

## ១.៣.គុណសម្បត្តិ និងគុណវិបត្តិនៃការប្រើប្រាស់ឥណទាន

### ១.៣.១.គុណសម្បត្តិ

**ក.ចំពោះអ្នកប្រើប្រាស់**

- ការកើនឡើងបទដ្ឋានរស់នៅ៖ ជាទូទៅអ្នកប្រើប្រាស់ទទួលបានផលប្រយោជន៍ពីការប្រើប្រាស់ឥណទាន ដោយពួកគេអាចយកចំណូលអនាគត ដែលលើសពីចំណាយ

[9] http://www.vtb.com/business/lending/lending_kind/, (Retrieved date: June 21,2017)

ប្រចាំថ្ងៃដើម្បីបំពេញសេចក្តីត្រូវការរបស់ខ្លួន មកទូទាត់សងបំណុល។ ពួកគេនឹងទទួលបាន នូវសម្ភារទំនើប ទាន់សម័យ លំនៅដ្ឋានស្អាត នៅពេលគេជ្រើសរើសកម្មវិធីឥណទាន។ ទាំងនេះនឹងធ្វើឱ្យបទដ្ឋានរស់នៅរបស់ប្រជាជនកើនឡើង និងល្អប្រសើរជាងមុន។

- ដោះស្រាយពេលមានអាសន្ន៖ ឧបទ្ទវហេតុកើតមានដោយមិនអាចគ្រោងទុកបានដូចជា គ្រោះថ្នាក់ចរាចរណ៍ មានជំងឺ រថយន្តខូច ជាដើម។ បញ្ហាទាំងនេះត្រូវការថវិការជាចាំបាច់សម្រាប់ដោះស្រាយ។ កម្មវិធីឥណទាន នឹងផ្តល់ឱ្យអ្នកប្រើប្រាស់ទទួលបាននូវមធ្យោបាយសម្រាប់ចំណាយលើពេលអាសន្នទាំងនេះបាន។
- ភាពងាយស្រួល៖ ឥណទានបានបង្កភាពងាយស្រួលជាច្រើនដល់អ្នកប្រើប្រាស់។ អ្នកប្រើប្រាស់អាចទិញទំនិញ ឬសេវាកម្ម ឬធ្វើដំណើរជុំវិញពិភពលោក គឺប្រើប្រាស់ប័ណ្ណឥណទានជំនួសឱ្យសាច់ប្រាក់វិញ។

**ខ.ចំពោះធុរកិច្ច**

- ការពង្រីកទីផ្សារ៖ ធុរកិច្ចជាច្រើនបានប្រើប្រាស់ឥណទានសម្រាប់ការពង្រីកទីផ្សារ និងការស្វែងរកអតិថិជនថ្មីៗ ប្រសិនបើគេផ្តល់ជម្រើសទិញដោយជំពាក់ (ទិញដោយឥណទាន) នោះអតិថិជនជាច្រើននឹងអាចទិញទំនិញ ឬសេវាកម្មបាន ឬទិញបន្ថែមទៀត ព្រោះថាអតិថិជនជាច្រើនខ្វះមូលនិធិជាសាច់ប្រាក់ សម្រាប់ទូទាត់ថ្លៃទំនិញ ឬសេវាកម្ម។
- ការផ្តល់ជាសន្និធិ៖ ធុរកិច្ចត្រូវពឹងលើសន្និធិសម្រាប់បង្វិលទំនិញប្រចាំថ្ងៃ។ ឥណទាននឹងផ្តល់នូវសន្និធិគ្រប់គ្រាន់ ទាន់ពេលវេលាសម្រាប់បង្វិលតាមតម្រូវការប្រចាំថ្ងៃ។
- ការទទួលបានមូលនិធិហិរញ្ញវត្ថុ៖ ធុរកិច្ចត្រូវការដើមទុនសម្រាប់ការចាប់ផ្តើមដំណើរការថែទាំ និងពង្រីកប្រតិបត្តិការអាជីវកម្ម។ ឥណទាននឹងផ្តល់ជាសាច់ប្រាក់សម្រាប់កិច្ចការទាំងនេះ ដែលឈានដល់ការស្វែងរកបាននូវប្រាក់ចំណេញបន្ថែមទៀត។

**គ.ចំពោះសេដ្ឋកិច្ច**

ឥណទានប្រៀបបានដូចជាប្រេងរំអិលសម្រាប់ក្បាលម៉ាស៊ីនសេដ្ឋកិច្ច។ ឥណទានបង្កើតចលនាសាច់ប្រាក់ និងជាមុខព្រួញផលិតកម្មនៅក្នុងសេដ្ឋកិច្ច។ ឥណទានបានផ្តល់ជាមធ្យោបាយដើម្បីស្ថិរភាពសកម្មភាពសេដ្ឋកិច្ច ដោយដាក់ចេញនូវអត្រាការប្រាក់ដើម្បីដោះដូរ ជាមួយអ្នកត្រូវការប្រើប្រាស់ឥណទាន។

### ១.៣.២.គុណវិបត្តិ

ជាក់ស្តែងឥណទានអាចមិនល្អប៉ុន្មានទេ នៅពេលអ្នកប្រើប្រាស់ប្រើវាមិនចំគោលដៅ វានឹងផ្តល់គ្រោះថ្នាក់ដល់កូនបំណុល។

**ក.ចំពោះអ្នកប្រើប្រាស់**

អ្នកដែលយកឥណទានទៅប្រើប្រាស់មិនបានត្រឹមត្រូវ ចំគោលដៅ នឹងទទួលបានមកវិញនូវបទពិសោធន៍មិនល្អ។ កូនបំណុលទាំងឡាយណា ដែលប្រើប្រាស់ឥណទានមិនបានល្អ នឹងជួបប្រទះបញ្ហាមួយចំនួនដូចជា៖ មិនអាចសងបំណុលបាន ឬអសមត្ថភាពនៅក្នុងការសងបំណុលជាដើម។ ឥណទានជាអន្ទាក់មួយធ្វើឱ្យអ្នកប្រើប្រាស់គ្មានផ្លូវដោះស្រាយបញ្ហារបស់ខ្លួន ជាលទ្ធផលចុងក្រោយ គឺឈានដល់ការបាត់បង់ទ្រព្យសម្បត្តិ កេរ្តិ៍ឈ្មោះ បែកបាក់ចំណងគ្រួសារ និងគ្មានលទ្ធភាពទទួលបានឥណទានថ្មី។

**ខ.ចំពោះធុរកិច្ច**

ធុរកិច្ចត្រូវប្រុងប្រយ័ត្ននៅពេលប្រើប្រាស់ឥណទាន។ នៅពេលមានអ្នកប្រើប្រាស់មួយចំនួនប្រើឥណទានក្នុងការទិញទំនិញ ឬសេវាកម្ម ហើយមិនសងតាមកិច្ចសន្យា នោះប្រាក់ចំណូលជាច្រើននឹងត្រូវបាត់បង់។ មានមូលហេតុសំខាន់ជាច្រើនទៀតដោយសារធុរកិច្ចនេះ អសមត្ថភាពក្នុងការអនុវត្តការគ្រប់គ្រងនយោបាយឥណទានឱ្យបានល្អ។ ធុរកិច្ចដែលមានស្ថានភាពបែបនេះ គួរតែមានវិធីសាស្ត្រទប់ស្កាត់ និងសម្រេចចិត្តឱ្យបានច្បាស់លាស់។ ការប្រមូលឥណទានត្រូវធ្វើយ៉ាងណាឱ្យចលនាសាច់ប្រាក់វិជ្ជមាន ទើបការគ្រប់គ្រងឥណទានមានប្រសិទ្ធភាព[10]។

## ១.៤.ដំណើរការនៃការគ្រប់គ្រងឥណទាន

ការគ្រប់គ្រងឥណទាន ពាក់ព័ន្ធនឹងការទាក់ទាញទឹកចិត្តដល់ការប្រើប្រាស់ឥណទាន វិភាគពីហានិភ័យអ្នកស្នើរសុំឥណទាន និងការប្រមូលសំណងក្រោយពីបំណុលត្រូវបានកើតមាន។ នៅជំហាននីមួយៗ អ្នកគ្រប់គ្រងឥណទានត្រូវបង្កើតគោលការណ៍អនុវត្ត ដែលអាចជួយឱ្យប្រាកដថាគ្រប់គណនីឥណទានអនុវត្តប្រកបដោយប្រសិទ្ធិភាព។

### ១.៤.១.ការជ្រើសរើសសំណើរសុំឥណទាន

ការជ្រើសរើសពាក្យស្នើសុំ អធិប្បាយពីការខិតខំប្រឹងប្រែងរបស់បុគ្គលិកធ្វើការដោយវាងវៃមានប្រសិទ្ធិភាព ត្រួតពិនិត្យឱ្យឃើញថា អ្នកស្នើសុំមានលក្ខខណ្ឌមូលដ្ឋានត្រឹមត្រូវសម្រាប់បើកគណនីឥណទាន។ បច្ចុប្បន្ន អ្នកផ្តល់ឥណទានជាច្រើនប្រើប្រាស់ប្រព័ន្ធដាក់ពិន្ទុ ដើម្បីជ្រើសរើសពាក្យស្នើសុំឥណទាន។ ប្រព័ន្ធដាក់ពិន្ទុឥណទាន គឺជាទម្រង់ស្ថិតិមូលដ្ឋានមួយប្រភេទ ឬកម្មវិធី

[10] ទុំ សុវណ្ណ, គ្រប់គ្រងឥណទាន, ២០១៥, ទំព័រទី៦

ដោយប្រើកុំព្យូទ័រដែលកំណត់ពិន្ទុទៅតាមរបាយការណ៍ដែលមាននៅក្នុងពាក្យស្នើសុំ របាយការណ៍ហិរញ្ញវត្ថុ ឬរបាយការណ៍នៃការិយាល័យឥណទាន។ ក្នុងអាជីវកម្ម ពិន្ទុផ្អែកលើអនុបាតហិរញ្ញវត្ថុដែលគណនាទ្រព្យសកម្ម បំណុល និងចំណូលរបស់អ្នកស្នើសុំឥណទាន។

ក្នុងឥណទានធុរកិច្ច ការជ្រើសរើសសំណើរសុំរួមមានៈ ការសិក្សា និងធ្វើការវិភាគទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលស្នើសុំឥណទាន។ ការវិភាគពាក់ព័ន្ធនឹងការគណនាអនុបាតហិរញ្ញវត្ថុ និងការគណនាផ្សេងទៀត ដោយប្រើប្រាស់ទិន្នន័យរបាយការណ៍ហិរញ្ញវត្ថុ។ លទ្ធផលត្រូវបានគេប្រើប្រាស់ ដើម្បីវាយតម្លៃពីសន្ទនីយភាព សាធនភាព ផលចំណេញ និងស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុនស្នើសុំឥណទាន។

### ១.៤.២.ការស៊ើបអង្កេតឥណទាន

ការស៊ើបអង្កេតឥណទាន ពាក់ព័ន្ធនឹងការត្រួតពិនិត្យព័ត៌មានលើពាក្យស្នើសុំឥណទាន។ ការស៊ើបអង្កេតឥណទានត្រូវធ្វើ ដើម្បីជាជំនួយក្នុងការសម្រេចចិត្តឱ្យបានត្រឹមត្រូវ។ ជាធម្មតាអ្នកគ្រប់គ្រងឥណទាននឹងបញ្ជាក់ពីចំណូល និងស្ថានភាពហិរញ្ញវត្ថុរបស់អ្នកស្នើសុំ។ បញ្ហារបស់អ្នកគ្រប់គ្រង គឺការប្រមូលព័ត៌មានឱ្យបានគ្រប់គ្រាន់ ដោយមិនចំណាយពេលវេលាច្រើនពេក និងថវិកាសម្រាប់ការស៊ើបអង្កេតច្រើន។ ម្យ៉ាងទៀត អ្នកគ្រប់គ្រងឥណទានអាចបង្កើតគោលការណ៍ឱ្យចំទិសដៅដើម្បីជំនួយក្នុងការស៊ើបអង្កេត។ ឧទាហរណ៍ អ្នកគ្រប់គ្រងឥណទានអាចបង្កើតគោលការណ៍តម្រូវឱ្យត្រួតពិនិត្យប្រវត្តិការងាររបស់អ្នកស្នើសុំយ៉ាងតិច២ឆ្នាំចុងក្រោយ។

### ១.៤.៣.ការសម្រេចចិត្តផ្តល់ឥណទាន

ការសម្រេចចិត្តផ្តល់ឥណទានជាបេះដូងសម្រាប់ការងារគ្រប់គ្រងឥណទាន អតិថិជនស្នើសុំឥណទានសម្រាប់ទំនិញ សេវាកម្ម និងមូលនិធិ។ អ្នកគ្រប់គ្រងឥណទានត្រូវតែសម្រេចចិត្ត យល់ព្រម ឬបដិសេធន៍ពាក្យស្នើសុំឥណទាន។

ការសម្រេចរួចតម្រូវឱ្យមានការរៀបចំបន្ទាត់ឥណទាន។ បន្ទាត់ឥណទាន គឺជាការឱ្យសិទ្ធដំបូងដល់អតិថិជនមានចំនួនកំណត់មួយ ហើយជាស្វ័យប្រវត្តិអនុញ្ញាតឱ្យដល់ចំនួនកំណត់ណាមួយ។ ការសម្រេចចិត្តដែលមានលក្ខណៈត្រឹមត្រូវ គឺផ្អែកទៅលើការរួមបញ្ចូលគ្នារវាងសិល្បៈ និងវិទ្យាសាស្ត្រ។ សិល្បៈ ពាក់ព័ន្ធនឹងបទពិសោធន៍ និងសមត្ថភាពក្នុងការបង្កើតសំនួរឱ្យបានត្រឹមត្រូវដើម្បីព្យាករណ៍ពីលទ្ធភាពសង។ វិទ្យាសាស្ត្រពាក់ព័ន្ធនឹងការវិភាគ ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកធ្វើការស្នើសុំ។

#### ១.៤.៤.ការត្រួតពិនិត្យលើគណនី

ការត្រួតពិនិត្យ គឺប្រើប្រាស់សម្រាប់តាមដានគណនី ដើម្បីប្រាកដថាបំណុលទាំងអស់សមស្របនឹងអតិថិជនម្នាក់ៗ។ បំណុលអាចឡើងខ្ពស់ពេក ឬអតិថិជនល្អមិនអាចប្រើឥណទានបានគ្រប់គ្រាន់។ សកម្មភាពត្រួតពិនិត្យពាក់ព័ន្ធនឹងការតាមដានពិនិត្យមើលគណនីសំណាងតាមផែនការ និងទំនាក់ទំនងរវាងអតិថិជន និងអ្នកគ្រប់គ្រងឥណទាន។ អ្នកគ្រប់គ្រងឥណទាន ត្រូវបន្ថែមព័ត៌មានថ្មីៗរបស់អតិថិជនក្នុងការសម្រេចចិត្តបង្កើន ឬដាក់កម្រិតបន្ទាត់ឥណទាន។

#### ១.៤.៥.ការទារប្រមូលឥណទាន

ការប្រមូល គឺជាការខិតខំប្រឹងប្រែងក្នុងការទទួលបានសំណងពីកូនបំណុលតាមពេលវេលាដែលបានកំណត់។ ការប្រមូលនេះ តម្រូវឱ្យមានការប្រាស្រ័យទាក់ទងជាមួយអតិថិជន រហូតដល់អតិថិជនបានសងរួចរាល់តាមកាលកំណត់។ មធ្យោបាយប្រមូលរួមមាន៖ វិក័យប័ត្រ សំបុត្រទូរស័ព្ទ សារអេឡិចត្រូនិច និងការប្រើកម្លាំងដោយស្របច្បាប់ បើសិនជាមានករណីធ្ងន់ធ្ងរមួយចំនួនលើការប្រមូលនេះ[11]។

## ១.៥.ការវាយតម្លៃឥណទាន

### ១.៥.១.ការវាយតម្លៃតាម ៦ C's

**ក.ចរិត (Character)**

ចរិតសម្តៅលើការប្រព្រឹត្ត ឫកពា ឬកិរិយាមាយាទរបស់អតិថិជន។ ចរិតកំណត់ដោយទំលាប់ និងអាកប្បកិរិយាដែលបានសម្តែងចេញ តាមរយៈការដើរ ការហូបអាហារ ការលេងល្បែងជាដើម។ ចរិតក៏សម្តែងចេញតាមរយៈសកម្មភាពជំនួញ ឬវិជ្ជាជីវៈ ដូចជាកាតព្វកិច្ចសំណាង និងការមិនគោរពសិទ្ធអ្នកដទៃជាដើម។ ចរិតនឹងបង្ហាញពីឆន្ទៈរបស់អតិថិជន ឬអ្នកស្នើសុំឥណទាន ក្នុងការទូទាត់បំណុលរបស់ពួកគាត់តាមការព្រមព្រៀង ឬកិច្ចសន្យា។

ចរិតមិនអាចវាស់វែង និងប៉ាន់តម្លៃបានទេ ដោយសារវាមានលក្ខណៈអរូបី ដែលជាការលំបាកសម្រាប់អ្នកគ្រប់គ្រងឥណទាន ដើម្បីកំណត់ និងវាយតម្លៃចរិតរបស់អតិថិជន ឬអ្នកស្នើសុំឥណទាន។ ដូច្នេះអ្នកគ្រប់គ្រងឥណទាន ត្រូវធ្វើការស៊ើបអង្កេតឥណទាន និងប្រើភាពប៉ិនប្រសព្វរបស់ខ្លួនជាចាំបាច់ក្នុងការងារ។

**ខ.សមត្ថភាព (Capacity)**

សមត្ថភាពជាលទ្ធភាពរបស់អ្នកស្នើសុំឥណទាន ដើម្បីទូទាត់កាតព្វកិច្ចបំណុលរបស់ពួកគាត់នៅពេលដល់ការកំណត់។ ជាទូទៅការវាស់វែងសមត្ថភាពរបស់អ្នកស្នើសុំឥណទានទាក់ទងនឹងការ

[11] ទុំ សុវណ្ណ, គ្រប់គ្រងឥណទាន, ២០១៥, ទំព័រទី១៨

ស៊ើបអង្កេតពីចំណូល និងការងារ។ ក្រៅពីនេះ ការចំណាយ និងបំណុលក៏ជាមធ្យោបាយសម្រាប់វាយតម្លៃ ពីសមត្ថភាពរបស់អ្នកស្នើសុំឥណទានផងដែរ។ សមត្ថភាពសងបំណុលរបស់អ្នកស្នើសុំឥណទាននឹងធ្លាក់ចុះ នៅពេលដែលចំណូលរបស់ពួកគាត់ថយចុះ ឬបាត់បង់ការងារ។

**គ.មូលធន (Capital)**

មូលធនជាភាពខ្លាំងខាងហិរញ្ញវត្ថុរបស់អ្នកស្នើសុំឥណទាន ដែលសម្តៅដល់ទ្រព្យសកម្មបម្រុងទុក។ ទ្រព្យសកម្មទាំងនោះជាទ្រព្យសកម្មរូបីដូចជា សមតុល្យប្រាក់បញ្ញើនៅធនាគារ (គណនីមានកាលកំណត់) ផ្ទះ ដីធ្លី អាគារ រថយន្ត ជាដើម និងទ្រព្យអរូបីមាន ដូចជា បទពិសោធន៍ការងារ ចំណេះដឹង ជំនាញជាដើម។ ទ្រព្យសកម្មទាំងនេះនឹងជួយសម្រួលដល់អ្នកស្នើសុំឥណទាន នៅពេលពួកគាត់ជួបប្រទះនឹងវិបត្តិហិរញ្ញវត្ថុ ដោយសារប្រាក់ចំណូលថយចុះ ឬបាត់បង់ការងារ។

**ឃ.ទ្រព្យធានា (Collateral)**

ទ្រព្យធានា សម្តៅដល់សិទ្ធជាម្ចាស់ លើទ្រព្យសម្បត្តិរបស់អ្នកស្នើសុំឥណទាន នៅពេលពួកគាត់មិនមានលទ្ធភាពសងបំណុល។ ទ្រព្យធានាផ្តល់នូវសុវត្ថិភាពសម្រាប់កម្ចី ឬក៏ជាកាតព្វកិច្ចឥណទាន។ ជាទូទៅ ទ្រព្យធានាតែងតែជាទ្រព្យសម្បត្តិទាំងឡាយណាដែលមានអាយុកាលប្រើប្រាស់បានយូរ ងាយលក់នៅលើទីផ្សារ ហើយតម្លៃមានការប្រែប្រួលតិចតួច។

**ង.លក្ខខណ្ឌ (Conditions)**

លក្ខខណ្ឌ ជាផ្នែកមួយក្នុងការវិភាគឥណទាន ដែលសម្តៅដល់ទំនាក់ទំនងរវាងអ្នកស្នើសុំឥណទាន និងប្រព័ន្ធសេដ្ឋកិច្ច។ គេត្រូវពិនិត្យថាព្រឹត្តិការណ៍សេដ្ឋកិច្ច នឹងមានឥទ្ធិពលកម្រិតណាដល់សមត្ថភាព និងឆន្ទៈសងបំណុលរបស់ពួកគាត់។ ការងារមួយចំនួនមានការប្រែប្រួលជាខ្លាំងទៅតាមនិន្នាការសេដ្ឋកិច្ចទាំងក្នុងតំបន់ និងពិភពលោក ប៉ុន្តែមានការងារខ្លះមិនសូវទទួលរងឥទ្ធិពលពីសេដ្ឋកិច្ចនោះទេ។

**ច.ការវិនិច្ឆ័យ (Common Sense)**

ជាឧបករណ៍វិភាគឥណទានមួយ នៅពេលដែលគណនីមួយបានក្លាយទៅជាគណនីពិបាកទារ។ នេះជាភារកិច្ចរបស់អ្នកគ្រប់គ្រងឥណទានក្នុងការកំណត់ថាគួរ ឬមិនគួរបន្តឥណទានដោយត្រូវឱ្យកូនបំណុលបញ្ជាក់ពីហេតុផល និងភស្តុតាងឱ្យបានច្បាស់លាស់[12]។

**១.៥.២.ការវាយតម្លៃតាម ៤ R's**

- អាជីវកម្មត្រឹមត្រូវ (Right Business)៖ អតិថិជនត្រូវមានមុខរបរច្បាស់លាស់ ស្របច្បាប់ និងមាននិរន្តរភាព មិនប៉ះពាល់បរិស្ថាន។

[12] Robert Core & Lon Mishler, 1998, Consumer and Business Credit Management, page 11

- មនុស្សត្រឹមត្រូវ (Right Person)៖ សម្តៅដល់អតិថិជន ដែលមានចរិតត្រឹមត្រូវ ទទួលខុសត្រូវលើបំណុលរបស់ខ្លួនតាមកាលកំណត់។
- ពេលវេលាត្រឹមត្រូវ (Right Time)៖ សម្តៅដល់ពេលវេលាដែលសាកសមក្នុងការផ្តល់ឥណទាន។
- ទំហំត្រឹមត្រូវ (Right Amount)៖ ផ្តល់ឥណទានតាមទំហំ ដែលអតិថិជនអាចមានលទ្ធភាពសងបំណុលវិញបាន[13]។

## ១.៦.វិធីសាស្ត្រក្នុងការសងបំណុល

វិធីសាស្ត្រនៅក្នុងការសងបំណុល ត្រូវបានគេធ្វើការបែងចែកជា៣ប្រភេទ ដោយអាស្រ័យទៅតាមប្រភេទបំណុល និងអតិថិជន ដែលក្នុងនោះរួមមាន៖ កម្ចីអប្បហារពិត កម្ចីសងតែការប្រាក់ និងកម្ចីសងរំលស់។

### ១.៦.១.កម្ចីអប្បហារពិត

កម្ចីអប្បហារពិត ជាកម្ចីដែលតម្រូវឱ្យអ្នកខ្ចីសងតែម្តងនៅចុងគ្រា ដោយក្នុងសំណងនោះមានទាំងការប្រាក់ និងប្រាក់ដើម។

ឧទាហរណ៍៖ រដ្ឋាភិបាលចេញផ្សាយ T-Bill មួយដែលមានតម្លៃចារឹក $១០,០០០ ក្នុងអត្រាការប្រាក់ ៩% ក្នុងរយៈពេល១ឆ្នាំ។ តើរដ្ឋាភិបាលគួរលក់ T-Bill ក្នុងតម្លៃប៉ុន្មាន?

Present Value = $១០,០០០/១.០៩ = $៩,១៧៤.៣១

### ១.៦.២.កម្ចីសងតែការប្រាក់

កម្ចីសងតែការប្រាក់ ជាវិធីសាស្ត្រមួយដែលតម្រូវឱ្យអ្នកខ្ចីសងតែការប្រាក់នៅគ្រាដំបូងៗ ហើយនៅចុងគ្រាទើបធ្វើការបង់ផ្តាច់ទាំងការប្រាក់ និងប្រាក់ដើម[14]។

ឧទាហរណ៍៖ លោក A ខ្ចីប្រាក់ចំនួន $១០,០០០ ក្នុងអត្រាការប្រាក់ ៩%ក្នុងមួយឆ្នាំ ជាមួយរយៈពេល ៥ឆ្នាំ។ ដូចនេះ លោក A ត្រូវធ្វើការសង $១០,០០០x0.០៩ = $៩០០ ជាការប្រាក់នៅចុងឆ្នាំទី១ ទី២ ទី៣ និងទី៤។ លោក A ត្រូវសងប្រាក់ដើម $១០,០០០ ជាមួយ និងអត្រាការប្រាក់ $៩០០ សម្រាប់ឆ្នាំទី៥។

### ១.៦.៣.កម្ចីសងរំលស់

កម្ចីសងរំលស់ត្រូវបានគេចែកជា២ប្រភេទ គឺរំលស់ប្រាក់ដើមថេរ និងរំលស់សំណងថេរ។

---

[13] https://www.linkedin.com/pulse/major-gift-asks-right-place-time-person-amount-why-mena-gainpaulsingh?articleId=6118402803741310976, (Retrieved date: June 21,2017)

[14] ជុន ចាន់ណែត, គណិតវិទ្យាហិរញ្ញវត្ថុ, ២០១៥, ទំព័រទី១៧

- **រំលស់ប្រាក់ដើមថេរ (Declining Amortization)**

ជាវិធីសាស្ត្រមួយ ដែលប្រាក់ដើមត្រូវបានគេធ្វើការរំលស់ថេរ ចំណែកឯការប្រាក់វិញត្រូវបានគេគិតដោយអាស្រ័យទៅតាមប្រាក់ដើមដែលនៅសល់ចុងគ្រា រហូតដល់សមតុល្យប្រាក់ដើមស្មើនឹងសូន្យ។

ឧទាហរណ៍៖ លោក A បានខ្ចីប្រាក់ពីធនាគារ ដែលមានចំនួនទឹកប្រាក់ $៨,០០០ ក្នុងរយៈពេល៤ឆ្នាំ ជាមួយអត្រាការប្រាក់១០%។ ក្នុងកិច្ចសន្យាតម្រូវឱ្យ លោក A ធ្វើការបង់រំលស់ប្រាក់ដើមថេរ។

**តារាងទី ១.១ ៖ រំលស់ប្រាក់ដើមថេរ**

| Year | Beginning Balance | Total Payment | Interest Paid | Principle Paid | Ending Balance |
|---|---|---|---|---|---|
| 1 | (8,000)$ | 2,800$ | 800$ | 2,000$ | (6,000)$ |
| 2 | (6,000)$ | 2,600$ | 600$ | 2,000$ | (4,000)$ |
| 3 | (4,000)$ | 2,400$ | 400$ | 2,000$ | (2,000)$ |
| 4 | (2,000)$ | 2,200$ | 200$ | 2,000$ | - |
| Total | | 10,000$ | 2,000$ | 8,000$ | |

- **រំលស់សំណងថេរ (Constant Payment)**

រំលស់សំណងថេរ ជាវិធីសាស្ត្រមួយ ដែលតម្រូវឱ្យសងជាលក្ខណៈថេរនៅចុងគ្រានីមួយៗ (ខែ ត្រីមាស ឆមាស ឆ្នាំ) ដោយនៅក្នុងនោះ ប្រាក់ដើមត្រូវបានគេរំលស់ក្នុងទិសដៅអវិជ្ជមាន ចំណែកឯការប្រាក់វិញថយចុះនៅគ្រាបន្ទាប់។ តាមរូបមន្ត[15]៖

**រូបមន្តទី ១.១ ៖ រំលស់សំណងថេរ**

$$Pv = C\left[\frac{1-(1+r)^{-t}}{r}\right] \Rightarrow C = \frac{Pv}{\left[\frac{1-(1+r)^{-t}}{r}\right]}$$

ដោយ Pv : តម្លៃបច្ចុប្បន្ននៃសាច់ប្រាក់

r : អត្រាការប្រាក់

t : ចំនួនរយៈពេលនៃគ្រានីមួយៗ

C : តម្លៃដែលត្រូវបង់រាល់គ្រានីមួយៗ

[15] ព្រំ សុគុណា, មូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុសាជីវកម្ម១, ២០១៥, ទំព័រទី៩៨

ឧទាហរណ៍៖ លោក A បានខ្ចីប្រាក់ពីធនាគារ ដែលមានចំនួនទឹកប្រាក់ $៨,០០០ រយៈពេល ៤ឆ្នាំ ជាមួយអត្រាការប្រាក់១០%។ នៅក្នុងកិច្ចសន្យាតម្រូវឱ្យ លោក A ធ្វើការបង់រំលស់ថេរ។

**តារាងទី ១.២ ៖ រំលស់សំណងថេរ**

| Year | Beginning Balance | Total Payment | Interest Paid | Principle Paid | Ending Balance |
|---|---|---|---|---|---|
| 1 | (8,000)$ | 2,523.76$ | 800$ | 1,723.76$ | (6,276.24)$ |
| 2 | (6,276.24)$ | 2,523.76$ | 627.62$ | 1,896.14$ | (4,380.1)$ |
| 3 | (4,380.1)$ | 2,523.76$ | 438.01$ | 2,085.75$ | (2,294.35)$ |
| 4 | (2,294.35)$ | 2,523.76$ | 229.41$ | 2,294.35$ | - |
| Total | | 10,095.04$ | 2,095.04$ | 8,000$ | |

## ១.៧.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន

### ១.៧.១.ចំណាត់ថ្នាក់ឥណទាន

ជាទូទៅចំណាត់ថ្នាក់ឥណទានត្រូវបានគេបែងចែកទៅតាមសមត្ថភាពសង របស់អតិថិជន។ សមត្ថភាពសងនេះត្រូវបានគេវាយតម្លៃតាមរយៈលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ប្រវត្តិនៃការទូទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងនៅពេលអនាគត
- គម្រោងលំហូរសាច់ប្រាក់ និងអាជីវកម្មសម្រាប់ពេលអនាគត ដែលផ្អែកទៅលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន
- លទ្ធភាព និងឆន្ទៈក្នុងការសងត្រលប់មកវិញរបស់អ្នកខ្ចី
- បរិស្ថានហិរញ្ញវត្ថុ និង
- គុណភាពនៃការរៀបចំឯកសារ។

ជាទូទៅធនាគារពាណិជ្ជធ្វើការបែងចែកចំណាត់ថ្នាក់បំណុលជា៥ថ្នាក់មានដូចជា៖ បំណុលធម្មតា បំណុលឃ្លាំចាំមើល បំណុលក្រោមស្តង់ដារ បំណុលសង្ស័យ និងបំណុលបាត់បង់ ឬខូចខាត។

- បំណុលស្តង់ដារ (Standard Loan) ៖ ឥណទានត្រូវបានធានាទាំងស្រុងដោយទ្រព្យសម្បត្តិ និងសមត្ថភាពទូទាត់សងរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងជាបំណុលដែលកំពុងដំណើរការដោយអនុលោមទៅតាមកិច្ចសន្យា និងរំពឹងថានៅតែបន្តដំណើរការបែបនេះរហូតតទៅ។

- បំណុលឃ្លាំចាំមើល (Non-Performing Loan) ៖ ឥណទានបែបនេះនឹងត្រូវបានធានា និងមិនទាន់ហួសកាលកំណត់សង ប៉ុន្តែមានចំនុចខ្សោយខ្លះ ដែលធ្វើឱ្យគុណភាពឥណទានចុះខ្សោយ។ ឥណទានណាដែលហួសកាលកំណត់សងចំនួន ៣០ថ្ងៃ ឬលើសនេះ ប៉ុន្តែតិចជាង ៩០ថ្ងៃ ត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំចាំមើល។
- បំណុលក្រោមស្តង់ដា (Sub-Standard Loan) ៖ ឥណទាននេះមិនត្រូវបានការពារគ្រប់គ្រាន់ ដោយទ្រព្យបញ្ចាំ និងសមត្ថភាពសងបំណុលរបស់អ្នកខ្ចី។ ឥណទានដែលការទូទាត់សងយឺតចំនួន ៩០ថ្ងៃ ឬលើសនេះ ប៉ុន្តែតិចជាង ១៨០ថ្ងៃ ត្រូវបានចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ។
- បំណុលសង្ស័យ (Doubtful Loan) ៖ ឥណទានប្រភេទបែបនេះ មានចំណុចខ្សោយដូចឥណទានក្រោមស្តង់ដារ ដោយបូកបន្ថែមលក្ខខណ្ឌដែលឥណទានមិនមានការធានាបានល្អ។ យោងតាមហេតុការណ៍ជាក់ស្តែង ស្ថានភាព និងចំណុចខ្សោយទាំងនេះ នាំឱ្យមានការសង្ស័យថា ឥណទានមិនអាចប្រមូលបានទាំងស្រុងទេ។ លទ្ធភាពបាត់បង់មានកម្រិតខ្ពស់ ប៉ុន្តែត្រូវធ្វើការរង់ចាំលើ ព្រឹត្តិការណ៍ជាក់លាក់ និងសមស្របណាមួយ។ ប្រសិនបើក្នុងរយៈពេល ១៨០ថ្ងៃហើយ ការទូទាត់សងត្រូវបានពន្យារពេលបន្ថែមទៀត នោះការចាត់ថ្នាក់ជាបំណុលសង្ស័យ។
- បំណុលបាត់បង់ ឬខូចខាត (Loss Loan) ៖ ឥណទានទាំងឡាយណា ដែលត្រូវបានចាត់ទុកថាមិនអាចប្រមូលមកវិញបាន ត្រូវចាត់ទុកជាបំណុលបាត់បង់។ ការខាតបង់ត្រូវទទួលស្គាល់ នៅពេលការទូទាត់សងប្រាក់សម្រាប់រយៈពេល ៣៦០ថ្ងៃ ឬលើសនេះ។

### ១.៧.២.សំវិធានធន

សំវិធានធន គឺជាចំនួនជាក់លាក់មួយធៀបនឹងការឱ្យខ្ចី ដែលធនាគារយល់ថាមិនអាចធ្វើការស្រោចស្រង់មកវិញបាន។ សំវិធានធន ត្រូវធ្វើតាមសមាមាត្រស្របតាមចំណាត់ថ្នាក់ឥណទានដែលបានកំណត់ ប៉ុន្តែនៅពេលដែលមានព័ត៌មានទុកចិត្តបាន បញ្ជាក់ថាការបាត់បង់អាចមានច្រើនជាង ចំនួនអប្បបរមានោះសមាមាត្រនៃសំវិធានធននឹងត្រូវធ្វើឡើងឱ្យកាន់តែធំជាងនេះ។

- សំវិធានធនទូទៅ
  - សម្រាប់ឥណទានថ្នាក់ធម្មតា ៖ ១%នៃឥណទានដុលសរុប

- សំវិធានធនជាក់លាក់
  - សម្រាប់ឥណទានថ្នាក់ឃ្លាំមើល ៖ ៣%នៃឥណទានដុល
  - សម្រាប់ឥណទានថ្នាក់ក្រោមស្តង់ដារ ៖ ២០%នៃឥណទានដុល
  - សម្រាប់ឥណទានថ្នាក់សង្ស័យ ៖ ៥០%នៃឥណទានដុល
  - សម្រាប់ឥណទានថ្នាក់បាត់បង់ ៖ ១០០%នៃឥណទានដុល[16]។

## ១.៨.ហានិភ័យឥណទាន

### ១.៨.១.និយមន័យ

ហានិភ័យឥណទាន គឺជាកម្រិតគ្រោះថ្នាក់ ដែលកើតឡើងចំពោះប្រាក់កម្ចីរបស់ធនាគារ ដោយវាអាចនឹងទទួលរងនូវការខាតបង់ ដោយសារតែអតិថិជនរបស់ខ្លួនមិនសងបំណុលទៅតាម កិច្ចសន្យា ឬសងមិនគ្រប់ចំនួនទឹកប្រាក់ទាំងដើមទាំងការប្រាក់។ ហានិភ័យនេះត្រូវបានធនាគារ យកចិត្តទុកដាក់ជាងគេ ព្រោះហានិភ័យនេះអាចធ្វើឱ្យធនាគារក្ស័យធនបាន។ ដូចនេះ មុននឹង សម្រេចចិត្តផ្តល់ឥណទាន ធនាគារតែងតែសិក្សាទៅលើហានិភ័យជាចំបង លុះត្រាតែធនាគារ យល់ឃើញថាគ្មានហានិភ័យ ឬមានហានិភ័យទាបទើបធនាគារផ្តល់ឥណទាន[17]។

### ១.៨.២.ហានិភ័យរបស់គ្រឹះស្ថានហិរញ្ញវត្ថុ

ស្ថាប័នហិរញ្ញវត្ថុ តែងតែជួបប្រទះនឹងហានិភ័យ នៅក្នុងការអនុវត្តប្រតិបត្តិការរបស់ខ្លួន ដែល ក្នុងនោះរួមមាន៖

- ហានិភ័យអត្រាការប្រាក់៖ កើតឡើងពីភាពមិនបន្សីុគ្នារវាង ទ្រព្យសកម្ម និងទ្រព្យ អកម្ម ដូចជាទ្រព្យសកម្មមានអត្រាការប្រាក់ថេរ ចំនែកឯទ្រព្យអកម្មមានអត្រាការ ប្រាក់ប្រែប្រួល (ឬផ្ទុយមកវិញ) អត្រាការប្រាក់ត្រូវបានកំណត់ដោយយោងទៅតាម គោលការណ៍ខុសគ្នា និងពេលវេលាខុសគ្នា។
- ហានិភ័យសាច់ប្រាក់ងាយស្រួល៖ គឺជាហានិភ័យនៃការខ្វះលទ្ធភាពក្នុងការបំពេញ កាតព្វកិច្ចបំណុល នៅពេលដល់ថ្ងៃកំណត់សង ព្រោះតែបំណុលរយៈពេលខ្លី យក ទៅផ្តល់ជាកម្ចីរយៈពេលវែង ដោយមិនអាចសងតាមតម្រូវការ។
- ហានិភ័យឥណទាន៖ ជាហានិភ័យនៃការមិនទូទាត់ការប្រាក់ ឬការមិនទូទាត់ប្រាក់ ដើមដោយអតិថិជន។

[16] ធនាគារជាតិនៃកម្ពុជា, កម្រងច្បាប់ និងបទបញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ, ទំព័រទី៥៧១

[17] http://www.investopedia.com/terms/c/creditrisk.asp, (Retrieved date: June 10, 2017)

- ហានិភ័យប្រតិបត្តិការះ គឺជាហានិភ័យ ដែលកើតឡើងដោយសារកំហុសឆ្គងដែលមាននៅនឹងកន្លែងធ្វើពាណិជ្ជកម្ម ឬការទូទាត់។ វាពាក់ព័ន្ធយ៉ាងសំខាន់ ជាមួយនឹងស្ថានភាពប្រតិបត្តិការរបស់បុគ្គលិក ឬការក្លែងបន្លំ។
- ហានិភ័យអត្រាប្តូរប្រាក់ះ កើតឡើងនៅពេលដែលមានប្រតិបត្តិការជារូបិយប័ណ្ណបរទេស។ ធនាគារ អាចជួបហានិភ័យនៅពេលដែលធ្វើការប្តូរប្រាក់[18]។
- ហានិភ័យកេរ្តិ៍ឈ្មោះ៖ ហានិភ័យនេះកើតចេញនៅពេលដែលសាធារណៈជនមានមតិមិនល្អមកលើធនាគារ។ ហានិភ័យនេះធ្វើឱ្យធនាគារអាចដួលរលំបាន[19]។
- ហានិភ័យនៃការអនុវត្តន៍ច្បាប់៖ ជាហានិភ័យដែលសកម្មភាពរបស់ធនាគារ អនុវត្តទៅមិនស្របទៅតាមច្បាប់ជាធរមាន។ ហានិភ័យនៃការអនុវត្តន៍ច្បាប់នេះ អាចធ្វើឱ្យធនាគារត្រូវបាត់បង់កេរ្តិ៍ឈ្មោះ បាត់បង់ឱកាសពាណិជ្ជកម្ម និងថយចុះនូវសក្តានុពលពង្រីកអាជីវកម្ម[20]។
- ហានិភ័យទីផ្សារ៖ ហានិភ័យនេះកើតឡើងដោយសារអត្រាការប្រាក់ អត្រាប្តូរប្រាក់ និងលក្ខខណ្ឌសេដ្ឋកិច្ច ដែលធ្វើឱ្យទ្រព្យសកម្ម និងទ្រព្យអកម្មមានការប្រែប្រួលតម្លៃចុះឡើងទៅតាមទីផ្សារ[21]។

### ១.៨.៣.មូលហេតុដែលបណ្តាលឱ្យមានហានិភ័យឥណទាន

**ក.មូលហេតុបណ្តាលមកពីអតិថិជន៖**

- ការព្យាករណ៍លើការវិនិយោគនៅទាប មិនមានសមត្ថភាពគ្រប់គ្រាន់។
- ការពិចារណាមិនដិតដល់ទៅលើការវិនិយោគណាមួយ ឬចូលចិត្តការវិនិយោគណាដែលមានប្រាក់ចំណេញច្រើន។
- ត្រូវបានដៃគូវិនិយោគបោកប្រាស់
- អតិថិជនខ្លះមានបំណងបោកប្រាស់ធនាគារតែម្តង។

**ខ.មូលហេតុបណ្តាលមកពីធនាគារ៖**

- បុគ្គលិកមិនមានសមត្ថភាពគ្រប់គ្រាន់ក្នុងការវាយតម្លៃអតិថិជន
- បុគ្គលិកមិនមានភាពស្មោះត្រង់

[18] http://thismatter.com/money/banking/bank-risks.htm, (Retrieved date: June 10, 2017)
[19] https://en.wikipedia.org/wiki/Reputational_risk, (Retrieved date: June 10, 2017)
[20] http://searchcompliance.techtarget.com/definition/compliance-risk, (Retrieved date: June 10, 2017)
[21] https://en.wikipedia.org/wiki/Market_risk, (Retrieved date: June 10, 2017)

- បុគ្គលិកមានចេតនាធ្វើការខ្ជីខ្ជា

**គ.មូលហេតុបណ្តាលមកពីសង្គម និងគ្រោះធម្មជាតិ**

- មានសង្គ្រាម
- ការធ្លាក់ចុះនៃសេដ្ឋកិច្ច
- ការផ្លាស់ប្តូរនយោបាយសេដ្ឋកិច្ច ឬរដ្ឋាភិបាល
- ភាពរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ រញ្ជួយដី

### ១.៨.៤.វិធីសាស្ត្រទប់ស្កាត់ហានិភ័យឥណទាន

**ក.វាយតម្លៃអតិថិជនឱ្យបានត្រឹមត្រូវ**

- គោលបំណងនៃការសុំខ្ចី
- ពិនិត្យមើលអាជីវកម្ម
- វិភាគលើរបាយការណ៍ហិរញ្ញវត្ថុ
- ពិនិត្យលើប្រវត្តិរូបអ្នកខ្ចី
- ត្រូវមានវត្ថុបញ្ចាំ ឬអ្នកធានា

**ខ.ពង្រឹងសមត្ថភាពបុគ្គលិកឱ្យមានសមត្ថភាព**

- ជ្រើសរើសបុគ្គលិកដែលមានជំនាញខាងឥណទាន
- ធ្វើការបណ្តុះបណ្តាលបន្ថែមដល់បុគ្គលិកជាចាំបាច់
- ដាក់ទោសទៅលើបុគ្គលិកដែលមានកំហុស
- លើកទឹកចិត្តដល់បុគ្គលិកដែលធ្វើការបានល្អ[22]។

### ១.៨.៥.ដំណោះស្រាយឥណទានមានបញ្ហា

នៅពេលដែលធនាគារផ្តល់កម្ចីទៅឱ្យអតិថិជន ធនាគារនឹងអាចប្រឈមមុខនឹងឥណទានមានបញ្ហា។ ឥណទានមានបញ្ហា អាចមានផលប៉ះពាល់ទៅដល់លំហូរសាច់ប្រាក់របស់ធនាគារ។ ឥណទានមានបញ្ហា មានលក្ខណៈស្មុគស្មាញក្នុងការដោះស្រាយ ដែលតម្រូវឱ្យធនាគារមានការយកចិត្តទុកដាក់។ ដំណោះស្រាយឥណទានមានបញ្ហាមានដូចខាងក្រោម៖

- ធ្វើការរាយការណ៍ភ្លាមៗនៅពេលមានការសង្ស័យថាឥណទានមានបញ្ហា ដើម្បីធ្វើការរកដំណោះស្រាយ

[22] ងួន ហេង, រូបិយវត្ថុ និងធនាគារ, ២០១៤, ទំព័រទី១១៤

- ធ្វើការកំណត់ពីមូលហេតុនៃបញ្ហា ដើម្បីដឹងថាវាជាបញ្ហាផ្នែកខាងក្នុងរបស់ធនាគារ ឬផ្នែកខាងក្រៅ ឬមូលហេតុបណ្តាលមកពីអតិថិជន[23]។
- នៅពេលដែលបញ្ហាមកពីអតិថិជន ធនាគារអាចធ្វើការទាមទារប្រឆាំងនឹងអ្នកខ្ចី ឬព្យាយាមទាមទារពីអ្នកធានា។
- ធនាគារអាចដាក់ពាក្យបណ្តឹងទៅកាន់តុលាការ ដើម្បីឱ្យធនាគារអាចមានសិទ្ធិលើទ្រព្យដែលអតិថិជនបានដាក់ជាទ្រព្យធានា[24]។

## ១.៩.តួនាទីឥណទានក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ

តួនាទីចំបងៗរបស់ធនាគារពាណិជ្ជ នៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិមាន៖

### ១.៩.១.ការគ្រប់គ្រងហានិភ័យ

ចំណុចនេះកើតមានឡើងនៅពេលដែល ធនាគារផ្តល់កម្ចីទៅឱ្យអ្នកជំនួញ ឬបុគ្គល។ ឧទាហរណ៍ ពេលដែលបុគ្គលម្នាក់ៗសុំខ្ចីប្រាក់ពីធនាគារ ធនាគារនឹងធ្វើការពិនិត្យលើហិរញ្ញវត្ថុរបស់បុគ្គលនោះ ដោយរួមបញ្ចូលទាំងចំណូល បំណុលដែលធ្លាប់មាន។ លទ្ធផលដែលកើតឡើងពីការវិភាគនេះអាចជួយឱ្យធនាគារវាយតម្លៃពីកម្រិតហានិភ័យរបស់អតិថិជន។ តាមការវាយតម្លៃពីហានិភ័យរបស់អ្នកសុំខ្ចី ធនាគារអាចកាត់បន្ថយហានិភ័យហិរញ្ញវត្ថុ។ ជាលទ្ធផលកម្ចីដែលមិនមានហានិភ័យ ឬហានិភ័យទាបអាចជួយឱ្យធនាគារពង្រីកនូវមូលធនធនាគារនៅក្នុងការផ្តល់កម្ចី ដែលជាហេតុជួយដល់ការអភិវឌ្ឍសេដ្ឋកិច្ច។

### ១.៩.២.បុគ្គល

នៅពេលដែលធនាគារកំណត់បាននូវហានិភ័យ ធនាគារអាចធានាបានថាតើកម្ចីត្រូវផ្តល់ឱ្យទៅអតិថិជនប្រភេទណាខ្លះ។ ដូច្នេះអ្នកសុំខ្ចីអាចប្រើប្រាស់នូវកម្ចីរបស់ខ្លួនដើម្បីធ្វើជំនួញ ឬក៏ប្រើប្រាស់លើការទិញផ្ទះ ការសិក្សា និងចំណាយលើការប្រើប្រាស់ផ្ទាល់ខ្លួន។ នៅក្នុងសកម្មភាពនេះធនាគារពាណិជ្ជបានជះឥទ្ធិពលទៅលើសកម្មភាពសេដ្ឋកិច្ចនៅក្នុងប្រទេស ដែលការផ្តល់មូលនិធិកម្ចីនេះអាចឱ្យពួកគេទទួលបានប្រភពធនធាន ក៏ដូចជាពង្រីកជំនួញរបស់ពួកគាត់។

[23] http://www.gbrw.com/_literature_129465/Preventing_and_Resolving_Non-Performing_Loans, (Retrieved date: June 21, 2017)

[24] http://www.iflr.com/Article/2026910/How-banks-can-reduce-the-risks-of-bad-loans.html, (Retrieved date: June 22, 2017)

### ១.៩.៣.ជំនួញ

ធនាគារពាណិជ្ជបានផ្តល់ហិរញ្ញប្បទានទៅឱ្យម្ចាស់ជំនួញតូច និងមធ្យមទៅតាមវិធីសាស្ត្រជាច្រើន។ ម្ចាស់ជំនួញអាចទទួលបានកម្ចីដើម្បីបង្កើតក្រុមហ៊ុនតូច ឬមធ្យម។ នៅពេលដែលជំនួញទាំងនោះមានមូលធនគ្រប់គ្រាន់ ពួកគេក៏ចាប់ផ្តើមដំណើរការ និងអភិវឌ្ឍន៍ផែនការរបស់ខ្លួន។ ការបង្កើតជំនួញនេះ បានជះឥទ្ធិពលទៅដល់ ភាពមានការងារធ្វើ របស់ប្រជាជនទូទាំងប្រទេស។

### ១.៩.៤.ការចំណាយរបស់រដ្ឋាភិបាល

ធនាគារពាណិជ្ជ ក៏ជួយគាំទ្រដល់រាជរដ្ឋាភិបាលដែលអាចចាត់ទុកថាជាភ្នាក់ងារក្នុងការអភិវឌ្ឍសេដ្ឋកិច្ច។ ជាទូទៅ ធនាគារពាណិជ្ជជួយសម្រួលដល់រដ្ឋាភិបាលនៅក្នុងការទិញមូលប័ត្រ (Bonds and Treasury) នៅពេលណាដែលរដ្ឋាភិបាលមានឱនភាពថវិការ និងជួយដល់រដ្ឋាភិបាលនៅក្នុងកម្មវិធីអភិវឌ្ឍន៍ជាដើម[25]។

[25] ងួន ហេង, រូបិយវត្ថុ និងធនាគារ, ២០១៤, ទំព័រទី១១៥

# ជំពូកទី២

# ស្ថានភាពទូទៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

## ២.១.លក្ខណៈទូទៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

### ២.១.១.ប្រវត្តិរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានបង្កើតឡើងនៅខែកញ្ញា ឆ្នាំ២០១៣ ជាធនាគារពាណិជ្ជ ដែលបាន ទទួលអាជ្ញាប័ណ្ណពេញលេញ ដោយមានដៃគូយុទ្ធសាស្ត្ររវាង កាណាឌីយ៉ា អ៊ីនវេសមែន ហូលឌីង ភី អិល ស៊ី (CIHP) ចំនួន ៥០% ហ្វុលលើតុនហ្វាយនែនសលហូលឌីង ភីធី អ៊ី អិលធីឌី (FFH) ចំនួន ៤៥% និងក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា (MPT) មានចំនួន៥% ។

ចាប់តាំងពីការកកើតដំបូងក្នុងខែកញ្ញា ឆ្នាំ២០១៣ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានបង្កើន ដើមទុន រហូតដល់សាមសិបប្រាំបីលានដុល្លារអាមេរិក។ នៅឆ្នាំ២០១៥ ធនាគារបានបន្ថែមដើមទុន ចុះបញ្ជីពី សាមសិបប្រាំបីលានដុល្លារអាមេរិក ដល់ សែសិបប្រាំពីរលានប្រាំរយពាន់ដុល្លារអាមេរិក ដែលជាការគាំទ្រដល់ ប្រតិបត្តិការដែលមានការរីកចម្រើនយ៉ាងឆាប់រហ័ស នៅក្នុងវិស័យធនាគារ។ ដោយសារនិន្នាការនៃការរីកចម្រើន ធនាគារបានដាក់ចូលបន្ថែមនូវដើមទុនសាមសិបលានដុល្លារ អាមេរិកទៀតនៅឆ្នាំ២០១៦។ ក្រោយមកទៀតដោយមើលឃើញពីកំណើនរីកលូតលាស់នៃសេដ្ឋកិច្ចក៏ដូចជាការរីកចម្រើនលើ វិស័យហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានសម្រេចចិត្តទិញយកភាគហ៊ុនរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណន ភីអិលស៊ី ១០០% ។

បច្ចុប្បន្នគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ហ្វូណន ភីអិលស៊ី គឺជាបុត្រសម្ព័ន្ធរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ដែលហ្វូណន មានបណ្តាញប្រតិបត្តិការចំនួន ៥១ សាខាគ្របដណ្តប់នៅទូទាំងប្រទេសកម្ពុជា ។ តាមរយៈបណ្តាញប្រតិបត្តិការដ៏ធំទូលាយជិត ១០០ កន្លែង (ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និងហ្វូណន ភីអិលស៊ី) អតិថិជននឹងកាន់តែមានភាពងាយស្រួលក្នុងការទំនាក់ទំនងក៏ដូចជាប្រើប្រាស់សេវាកម្មផ្សេងៗ រួមទាំងបង់សងឥណទាន។

### ២.១.២.ទស្សនៈវិស័យ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ គឺជាធនាគារផ្តល់សេវាកម្មហិរញ្ញវត្ថុឈានមុខគេ ជូនចំពោះអតិថិជនគ្រប់កំរិត ដើម្បីលើកកម្ពស់ជីវភាព និងជួយបំពេញបំណង រីកចម្រើនរបស់ប្រជាជនកម្ពុជាហើយបង្កើតតំលៃជានិរន្ត ដល់ភាគទុនិក បុគ្គលិក និង សង្គម។

### ២.១.៣.បេសកកម្ម

បេសកកម្មរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ គឺការអភិវឌ្ឍផលិតផល និងសេវាកម្មហិរញ្ញវត្ថុប្រកបដោយភាពច្នៃប្រឌិតតាមតម្រូវការទីផ្សារ ព្រមទាំងបម្រើសេវាល្អបំផុតជូនអតិថិជន។

### ២.១.៤.គោលដៅ

គោលដៅរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ គឺត្រូវផ្តល់ផលិតផល និងសេវាកម្មធនាគារដ៏ល្អបំផុត និងមានសុវត្ថិភាពខ្ពស់តាមរយៈសាខា និងបណ្តាញដ៏ច្រើនរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ជូនអតិថិជនគ្រប់ស្រទាប់ ដោយប្រមើលមើលតម្រូវការរបស់អតិថិជន និងត្រៀមលក្ខណៈរួចជាស្រេច ដើម្បីឆ្លើយតបទៅនឹងតម្រូវការទាំងនោះ ឱ្យបានទាន់ចិត្ត ផ្តល់នូវប្រតិបត្តិការហិរញ្ញវត្ថុដ៏រឹងមាំ និងជាក់លាក់ រក្សានូវបរិយាកាសការងារមួយដែលអាចទាក់ទាញ ថែរក្សា និងអភិវឌ្ឍកម្មករ និយោជិកដែលមានឆន្ទៈការងារខ្ពស់ដែលបានរួមចំណែកក្នុងការធ្វើឱ្យធនាគារទទួលបានជោគជ័យ និងការគិតគូរដល់សហគមន៍ និងបរិស្ថានផងដែរ។

### ២.១.៥.វប្បធម៌ការងារ

វប្បធមិការងារគឺជាក្រម ឬបទបញ្ញត្តិសម្រាប់ធ្វើការរៀបចំគោលនយោបាយ ដើម្បីឱ្យអង្គភាពមានដំណើរការល្អប្រសើរនៅក្នុងសង្គម សហគមន៍ក្នុងប្រទេស និងលើឆាកអន្តរជាតិ។ វប្បធមិការងារឆ្លុះបញ្ចាំងអំពីគុណភាព បច្ចេកទេស និងវិជ្ជាជីវៈនៅអង្គភាពមួយ។

វប្បធមិការងាររបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានដូចជាៈ

- ការហៅ លោកគ្រូ-អ្នកគ្រូ
- មានការប្តេជ្ញាចិត្តប្រកបដោយឆន្ទៈ ក្នុងការសម្រេចការងារឱ្យមានប្រសិទ្ធិភាព
- ប្រឹងប្រែងរៀនសូត្រពីខ្លួនឯង ពីអ្នកដ៏ទៃ និងអ្វីៗដែលនៅជុំវិញខ្លួនដោយយកចិត្តទុកដាក់
- មានភាពស្អាតស្អំ ស្មោះត្រង់ សាមគ្គីភាព និងឯកភាព
- មិនប្រមាថការងារ មិនពុករលួយ មិនស៊ីសំណូក
- ទន់ភ្លន់ សុភាពរាបសា តែមានភាពម៉ត់ចត់ក្នុងការងារ
- មានការចូលរួមខ្ពស់ពីគ្រប់លំដាប់ថ្នាក់ និងគ្រប់ផ្នែកការងារ។

### ២.១.៦.អភិបាលកិច្ចសាជីវកម្ម

ក្រុមប្រឹក្សាភិបាលនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ យល់ឃើញថាអភិបាលកិច្ចសាជីវកម្មគឺជាចំនុចដ៏សំខាន់របស់ធនាគារ ហើយថែមទាំងជួយផ្តល់ផលប្រយោជន៍ផ្នែកធុរកិច្ច សម្រាប់ធនាគារ។ អភិបាលកិច្ចសាជីវកម្មជួយពង្រីកវិសាលភាព បង្កើនកេរ្តិ៍ឈ្មោះ និងភាពទាក់ទាញដល់អតិថិជន អ្នកវិនិយោគ អ្នកផ្គត់ផ្គង់ និងសហគមន៍។ ធនាគារបានខិតខំ ប្រឹងប្រែងយ៉ាងខ្លាំងដើម្បី

កសាងនូវវប្បធម៌ការងារល្អ ព្រមទាំងបានបង្កើតនូវមុខងារសវនកម្មផ្ទៃក្នុង ដើម្បីធានាបាននូវប្រសិទ្ធភាព។ ប្រព័ន្ធអភិបាលកិច្ចសាជីវកម្មរបស់ធនាគារត្រូវ បានរចនាឡើងដើម្បីបង្កើតតម្លៃប្រកបដោយនិរន្តរភាព និងធានាពីប្រសិទ្ធិភាពនៃការគ្រប់គ្រងហានិភ័យ ។ តួនាទីរបស់ក្រុមប្រឹក្សាភិបាល ត្រូវបានកំណត់តាមខ្នាតគំរូអន្តរជាតិ ដោយអនុឡោមតាម ក្របខណ្ឌច្បាប់ និងបទប្បញ្ញត្តិក្នុងតំបន់។ ការទទួលខុសត្រូវរបស់សមាជិកក្រុមប្រឹក្សា ភិបាលត្រូវបានបង្ហាញយ៉ាងច្បាស់ទៅកាន់ពួកគាត់ ដូចជា ការរីកចំរើននៃការបង្កើតប្រព័ន្ធគ្រប់គ្រងហានិភ័យ ការអនុឡោមតាមបទដ្ឋានអភិបាលកិច្ចសាជីវកម្ម សមាសភាព គណៈកម្មាធិការ និងសមាជិកនានាក៏ដូចជារយៈពេលនៃកិច្ចប្រជុំត្រូវបានបង្ហាញយ៉ាងច្បាស់ ទៅក្រុមប្រឹក្សាភិបាល។

## ២.២.អត្តសញ្ញាណរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

- **រូបសញ្ញា**

**រូបភាពទី ២.១ ៖ និមិត្តសញ្ញារបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ**

នៅផ្នែកខាងឆ្វេងមានរូបសញ្ញាអន្តួន ដែលទាញចេញពីអក្សរអង់គ្លេស CNP ដែលបង្ហាញពីភាពរីកចម្រើនឥតដែនកំណត់ ក្នុងការផ្តល់សេវាហិរញ្ញវត្ថុជូនអតិថិជនរបស់ខ្លួន។

នៅផ្នែកខាងស្តាំនៃរូបសញ្ញាមានចារឹកអក្សរសម្គាល់ថា **“ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ”** ជាអក្សរផុសពណ៌ខៀវ និងមានចរឹកជាពាក្យភាសាចិន និងអង់គ្លេសពណ៌ខៀវនៅពីខាងក្រោមថា **“CAMBODIA POST BANK PLC”**។ ហើយពាក្យថា **ក.អ** ជាអក្សរបំព្រួញនៃពាក្យថា **ក្រុមហ៊ុនអនាមិក** ឬមានន័យជាភាសាអង់គ្លេសថា Public Limited Company (PLC.) ។

## ២.៣.ទីតាំងតូមិសាស្ត្រការិយាល័យកណ្តាលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

ការិយាល័យកណ្តាលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានទីតាំងស្ថិតនៅអគារលេខ ២៦៥-២៦៩ វិថីព្រះបាទអង្គឌួង សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ។

ទូរស័ព្ទលេខ ៖ +(៨៥៥) ២៣ ២២០ ៧៧២/ ០២៣ ២២០ ៧៧៣/ ០៧០ ៦០០ ០៩៨

ទូរសារលេខ ៖ +(៨៥៥) ២៣ ៨២៧ ០៦៤

អ៊ីម៉ែល ៖ bm-opd@cambodiapostbank.com

គេហទំព័រ ៖ www.cambodiapostbank.com.kh

## ២.៤.បណ្តាញប្រតិបត្តិការរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

ការិយាល័យកណ្តាលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានទីតាំងស្ថិតនៅរាជធានីភ្នំពេញ។ នៅខែកញ្ញា ឆ្នាំ២០១៣ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានតែសាខាការិយាល័យកណ្តាលមួយប៉ុណ្ណោះ។ ឆ្នាំ២០១៤ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានពង្រឹងបន្ថែមសាខារបស់ខ្លួនចំនួន១៨ថែមទៀត នៅតំបន់រាជធានីភ្នំពេញ និងនៅតាមបណ្តាលខេត្តដទៃទៀតដូចជា៖ សាខាទឹកថ្លា សាខាតាខ្មៅ សាខាកំពង់ធំ សាខាបាត់ដំបង សាខាកំពត សាខាកាណាឌីធី សាខាច្បារអំពៅ សាខាប៉ោតប៉ែត សាខាកំពង់ចាម សាខាពោធិ៍សាត់ សាខាអូឡាំពិក សាខាសៀមរាប សាខាថ្មគោល សាខាបន្ទាយមានជ័យ សាខាតាកែវ សាខាកំពង់ស្ពឺ សាខាសុវណ្ណា សាខាបាកាន។ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ជាធនាគារដែលមានការរីកចម្រើនយ៉ាងឆាប់រហ័ស ដោយបានបម្រើសេវាអតិថិជនបានលឿន និងប្រកបទៅដោយភាពច្នៃប្រឌិត។ នៅឆ្នាំ២០១៥ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក៏បានទទួលអាជ្ញាប័ណ្ណឱ្យប្រតិបត្តិការសាខាចំនួន១២ថែមទៀតពីធនាគារជាតិនៃកម្ពុជា។ សាខាទាំង១២នោះមានដូចជា៖ សាខាស្វាយរៀង សាខាព្រៃវែង សាខាអូរបែកក្អម សាខាកៀនស្វាយ សាខាពូក សាខាស្ទោង សាខាស្អាង សាខាប៉ៃលិន សាខាឧត្តរមានជ័យ សាខាជ្រោយចង្វារ សាខាបារិត និងសាខាសំពៅលូន។ នៅឆ្នាំ២០១៦ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក៏បានបើកប្រតិបត្តិការសាខាបន្ថែមទៀតដូចជាសាខាអង្គស្នួល សាខាពញាក្រែក សាខាក្រចេះ សាខាមេមត់ សាខាបារាយ សាខាក្រុងបាត់ដំបង សាខាច្បារអំពៅ សាខាដូនពេញ សាខាសៀមរាបជាដើម។ ដោយផ្តោតទៅលើការបម្រើសេវាដល់អតិថិជននៃទីផ្សារធំៗ និងអាជីវកម្មតូចៗ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ នឹងពង្រឹងចំណេះដឹងជាមូលដ្ឋាននៃការវិនិយោគរបស់កាណាឌីយ៉ា អ៊ីនវេសមែន ហូលឌីង ភីអិលស៊ី និងប្រៃសណីយ៍កម្ពុជា និងអ្នកជំនាញរបស់ហ្វុលលើតុន ដែលបានកំពុងបម្រើដល់អតិថិជនទាំងនោះ ដោយប្រើប្រាស់នូវបច្ចេកវិទ្យាប្រកបទៅដោយគំនិតច្នៃប្រឌិត មានការគាំទ្រដោយការគ្រប់គ្រងហានិភ័យយ៉ាងម៉ត់ចត់ និងអភិបាលកិច្ចសាជីវកម្មដ៏ល្អ។ ដោយមានគោលជំហរដ៏រឹងមាំ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មានគោលបំណងពង្រីកបន្ថែមនូវទីតាំងសាខាបន្ថែមទៀតទៅទូទាំងប្រទេសកម្ពុជា ក្នុងកំឡុងពេលប៉ុន្មានឆ្នាំខាងមុខនេះ។

### ២.៤.១.ទីតាំងភូមិសាស្ត្ររបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក មានទីតាំងស្ថិតនៅផ្ទះលេខ ២៨៩-២៩១ ផ្លូវព្រះមុនីវង្ស សង្កាត់វាលវង់ ខណ្ឌ ៧មករា រាជធានីភ្នំពេញ។

ទូរស័ព្ទលេខ ៖ +(៨៥៥) ២៣ ២១៦ ៨០៣/ ០២៣ ៦០០ ០៩១/ ០៧០ ៦០០ ០១៥

អ៊ីម៉ែល ៖ bm-olp@cambodiapostbank.com

គេហទំព័រ ៖ www.cambodiapostbank.com.kh

**រូបភាពទី ២.២ ៖ រូបភាពរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក**




## ២.៤.២.ប្រវត្តិរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ត្រូវបានបង្កើតឡើងនៅចុងខែមីនា ឆ្នាំ២០១៣ ក្រោមរូបភាពជាការិយាល័យខ័ណ្ឌដែលចាប់ពីថ្ងៃកើត រហូតដល់ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៥ ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយលោក ឈុន ឌីណា ដែលជានាយកសាខាអូឡាំពិក និងចាប់ពីថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០១៥ រហូតដល់បច្ចុប្បន្ន ស្ថិតក្រោមការគ្រប់គ្រងផ្ទាល់ដោយលោក កាន ស៊ីវ ដែលជានាយកសាខាអូឡាំពិក ដោយមានបុគ្គលិកបម្រើការងារចំនួន ៣៣នាក់ ក្នុងនោះ មានបុគ្គលិកនារីចំនួន ៩នាក់ និងបុគ្គលិកបុរសចំនួន ២៤នាក់។

នៅចុងឆ្នាំ២០១៦ សមតុល្យឥណទានសរុបដែលបានផ្តល់ឱ្យអតិថិជនស្មើ ១៤,៨៨០,០០០ ដុល្លារអាមេរិក និងមានអតិថិជនសកម្មចំនួន ៩៣៦នាក់ ចំណែកឯសមតុល្យប្រាក់សន្សំស្មើនឹង ២១,៣៣៨,៩០០ដុល្លារអាមេរិក និងអតិថិជនចំនួន ១,៧៦៦នាក់។

## ២.៤.៣.ភាគទុនិក

**តារាងទី ២.១ ៖ ភាគទុនិករបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ**

| ភាគទុនិក | ភាគរយ |
|---|---|

| | |
|---|---|
| កាណាឌីយ៉ា អ៊ីនវេសមែន ហូលឌីង ភី អិល ស៊ី | ៥០% |
| ហ្វុលលើតុនហ្វាយនែនសលហូលឌីង ភី ធី អ៊ី អិលធីឌី | ៤៥% |
| ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍កម្ពុជា | ៥% |
| **សរុប** | **១០០%** |

### ២.៤.៤.អង្គការលេខរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

រូបភាពទី ២.៣ ៖ អង្គការលេខរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ




## ២.៥.ផលិតផល និងសេវាកម្មរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ

### ២.៥.១.ផលិតផលឥណទាន

ផលិតផលឥណទានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ត្រូវបានបង្កើតឡើងសម្រាប់ផ្តល់ជាមូលនិធិក្នុងការបង្កើត ឬពង្រីកមុខរបរ ដើម្បីស្វែងរកក្តីស្រមៃរបស់ពួកគេ។ ផលិតផលឥណទានទាំងនោះរួមមាន៖

#### ២.៥.១.១.ឥណទានខ្នាតតូចបំផុត

ជាប្រភេទឥណទាន ដែលអតិថិជនអាចខ្ចីដើម្បីប្រើប្រាស់តាមសេចក្តីត្រូវការរបស់ខ្លួន ដោយធនាគារផ្តល់ជូនជា លុយរៀលខ្មែរ លុយបាតថៃ និងលុយដុល្លារសហរដ្ឋអាមេរិក។ ជាមួយទំហំទឹកប្រាក់ពី ៣០០$ រហូតដល់ ៣,០០០$។

**២.៥.១.២.ឥណទានខ្នាតតូច**

ឥណទានប្រភេទនេះ ផ្តល់ជូនអតិថិជនដើម្បីបំពេញបំណងរបស់គាត់ ដោយប្រើតាមសេចក្តីត្រូវការ។ ធនាគារអនុញ្ញាត្តិឱ្យអតិថិជនធ្វើការខ្ចីប្រាក់ជា លុយរៀលខ្មែរ លុយបាតថៃ និងលុយដុល្លារសហរដ្ឋអាមេរិក ជាមួយអត្រាការប្រាក់សមរម្យ។ អតិថិជនអាចធ្វើការខ្ចីប្រាក់ចាប់ពី ៣,០០០$ រហូតដល់ ៥០,០០០$ ជាមួយរយៈពេលចាប់ពី៦ខែ ដល់៥ឆ្នាំ។

**២.៥.១.៣. ឥណទានខ្នាតមធ្យម**

ជាប្រភេទឥណទាន ដែលផ្តល់ជូនក្នុងការប្រើប្រាស់តាមគោលដៅ និងសេចក្តីត្រូវការរបស់អតិថិជន។ ធនាគារផ្តល់ជូនអតិថិជនជាមួយអត្រាការប្រាក់សមរម្យ និងរូបិយប័ណ្ណជាលុយរៀលខ្មែរ លុយបាតថៃ និងលុយដុល្លារសហរដ្ឋអាមេរិក។ សម្រាប់រយៈពេលឥណទាន អតិថិជនអាចធ្វើការស្នើសុំ ប្រសិនបើអតិថិជនត្រូវការប្រើប្រាស់លើសពីរយៈពេល ដែលធនាគារបានកំណត់។ អតិថិជនអាចខ្ចីប្រាក់ចាប់ពី៥០,០០០$ រហូតដល់ ២៥០,០០០$។

**២.៥.១.៤.ឥណទានកសិកម្ម**

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានបង្កើតគោលនយោបាយឥណទានកសិកម្ម ដាច់ដោយឡែក ដើម្បីបំពេញតម្រូវការអតិថិជនគោលដៅ ដែលមិនទាន់បានទទួលសេវាឥណទាននៅក្នុងប្រទេសកម្ពុជា ជាពិសេសសម្រាប់អតិថិជន ដែលមានអាជីវកម្មផ្ទាល់ខ្លួនស្ថិតនៅក្នុងវិស័យកសិកម្ម។ រាល់ឥណទានទាំងអស់តម្រូវឲ្យមានទ្រព្យធានា។

**លក្ខខណ្ឌដើម្បីទទួលប្រាក់កម្ចី៖**

- ប្រភេទរូបិយប័ណ្ណមានដូចជា ប្រាក់រៀល ប្រាក់បាតថៃ និងប្រាក់ដុល្លារអាមេរិក
- ទំហំឥណទានរហូតដល់ ៥០,០០០ដុល្លារអាមេរិក
- របៀបនៃការសងត្រលប់មានភាពបត់បែន
- មានទីលំនៅអចិន្ត្រៃយ៍
- មានអាជីវកម្ម ឬមុខរបរច្បាស់លាស់ និងស្របច្បាប់
- អាយុចាប់ពី១៨ ដល់ ៧០ ឆ្នាំ
- ទ្រព្យធានា (ប្លង់រឹង ឬប្លង់ទន់)។

**២.៥.១.៥.ឥណទានមិនមែនកសិកម្ម**

ឥណទានមិនមែនកសិកម្ម គឺជាឥណទានមានកាលកំណត់ដែលត្រូវបានបង្កើតឡើងសម្រាប់គោលបំណងផ្សេងៗដែលមិនទាក់ទងទៅនឹងកសិកម្ម សម្រាប់អតិថិជនដែលស្ថិតនៅក្នុងចំណែកទីផ្សារមានដូចជា៖ មានចំណូលពីប្រាក់បៀវត្សរ៍ មានអាជីវកម្មផ្ទាល់ខ្លួន និង សហគ្រាសខ្នាតតូចនិង

មធ្យម។ អតិថិជនគោលដៅសម្រាប់ឥណទានប្រភេទនេះអាចមកពីទីក្រុងឬជនបទដែលមានទ្រព្យធានាជាអចលនទ្រព្យ។

**លក្ខខណ្ឌដើម្បីទទួលប្រាក់កម្ចី៖**

- ប្រភេទរូបិយប័ណ្ណមានដូចជា ប្រាក់រៀល ប្រាក់បាតថៃ និងប្រាក់ដុល្លារអាមេរិក
- ទំហំឥណទានរហូតដល់ ២៥០,០០០ដុល្លារអាមេរិក
- រយៈពេលឥណទានរហូតដល់ ៨៤ខែ
- របៀបនៃការសងត្រលប់មានភាពបត់បែន
- មានទីលំនៅអចិន្ត្រៃយ៍
- មានអាជីវកម្ម ឬមុខរបរច្បាស់លាស់ និងស្របច្បាប់
- អាយុចាប់ពី១៨ ដល់ ៧០ ឆ្នាំ
- ទ្រព្យធានា (ប្លង់រឹង ឬប្លង់ទន់)។

**២.៥.១.៦.ឥណទានវិបារូបរ៍**

ឥណទានវិបារូបរ៍ ដែលមានប្រាក់បញ្ញើមានកាលកំណត់ជាទ្រព្យធានា អាចឲ្យអតិថិជនដែលមានបញ្ហាសាច់ប្រាក់ម្តងម្កាល ដែលបណ្តាលមកពីភាពយឺតយ៉ាវនៃចរន្តសាច់ប្រាក់ ឬបញ្ហាកកស្ទះទុនបង្វិលរបស់ពួកគាត់។ អតិថិនអាចដកប្រាក់ប្រើប្រាស់ពីគណនីសន្សំ ឬចរន្ត លើសពីសមតុល្យដែលមាន (សមតុល្យអវិជ្ជមាន) ស្របតាមកម្រិតអនុម័តដែលបានព្រមព្រៀងជាមួយធនាគារ។ ការប្រាក់នឹងត្រូវបានគិតលើចំនួនទឹកប្រាក់ដែលបានដកប្រើប្រាស់នោះ។

**លក្ខណៈពិសេសរបស់ឥណទានវិបារូបរ៍៖**

- ប្រភេទរូបិយប័ណ្ណជាប្រាក់ដុល្លារអាមេរិកតែប៉ុណ្ណោះ
- ទំហំឥណទានអតិបរមាស្មើនឹង ៩៥% នៃសមតុល្យប្រាក់បញ្ញើមានកាលកំណត់
- អាយុចាប់ពី ២០ ដល់ ៦០ឆ្នាំ
- រយៈពេលឥណទានរហូតដល់១២ខែ
- ទទួលយកវិញ្ញាបនប័ត្រប្រាក់បញ្ញើមានកាលកំណត់ច្បាប់ដើមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ តែប៉ុណ្ណោះសម្រាប់ធ្វើជាទ្រព្យធានា។

**អត្ថប្រយោជន៍របស់ឥណទានវិបារូបរ៍៖**

- បំពេញកង្វះខាតសាច់ប្រាក់រយៈពេលខ្លី
- មានភាពងាយស្រួល
- អាចធ្វើការទូទាត់ក្នុងរយៈពេលខ្លីជាមួយអត្រាការប្រាក់ទាប។

**២.៥.១.៧.ឥណទានគេហដ្ឋាន**

លោកអ្នកអាចក្លាយជាម្ចាស់គេហដ្ឋាន ក្នុងក្តីសុបិន្តបានយ៉ាងងាយស្រួលជាមួយឥណទានគេហដ្ឋានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។

**លក្ខណៈពិសេសរបស់ឥណទានគេហដ្ឋានះ**

- ទំហំកម្ចីរហូតដល់ ១៥០,០០០ដុល្លារអាមេរិក
- រយៈពេលកម្ចីរហូតដល់ ១៥ឆ្នាំ
- រូបិយប័ណ្ណជាប្រាក់ដុល្លារអាមេរិក។

**អត្ថប្រយោជន៍របស់ឥណទានគេហដ្ឋានះ**

- អត្រាការប្រាក់មានភាពប្រកួតប្រជែង
- ទម្រង់បែបបទងាយស្រួល
- ទទួលយកទាំងប្លង់ទន់ និងប្លង់រឹង។

**២.៥.១.៨.ឥណទានគ្មានទ្រព្យធានា**

ឥណទានគ្មានទ្រព្យធានារបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្តល់ជូនអតិថិជនគ្រប់កម្រិតទាំងនៅតំបន់ទីក្រុងនិងជនបទដែលមានប្រាក់ចំណូលជាប្រាក់បៀរវត្សរ៍។

**លក្ខណៈពិសេសះ**

- ប្រភេទរូបិយប័ណ្ណមានដូចជា ប្រាក់រៀល ប្រាក់បាតថៃ និងប្រាក់ដុល្លារអាមេរិក
- ទំហំឥណទានរហូតដល់ ៣០,០០០ដុល្លារអាមេរិក
- រយៈពេលឥណទានរហូតដល់២៤ខែ
- របៀបនៃការសងត្រលប់មានភាពបត់បែន
- មានទីលំនៅអចិន្ត្រៃយ៍
- មានអាជីវកម្ម ឬមុខរបរច្បាស់លាស់ និងស្របច្បាប់
- អាយុចាប់ពី ២៥ ដល់ ៦០ឆ្នាំ

**២.៥.១.៩.ឥណទានយានយន្ត**

ឥណទានយានយន្ត ត្រូវបានបង្កើតឡើងសម្រាប់បុគ្គលិកដែលមានចំណូលជាប្រាក់បៀរវត្សរ៍ និងអតិថិជនដែលមានអាជីវកម្មផ្ទាល់ខ្លួន ដែលមានបំណងចង់ទិញរថយន្តថ្មី ឬរថយន្តប្រើប្រាស់មួយតឹក។ ឥណទានយានយន្តនឹងជួយឱ្យរថយន្តក្នុងក្តីស្រមៃលោកអ្នក ក្លាយជាការពិត។

**លក្ខណៈពិសេសៈ**

- ប្រភេទរូបិយប័ណ្ណមានដូចជា ប្រាក់រៀល ប្រាក់បាតថៃ និងប្រាក់ដុល្លារអាមេរិក
- ទំហំឥណទានរហូតដល់ ១០០,០០០ ដុល្លារអាមេរិក
- រយៈពេលឥណទាន ៥ ឆ្នាំសម្រាប់រថយន្តប្រើប្រាស់មួយតឹក និងរហូតដល់ ៨ ឆ្នាំសម្រាប់រថយន្តថ្មី
- របៀបនៃការសងត្រលប់មានភាពបត់បែន
- មានទីលំនៅអចិន្ត្រៃយ៍
- មានអាជីវកម្ម ឬ មុខរបរច្បាស់លាស់ និង ស្របច្បាប់
- អាយុចាប់ពី ២៥ ដល់ ៧០ ឆ្នាំ
- ប័ណ្ណសម្គាល់យានយន្ត ត្រូវដាក់ជាទ្រព្យធានា។

**២.៥.២.ផលិតផលបញ្ញើសន្សំ**

ការសន្សំប្រាក់ដោយទុកក្នុងកូនជ្រូក បំពង់ឬស្សី ក្រោមពូក និងខ្នើយអាចនឹងមានហានិភ័យ និងបាត់បង់ឱកាសក្នុងការរកចំណូល។ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានធ្វើការបង្កើតប្រភេទផលិតផលសន្សំប្លែកៗពីគ្នាជាច្រើន ដើម្បីជួយអតិថិជនក្នុងការគ្រប់គ្រងប្រាក់ឱ្យមានប្រសិទ្ធិភាព។ អតិថិជន ដែលមានបំណងចង់ធ្វើការសន្សំប្រាក់អាចសន្សំជា លុយរៀលខ្មែរ លុយដុល្លារអាមេរិក និងលុយបាតថៃ។ ផលិតផលបញ្ញើរសន្សំ ដែលធនាគារផ្តល់ជូនរួមមានៈ

**២.៥.២.១.គណនីបញ្ញើសំចៃ**

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្តល់ភាពងាយស្រួលដល់អ្នកដែលមានមូលធនលើស ឬ មូលធនទំនេរ ហើយមានបំណងចង់បង្កើនទ្រព្យសកម្មផ្ទាល់ខ្លួនដោយការវិនិយោគទទួល បាននូវហានិភ័យកំរិតទាបជាមួយធនាគារដែលមានសុវត្ថិភាព។ អតិថិជនទាំងឡាយណាដែលមានបំណងចង់រកប្រាក់ចំណូលកាន់តែច្រើនអាចបើកគណនីសន្សំ ជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ជារូបិយប័ណ្ណក្នុង និង ក្រៅស្រុកអាស្រ័យលើប្រភពមូលនិធិរបស់ពួកគាត់។ ចំនួនអប្បបរមា ១០ ដុល្លារអាមេរិកគឺត្រូវបានទាមទារសម្រាប់ការដាក់ប្រាក់ដំបូង ហើយអត្រាការប្រាក់គឺទៅតាមរូបិយប័ណ្ណដែលបានជ្រើស។

**២.៥.២.២.គណនីសន្សំ វីអាយភី**

គណនីនេះត្រូវបានបង្កើតឡើង ដើម្បីបំពេញតម្រូវការអតិថិជនពិសេសៗរបស់ខ្លួន ដែលមានកម្រិតជីវភាពធូធារ។ អតិថិជនមិនត្រឹមតែទទួលបានអត្រាការប្រាក់ខ្ពស់ជាងគណនីសន្សំប៉ុណ្ណោះទេ ថែមទាំងទទួលបាននូវប័ណ្ណ សមាជិក VIP ដើម្បីទទួលបាននូវអាទិភាពនៃការបម្រើសេវាកម្ម

នៅតាមសាខាទាំងអស់ របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។ សមតុល្យអប្បបរមាចំនួន ៥០០ ដុល្លារអាមេរិក (ឬសមមូលនឹងរូបិយប័ណ្ណផ្សេង) ត្រូវបានកំណត់សម្រាប់ការបើកគណនីដំបូង។

**២.៥.២.៣.គណនីចរន្ត**

វាជាគណនីប្រតិបត្តិការដែលបង្កើតឡើង សម្រាប់ការប្រើប្រាស់ជួយគាំទ្រដល់សកម្មភាពអាជីវកម្មប្រចាំថ្ងៃរបស់អតិថិជន គណនីនេះគឺតម្រូវឱ្យអតិថិជនប្រើប្រាស់មូលប្បទានប័ត្រ។ គណនីប្រភេទនេះអាចប្រើបានសម្រាប់អតិថិជនជារូបវន្តបុគ្គល និងនីតិបុគ្គល។ ទឹកប្រាក់អប្បបរមាចំនួន ១០០ ដុល្លារអាមេរិក សម្រាប់អតិថិជនជាលក្ខណៈបុគ្គល និង ៥០០ ដុល្លារអាមេរិក សម្រាប់អតិថិជនជានីតិបុគ្គល។

**២.៥.២.៤.គណនីចរន្ត វីអាយភី**

គណនីនេះគឺជាប្រភេទគណនីដែលទទួលបាន ការប្រាក់ និងត្រូវបានបង្កើតឡើងជាពិសេសសម្រាប់គាំទ្រដល់អតិថិជនរូបវន្តបុគ្គល និងនីតិបុគ្គលដែលមានតម្រូវការទូទាត់សាច់ប្រាក់ចំនួនធំៗទៅនរណាម្នាក់ នៅក្នុងសកម្មភាពអាជីវកម្មប្រចាំថ្ងៃរបស់ពួកគាត់ តាមរយៈការចេញជាមូលប្បទានប័ត្រ។ សមតុល្យអប្បបរមាចំនួន ២,០០០ ដុល្លារអាមេរិក (ឬសមមូលនឹងរូបិយប័ណ្ណផ្សេង) ត្រូវបានកំណត់សម្រាប់ការបើកគណនីដំបូង។

**២.៥.២.៥.គណនីវីកវាយ**

គណនីវីកវាយគឺជាគណនីពិសេសម៉្យាងដែលកើតពីការរួមបញ្ចូលគ្នារវាងគណនីសន្សំ និងគណនីបញ្ញើមានកាលកំណត់។ ប្រភេទគណនីនេះ ផ្តល់នូវជម្រើសមួយផ្សេងទៀតប្រកប ដោយភាពបត់បែន សម្រាប់អ្នកដាក់ប្រាក់បញ្ញើដោយផ្អែកលើលំហូរនៃប្រាក់ចំណូលរបស់ពួកគាត់អាចជាប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ឬ ប្រចាំខែ។ អត្រាការប្រាក់ដែលទទួលបានគឺអាស្រ័យ លើការជ្រើសរើសរយៈពេលនិងប្រភេទរូបិយប័ណ្ណ។ ដើម្បីបើកគណនីនេះបាន អតិថិជនត្រូវធ្វើការសន្សំចាប់ពី ៥០ ដុល្លារអាមេរិកនៅក្នុងគណនីរបស់គាត់ ចំពោះទឹកប្រាក់អតិបរមា មិនត្រូវបានកំណត់ឡើយ។

**២.៥.២.៦.គណនីបញ្ញើមានកាលកំណត់**

ជាម្រើសមួយដ៏ល្អបំផុតសម្រាប់អ្នកដែលមានប្រាក់ច្រើន ហើយចង់បង្កើតប្រាក់ចំណូលរបស់ពួកគាត់បន្ថែមទៀតដោយការបើកគណនី ប្រាក់បញ្ញើមានកាលកំណត់ ជាមួយធនាគារប្រៃសណីយ៍កម្ពុជា ក.អ។ ទាមទារអោយមានទឹកប្រាក់យ៉ាងតិចណាស់ ៥០ ដុល្លារអាមេរិកសម្រាប់ការដាក់ប្រាក់លើកដំបូង ហើយការដាក់ប្រាក់បញ្ញើមានកាលកំណត់នេះអាចត្រូវ បានធ្វើឡើងជារូបិយប័ណ្ណបីផ្សេងគ្នា ដូចជា ប្រាក់រៀលខ្មែរ ប្រាក់ដុល្លារអាមេរិក និងប្រាក់បាតថៃ។ អត្រាការប្រាក់អាស្រ័យលើការជ្រើសរើសរយៈពេល និងប្រភេទរូបិយប័ណ្ណ។

អ្នកប្រើប្រាស់គណនីបញ្ញើមានកាលកំណត់ជាមួយធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ តម្រូវអោយបើកគណនីសន្សំ ឬគណនីចរន្តជាមួយធនាគារ ដូច្នេះការប្រាក់ដែលទទួលបានរបស់អតិថិជនពីការដាក់សន្សំប្រភេទនេះនឹងត្រូវបានគណនាដោយស្វ័យប្រវត្តិ ទៅក្នុងគណនីចរន្តឬក៏គណនីសន្សំរបស់អ្នកដាក់ប្រាក់បញ្ញើសន្សំដូច ដែលបានព្រមព្រៀង។

**ចំណូលពីការប្រាក់ប្រចាំខែ៖**

ការប្រាក់រាល់ខែនឹងត្រូវបញ្ចូលទៅក្នុងគណនីចរន្តឬក៏គណនីសន្សំរបស់អតិថិជនប្រាក់បញ្ញើសន្សំដោយយោងតាមគោលការណ៍របស់ធនាគារ។

**ចំណូលពីការប្រាក់ចុងវគ្គ៖**

ដល់ពេលកំណត់នៃរយៈពេលបញ្ញើ សន្សំ ការប្រាក់នឹងត្រូវបញ្ចូលទៅក្នុងគណនីចរន្តឬក៏គណនីសន្សំរបស់អតិថិជនប្រាក់បញ្ញើសន្សំតាមគោលការណ៍ និងការព្រមព្រៀងរវាងធនាគារ និងអតិថិជន។ ជាធម្មតា អត្រាការប្រាក់នៃគណនីប្រភេទនេះ គឺខ្ពស់ជាងប្រភេទ ចំណូលការប្រាក់ប្រចាំខែបន្តិច។

**២.៥.២.៧.គណនីសន្សំ/ចរន្តបានការប្រាក់ខ្ពស់**

ជាប្រភេទគណនី ដែលជួយឱ្យអតិថិជនទទួលបានការប្រាក់កាន់តែច្រើន ទៅតាមទំហំសមតុល្យ សាច់ប្រាក់ដែលរក្សាទុកក្នុងគណនី។ អត្រាការប្រាក់ត្រូវបានកំណត់តាមថ្នាក់នីមួយៗផ្អែកតាមទំហំប្រាក់សន្សំដែលអតិថិជនបានដាក់ក្នុងគណនី ហើយការប្រាក់ត្រូវបានគិតបង្គរជារៀងរាល់ថ្ងៃដោយគណនាទៅលើសមតុល្យប្រាក់សន្សំសរុបនៅក្នុងគណនីប្រចាំថ្ងៃនីមួយៗ ហើយការប្រាក់នេះនឹងកត់ត្រាចូលទៅក្នុងគណនីរបស់អតិថិជននៅរៀងរាល់ដំណាច់ខែនីមួយៗ។ សមតុល្យអប្បបរមាចំនួន ១,០០០ ដុល្លារអាមេរិក (ឬសមមូលនឹងរូបិយប័ណ្ណផ្សេង) ត្រូវបានកំណត់សម្រាប់ការបើកគណនីដំបូង។

**២.៥.២.៨.គណនី Trust សម្រាប់អចលនទ្រព្យ**

ជាប្រភេទគណនី ដែលបានអភិវឌ្ឍឡើងដោយឡែក ដើម្បីផ្តល់ទំនុកចិត្តដល់អ្នកលក់អចលនទ្រព្យក្នុងការទទួលបាននូវការទូទាត់ពេញលេញ ក៏ដូចជាការពារអ្នកទិញមិនឲ្យបាត់បង់សាច់ប្រាក់ក្នុងករណីមិនទទួលបានអចលនទ្រព្យតាមការសន្យា។ គណនីនេះជួយលើកកម្ពស់ក្នុងការទុកចិត្តគ្នាទៅវិញទៅមករវាងអ្នកលក់និងអ្នកទិញ។

**២.៥.៣.សេវាផ្សេងៗ**

ក្រៅពីផលិតផលឥណទាននិងផលិតផលបញ្ញើសន្សំ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អក៏មានផ្តល់ជាសេវាហិរញ្ញវត្ថុជាច្រើនទៀត ដើម្បីបំពេញសេចក្តីត្រូវការរបស់អតិថិជនក្នុងនោះរួមមាន៖

**២.៥.៣.១.សេវាផ្ទេរប្រាក់**

ដើម្បីផ្តល់ជូននូវសេវាល្អឥតខ្ចោះដល់អតិថិជន ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានធ្វើការអភិវឌ្ឍនូវសេវាផ្ទេរប្រាក់ដែលមានភាពសាមញ្ញ ងាយស្រួល សុវត្ថិភាព និងមានទំនុកចិត្តជូនដល់អតិថិជន។

**អត្ថប្រយោជន៍៖**

- មានសុវត្ថិភាព សេវារហ័ស ចំណាយតិច និងចំណេញពេលវេលា
- សេវាកម្មល្អ តម្លៃសមរម្យ និងមានតម្លាភាព
- មានបណ្តាញសាខាធំទូលាយដែលផ្តល់ភាពងាយស្រួលក្នុងការផ្ញើ ឬទទួលប្រាក់
- ដំណើរការមិនស្មុគស្មាញ និងប្រើរយៈពេលខ្លី។

**អតិថិជនអាចផ្ទេរប្រាក់៖**

- ពីគណនីទៅគណនី
- ពីគ្មានគណនីទៅគណនី
- ពីគណនីទៅគ្មានគណនី
- ពីគ្មានគណនីទៅគ្មានគណនី
- ពីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ទៅធនាគារផ្សេងទៀត
- ពីប្រទេសកម្ពុជា ទៅប្រទេសផ្សេងទៀតជុំវិញពិភពលោក។

**២.៥.៣.២.សេវាទូទាត់រហ័ស**

សេវាទូទាត់រហ័សជាសេវាថ្មីមួយដែលអតិថិជន អាចធ្វើប្រតិបត្តិការហិរញ្ញវត្ថុរវាងធនាគារមានដូចជា៖ ប្រតិបត្តិការផ្ទេរប្រាក់ ទូទាត់សងប្រាក់ និងទទួលប្រាក់បានភ្លាមជាប្រាក់រៀលខ្មែរ។ មិនតែប៉ុណ្ណោះ សេវាទូទាត់រហ័សនេះក៏បានជួយជំរុញក្នុងការប្រើប្រាស់ប្រាក់រៀល បង្កើនតម្លាភាពតាមរយៈការទូទាត់ជាអេឡិចត្រូនិក កាត់បន្ថយចរាចរសាច់ប្រាក់នៅលើទីផ្សារ បង្កើនប្រសិទ្ធិភាពក្នុងការប្រើប្រាស់ធនធានហិរញ្ញវត្ថុ និងជាពិសេសលើកកម្ពស់បរិយាប័ន្នហិរញ្ញវត្ថុ និងចូលរួមអភិវឌ្ឍសេដ្ឋកិច្ចតាមរយៈការធ្វើទំនើបកម្មប្រព័ន្ធទូទាត់នៅប្រទេសកម្ពុជាឲ្យកាន់តែប្រសើរឡើង។

**២.៥.៣.៣.សេវាផ្ទេរប្រាក់ក្នុងប្រទេស**

លោកអ្នកមិនមានបញ្ហា ឬក្តីបារម្ភក្នុងការផ្ញើរប្រាក់ទៅកាន់សមាជិកគ្រួសារ សាច់ញាតិ ឬដៃគូអាជីវកម្ម មិនថានៅទីក្រុង ជនបទ ឬតំបន់ដាច់ស្រយាលនោះទេ ព្រោះសេវាផ្ទេរប្រាក់ក្នុងប្រទេសរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្តល់នូវដំណោះស្រាយ ដែលឆ្លើយតបទៅនឹងបញ្ហាទាំងអស់នេះ។ វត្តមានរបស់បណ្តាញសាខាធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ តែងតែនៅជិតលោកអ្នក

មិនត្រឹមតែតំបន់ដែលអតិថិជនរស់នៅ តែក៏ជាកន្លែងដែលពួកគាត់ប្រកបអាជីវកម្មផងដែរ ដើម្បីឱ្យប្រាកដថាអតិថិជន នឹងមិនមានបញ្ហាក្នុងការប្រើប្រាស់សេវាផ្ទេរប្រាក់នេះ។ លោកអ្នកអាចប្រើប្រាស់សេវាផ្ទេរប្រាក់ក្នុងប្រទេសបាន ដោយគ្រាន់តែមកកាន់សាខារបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ណាមួយដែលនៅជិតលោកអ្នក ឬ តាមរយៈសេវាធនាគារចល័ត។

**២.៥.៣.៤.សេវាផ្ទេរប្រាក់ក្រៅប្រទេស**

អតិថិជន អាចផ្ទេរប្រាក់ក្រៅប្រទេសជុំវិញពិភពលោកជាមួយនឹងសេវាផ្ទេរប្រាក់ក្រៅប្រទេសរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ តាមរយៈលេខកូដ SWIFT “**CPBKHP2**” ។ អត្ថប្រយោជន៍អតិថិជនទទួលបានមានដូចជា ថ្លៃសេវាទាប រហ័ស មានភាពងាយស្រួល និងសុវត្ថិភាពខ្ពស់។

**២.៥.៣.៥. សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិក**

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានប្រើប្រាស់នូវសេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិកដើម្បីសម្រួលដល់ការប្រើប្រាស់សេវាធនាគារឲ្យកាន់តែមានភាពងាយស្រួល។ អតិថិជនអាចប្រើប្រាស់សេវាបាន២៤ម៉ោងក្នុង១ថ្ងៃ ៧ថ្ងៃក្នុងមួយសប្តាហ៍ បានគ្រប់ពេលវេលា និងគ្រប់ទីកន្លែង។ សេវាធនាគារតាមប្រព័ន្ធអេឡិចត្រូនិកមានដូចជា៖

**ក.សេវាធនាគារចល័ត**

ដោយយល់ឃើញថា ចំនួនអ្នកដែលប្រើប្រាស់ទូរស័ព្ទដៃមានការកើនឡើងគួរឱ្យកត់សំគាល់ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានអភិវឌ្ឍនូវសេវាធនាគារចល័តដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជន។ សេវានេះអាចប្រើប្រាស់បានជាមួយទូរស័ព្ទដែលមានប្រព័ន្ធប្រតិបត្តិការ iOS, Android, Window ឬ ទូរស័ព្ទធម្មតា។ ធនាគារ ប្រៃសណីយ៍ កម្ពុជា ក.អ ផ្តល់នូវដំណោះស្រាយសេវាធនាគារចល័ត យុទ្ធសាស្ត្រគ្រប់គ្រងទីផ្សារ និងការគាំទ្រផ្សេងៗដល់អតិថិជន ក៏ដូចជាការគ្រប់គ្រងប្រតិបត្តិការសាច់ប្រាក់តាមរយៈគោលនយោបាយនិងគោលការណ៍ផ្ទៃក្នុងរបស់ធនាគារ។

តាមរយៈសេវាធនាគារចល័តលោកអ្នកអាច៖

- ពិនិត្យមើលសមតុល្យក្នុងគណនី
- ពិនិត្យមើលប្រវត្តិប្រតិបត្តិការ
- ការផ្ទេរប្រាក់រវាងគណនីក្នុងធនាគារ
- ផ្ទេរប្រាក់ទៅធនាគារផ្សេងៗ
- ទូទាត់វិក្កយបត្រ
- បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ
- ទទួលសារជូនដំណឹង

- ការផ្សព្វផ្សាយ
- ស្វែងរកទីតាំងសាខា
- ស្វែងរកទីតាំងម៉ាស៊ីនអេធីអឹម
- សេវាប្តូរប្រាក់
- អត្រាការប្រាក់
- សាកសួរព័ត៌មានផ្សេងៗ។

**ខ.សេវាអេ ធី អឹម (ATM)**

ម៉ាស៊ីនអេធីអឹមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ត្រូវបានបំពាក់នូវបច្ចេកវិទ្យាទំនើប និងទាន់សម័យ ដែលផ្តល់ភាពងាយស្រួលដល់អតិថិជនក្នុងការធ្វើប្រតិបត្តិការហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុបានយ៉ាងងាយស្រួលនិងមានសុវត្ថិភាពខ្ពស់។ ភាពងាយស្រួល និងសុវត្ថិភាពសម្រាប់អតិថិជនគឺជាកត្តាដ៏ចាំបាច់ដែលធនាគារត្រូវតែផ្តោតការយកចិត្តទុកដាក់ ដើម្បីធានាបានថារាល់ប្រតិបត្តិការរបស់អតិថិជនទាំងអស់របស់ធនាគារត្រូវបានការពារ។

តាមរយៈសេវាអេ ធី អឹម លោកអ្នកអាចៈ

- ពិនិត្យមើលសមតុល្យក្នុងគណនី
- ពិនិត្យមើលរបាយការណ៍សង្ខេប
- ដកប្រាក់
- ផ្ទេរប្រាក់រវាងគណនីក្នុងធនាគារ
- ផ្ញើប្រាក់ ទៅធនាគារផ្សេងៗ
- ទូទាត់វិក្កយបត្រ
- បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ
- ទទួលសារជូនដំណឹង។

# ជំពូកទី៣

# ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក

## ៣.១.គោលបំណងនៃផលិតផលឥណទានខ្នាតមធ្យម

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានបង្កើតនូវឥណទានខ្នាតមធ្យម ដើម្បីលើកកម្ពស់ជីវភាពប្រជាជនកម្ពុជា តាមរយៈការផ្តល់នូវទុនសម្រាប់បង្កើតនូវអាជីវកម្ម ក្នុងគោលបំណងចូលរួមក្នុងសកម្មភាពកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។ម្យ៉ាងវិញទៀត គឺដើម្បីចូលរួមចំណែកអភិវឌ្ឍន៍ និងជំរុញឱ្យមាននិរន្តភាពអាជីវកម្មពេលមានតម្រូវការហិរញ្ញវត្ថុ ជាពិសេសទ្រទ្រង់ដល់ការអភិវឌ្ឍន៍ សេដ្ឋកិច្ច សង្គមកិច្ច តាមរយៈការប្រមូលមូលធន និងដាក់ឱ្យចរាចរក្នុងផ្នែកផលិតកម្ម ដើម្បីស្រូបយកផលប្រយោជន៍ពីប្រភពធនធានដែលមានក្នុងប្រទេសដើម្បីបង្កើតការងារ និងបង្កើនប្រាក់ចំណូល។

## ៣.២.លក្ខណៈទូទៅរបស់ឥណទានខ្នាតមធ្យម

### ៣.២.១.និយមន័យ

ឥណទានខ្នាតមធ្យម គឺជាកម្រិតបន្ទាត់ឥណទានមួយដែលមានរយៈពេលពី ៦ខែ ទៅដល់ ៥ឆ្នាំ សម្រាប់ផ្តល់ជូនអតិថិជន ក្នុងគោលបំណងអាជីវកម្ម ដើម្បីឱ្យអតិថិជនមានមូលធនចម្បងសម្រាប់វិនិយោគក្នុងការទិញ ឬការជួសជុសកែលម្អអចលនវត្ថុ មានទុនគ្រប់គ្រាន់សម្រាប់បង្វិលនៅពេលដែលត្រូវការសាច់ប្រាក់បន្ទាន់ក្នុងគ្រាណាមួយ និងបម្រើឱ្យវិស័យផលិតកម្ម សេវាកម្ម ទេសចរណ៍ នេសាទ ការដាំដុះ ការចិញ្ចឹមសត្វ និងការវិនិយោគផ្សេងៗ។

### ៣.២.២.អតិថិជនគោលដៅ

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានកំណត់អតិថិជនគោលដៅដូចខាងក្រោម៖

- រូបវន្តបុគ្គល៖ សម្តៅដល់អ្នកខ្ចីជាគ្រួសារ ឬឯកត្តជនដែលខ្ចីប្រាក់ពីធនាគារ សម្រាប់សកម្មភាពអាជីវកម្មផ្ទាល់ខ្លួនដែលមានលក្ខណៈជារូបវន្តបុគ្គល។
- នីតិបុគ្គល៖ សម្តៅដល់ស្ថាប័ន សហគ្រាសដែលបង្កើតឡើងដោយច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះរួមមាន៖
  - សហគ្រាស ឬក្រុមហ៊ុនឯកកម្មសិទ្ធិ៖ ជាសហគ្រាស ឬក្រុមហ៊ុនដែលបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទស្របច្បាប់ ធ្វើប្រតិបត្តិការដោយបុគ្គលម្នាក់ជាម្ចាស់មូលធនរបស់ខ្លួន ហើយទទួលខុសត្រូវគ្មានកំរិត។

- សហគ្រាស ឬក្រុមហ៊ុនសហកម្មសិទ្ធិ៖ ជាសហគ្រាស ឬក្រុមហ៊ុនដែលបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់ស្របច្បាប់ជានីតិបុគ្គល ហើយទទួលខុសត្រូវពីរនាក់ ឬច្រើននាក់។
- សហគ្រាស ឬក្រុមហ៊ុនសាជីវកម្ម៖ ជាសហគ្រាស ឬក្រុមហ៊ុនសាជីវកម្មដែលបានបង្កើតឡើង និងចុះបញ្ជីពាណិជ្ជកម្មតាមទម្រង់បែបបទស្របច្បាប់ និងត្រូវបានផ្តល់សិទ្ធិតាមផ្លូវច្បាប់ជានីតិបុគ្គល ដោយឡែកពីសិទ្ធិរបស់ម្ចាស់ភាគហ៊ុន។ សហគ្រាស ឬក្រុមហ៊ុនសាជីវកម្មមានវិនិយោគច្រើនចូលរួមវិនិយោគ និងជាម្ចាស់ភាគហ៊ុនកាន់កាប់ចំណែកភាគហ៊ុនរបស់ខ្លួនដែលបានវិនិយោគ។

## ៣.៣.គោលការណ៍នៃការផ្តល់ឥណទានខ្នាតមធ្យម

### ៣.៣.១.លក្ខណៈសម្បត្តិដែលអាចទទួលឥណទាន

សម្រាប់លក្ខណៈសម្បត្តិដែលអាចទទួលបានឥណទានពីធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ គឺជាអតិថិជនដែលមានលក្ខណៈសម្បត្តិដូចខាងក្រោម៖

- រូបវន្តបុគ្គល៖
  - អតិថិជនត្រូវមានប្រវត្តិរូបល្អនិងគ្មានជាប់ពាក់ព័ន្ធជាមួយនឹងបទល្មើសផ្សេងៗ ឬមិនស្ថិតនៅក្នុងបញ្ជីនៃអតិថិជនដែលសងបំណុលយឺតយ៉ាវរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ
  - មានទីលំនៅអចិន្ត្រៃយ៍
  - មានសុខភាពល្អ ទាំងផ្លូវកាយ និងផ្លូវចិត្ត
  - ចរិតស្មោះត្រង់ និងការតាំងចិត្តផ្ទាល់ខ្លួនខ្លាំងក្លាក្នុងការសងបំណុល
  - មុខរបរស្របច្បាប់ និងជាអចិន្ត្រៃយ៍
  - ប្រវត្តិរូបនៃការបំពេញការងារបានល្អ ប្រសិនបើអ្នកខ្ចីជាបុគ្គលក្នុងក្រុមហ៊ុនផ្សេងៗ
  - បទពិសោធន៍យូរក្នុងអាជីវកម្ម
  - មានលទ្ធភាពសងបំណុលទាំងប្រាក់ដើម និងការប្រាក់
  - សមត្ថភាពក្នុងការគ្រប់គ្រងហិរញ្ញវត្ថុរបស់ខ្លួនឱ្យបានត្រឹមត្រូវ
  - មានទ្រព្យសម្បត្តិធានាលើប្រាក់កម្ចី
  - មានដី ផ្ទះ អគារ ឬអ្វីផ្សេងទៀតដែលអាចជំនួសបាន

- ប្រជាជនកម្ពុជាគ្រប់រូបដែលជាពលរដ្ឋសកម្ម ឬជានីតិជន (បុគ្គលដែលមានសិទ្ធិប្រកបការងារតាមផ្លូវច្បាប់ ចាប់ពីអាយុ ១៨ឆ្នាំឡើងទៅ) ដែលមានលក្ខណៈសមស្របតាមបណ្តាចំណុចដូចបានរៀបរាប់ខាងលើ។

➢ នីតិបុគ្គលៈ

- ក្រុមហ៊ុនត្រូវមានការចុះបញ្ជីត្រឹមត្រូវនៅក្រសួងពាណិជ្ជកម្ម និងត្រូវស្របតាមច្បាប់នៃប្រទេសកម្ពុជា
- ក្រដាសចុះបញ្ជីកាន់កាប់ទ្រព្យសម្បត្តិត្រឹមត្រូវ
- លក្ខន្តិកៈនៃអាជីវកម្មត្រឹមត្រូវ
- ការិយាល័យដែលមានអាសយដ្ឋានត្រឹមត្រូវ និងច្បាស់លាស់
- ការគ្រប់គ្រងហិរញ្ញវត្ថុខ្លាំង
- ប្រវត្តិនៃដំណើរការអាជីវកម្មជោគជ័យនៅពេលថ្មីៗ
- ការគ្រប់គ្រងប្រកបដោយវិជ្ជាជីវៈ និងជោគជ័យ
- បទពិសោធន៍យូរក្នុងការដំណើរការអាជីវកម្មរបស់ខ្លួន
- ទ្រព្យសកម្មវិជ្ជមាន
- មិនត្រូវមានជាប់ពាក់ព័ន្ធ នឹងបទល្មើសណាមួយឡើយ ឬពាក់ព័ន្ធនឹងការសងឥណទានមិនតាមពេលកំណត់របស់ធនាគារ
- មានទ្រព្យសម្បត្តិ ឬវត្ថុសម្រាប់ដាក់បញ្ចាំនៅធនាគារ។

### ៣.៣.២.លក្ខណៈសម្បត្តិដែលមិនអាចទទួលបានឥណទាន

ធនាគារ ប្រែសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក មិនផ្តល់ឥណទានដល់អតិថិជនទាំងឡាយណាដែលជាអនីតិជន ឬជនពិការមានដូចជាៈ

- ជនដែលមិនមានសិទ្ធិក្នុងការប្រកបការងារស្របតាមច្បាប់កំណត់
- ជនដែលមានអាយុក្រោម ១៨ឆ្នាំ
- ជនពិការសតិ
- ជនញៀនគ្រឿងស្រវឹង និងគ្រឿងញៀន។

មុខរបរជំនួញទាំងឡាយណា ដែលស្ថិតក្រោមការហាមឃាត់នៃច្បាប់ព្រះរាជាណាចក្រកម្ពុជាត្រូវជៀសវាងក្នុងការផ្តល់ឥណទាន។ មុខរបរទាំងនោះរួមមានៈ

- សំណាញ់រសាត់សម្រាប់ចាប់ត្រីក្នុងទឹក ដោយប្រើសំណាញ់មានប្រវែងលើសពី ២.៥ គីឡូម៉ែត្រ

- មុខរបរចិញ្ចឹមត្រីចាប និងប្រភេទត្រីដែលស៊ីសាច់ជាអាហារ
- ការចិញ្ចឹមត្រីឆ្តោ ត្រូវបានហាមឃាត់ដោយក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទ
- ផលិតកម្ម ឬជំនួញ ជួញដូរអាវុធជាតិផ្ទុះ ឬសកម្មភាពផលិតគ្រាប់រំសេវដែលចាត់ទុកជាអំពើខុសច្បាប់
- ផលិតកម្ម ឬសកម្មភាពជំនួញទាំងឡាយណាដែលប្រើប្រាស់កម្លាំងដោយបង្ខំ ឬប្រើពលកម្មកុមារ
- សកម្មភាពអាជីវកម្មដែលពាក់ព័ន្ធនឹងល្បែងស៊ីសង ពេស្យាចារ ការនេសាទខុសច្បាប់ និងការកាប់បំផ្លាញព្រៃឈើខុសច្បាប់។

### ៣.៣.៣.លក្ខណៈសម្បត្តិរបស់អ្នកធានា

ប្រសិនបើអតិថិជនគ្មានទ្រព្យដាក់បញ្ចាំ អ្នកធានាត្រូវដាក់ទ្រព្យសម្បត្តិរបស់ខ្លួនបញ្ចាំជំនួសអតិថិជននោះ។ អ្នកធានានឹងទទួលខុសត្រូវផងដែរលើការសងត្រលប់នៃឥណទាន។ ដូច្នេះហើយទើបធនាគារតម្រូវឱ្យអ្នកធានាត្រូវមានលក្ខណៈសម្បត្តិ និងគោរពនូវលក្ខខណ្ឌដូចខាងក្រោម៖

- ជានីតិជនដែលមានអាយុចាប់ពី ១៨ឆ្នាំ ដល់ ៦០ឆ្នាំ និងមានសុខភាពល្អ
- ជាមនុស្សល្អ មានមុខរបរសមរម្យ ពិតប្រាកដ និងស្របច្បាប់
- មានលទ្ធភាពប្រហាក់ប្រហែល ឬលើសអ្នកខ្ចី
- មានលទ្ធភាពគ្រប់គ្រាន់ និងយល់ព្រមសងជំនួសអ្នកខ្ចី នៅពេលអ្នកខ្ចីគ្មានលទ្ធភាពសងប្រាក់តាមកិច្ចសន្យា និងតារាងសាច់ប្រាក់ ឬមានបំណងមិនចង់សងប្រាក់
- ដាក់ទ្រព្យធានាបន្ថែម (បើតម្លៃទ្រព្យដែលបានដាក់ធានាកម្ចីកំពុងជំពាក់ មិនគ្រប់គ្រាន់សម្រាប់ធានាកម្ចី)
- មានអាសយដ្ឋានជាអចិន្ត្រៃយ៍នៅក្នុងតំបន់ប្រតិបត្តិការរបស់ធនាគារ។

### ៣.៣.៤.ប្រភេទរូបិយប័ណ្ណ ទំហំឥណទាន រយៈពេលខ្ចី អត្រាការប្រាក់ និងសោហ៊ុយឥណទាន

➢ **ប្រភេទរូបិយប័ណ្ណ**

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានផ្តល់ឥណទានដល់អតិថិជនជាប្រភេទរូបិយប័ណ្ណដូចជា ប្រាក់រៀលខ្មែរ ប្រាក់បាតថៃ និងប្រាក់ដុល្លារអាមេរិក ទៅតាមតម្រូវការជាក់ស្តែងរបស់អតិថិជន និងតំបន់ប្រតិបត្តិការដែលបានកំណត់។

**តារាងទី ៣.១ ៖ តារាងរូបិយប័ណ្ណ និងតំបន់ប្រតិបត្តិការដែលបានអនុញ្ញាតបញ្ចេញឥណទានតាមសាខា**

| ប្រភេទរូបិយប័ណ្ណ | តំបន់ប្រតិបត្តិការ |
|---|---|
| ប្រាក់រៀលខ្មែរ | ទូទាំងប្រទេស |
| ប្រាក់បាតថៃ | អនុញ្ញាតតែខេត្តបាត់ដំបង សៀមរាប បន្ទាយមានជ័យ ពោធិសាត់ ឧត្តរមានជ័យ ព្រះវិហារ កោះកុង និងប៉ៃលិន |
| ប្រាក់ដុល្លារអាមេរិក | ទូទាំងប្រទេស |

- **ទំហំឥណទាន**

**តារាងទី ៣.២ ៖ តារាងទំហំឥណទានសម្រាប់ប្រភេទរូបិយប័ណ្ណនីមួយៗ**

| ប្រភេទរូបិយប័ណ្ណ | ទំហំអប្បបរមា | ទំហំអតិបរមា |
|---|---|---|
| ប្រាក់រៀលខ្មែរ | ២០០,០០០,០០០ | ១,០០០,០០០,០០០ |
| ប្រាក់បាតថៃ | ២,០០០,០០០ | ១០,០០០,០០០ |
| ប្រាក់ដុល្លារអាមេរិក | ៥០,០០០ | ២៥០,០០០ |

- **រយៈពេលខ្ចី**

រយៈពេលខ្ចីនៃឥណទានខ្នាតមធ្យមដែលធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ បានផ្តល់ដល់អតិថិជន គឺចាប់ពី ៦ខែ ដល់ ៥ឆ្នាំ។

- **អត្រាការប្រាក់**

**តារាងទី ៣.៣ ៖ តារាងអត្រាការប្រាក់**

| **ទំហំទឹកប្រាក់ ($)** | **ប្តូង់ទន់** | | | **ប្លង់រឹង** | | |
|---|---|---|---|---|---|---|
| | **ពី ៦ខែ ដល់ ២ឆ្នាំ** | **ពី ២ឆ្នាំ ដល់ ៤ឆ្នាំ** | **ពី ៤ឆ្នាំ ដល់ ៥ឆ្នាំ** | **ពី ៦ខែ ដល់ ២ឆ្នាំ** | **ពី ២ឆ្នាំ ដល់ ៤ឆ្នាំ** | **ពី ៤ឆ្នាំ ដល់ ៥ឆ្នាំ** |
| ៥០០០០-១០០០០០ | ១.១០% | ១.១៥% | ១.២០% | ១.០០% | ១.០៥% | ១.១០% |
| ១០០០០១-២៥០០០០ | ១.០៥% | ១.១០% | ១.១៥% | ១.០០% | ១.០៥% | ១.១០% |
| **សម្គាល់៖ USD1 = 40THB និង USD1 = 4000KHR** | | | | | | |

- **សោហ៊ុយឥណទាន**

សោហ៊ុយចំណាយឥណទានរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ គឺដូចខាងក្រោម៖

- ២% សម្រាប់ឥណទានដែលមានទំហំធំជាង ១,០០០ ដល់ ៥,០០០ដុល្លារអាមេរិក
- ១.៥% សម្រាប់ឥណទានដែលមានទំហំធំជាង ៥,០០០ ដល់ ១០,០០០ដុល្លារអាមេរិក
- ១% សម្រាប់ឥណទានដែលមានទំហំចាប់ពី ១០,០០០ដុល្លារអាមេរិក ឡើងទៅ
- ករណីពិសេស នាយក នាយិកាសាខាមានសិទ្ធិបញ្ចុះសោហ៊ុយចំណាយឥណទាន តែមិនត្រូវទាបជាង ១%។

### ៣.៣.៥.ការកំណត់ទំហំឥណទាន

ទំហំឥណទានត្រូវបានកំណត់ដោយផ្អែកលើកត្តា៖

- លទ្ធភាពក្នុងការសង៖ មិនត្រូវលើសពីសមត្ថភាពរបស់អតិថិជន ដែលត្រូវសងក្នុងមួយខែៗ ឡើយ។ មិនត្រូវធំជាង ៦០%នៃប្រាក់ចំណោញក្នុងមុខរបរ និង មិនត្រូវលើសពី ៨៥% នៃប្រាក់បៀវត្ស។
- ទ្រព្យដាក់ធានា៖ ជាទ្រព្យទាំងឡាយណា ដែលអាចធ្វើការធានាលើប្រាក់កម្ចីបាន។
- រយៈពេលនៃការខ្ចី៖ រយៈពេលវែង ឬខ្លី ដើម្បីប្រើប្រាស់ជាដើមទុន និងការរកចំណូល។

### ៣.៣.៦.ឯកសារឥណទាន ការទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន

#### ៣.៣.៦.១.ឯកសារឥណទាន

- ការរៀបចំឯកសារមុនពេលអនុម័តឥណទាន
  - ទម្រង់ពាក្យស្នើសុំខ្ចីឥណទាន
  - ទម្រង់ផែនការអាជីវកម្ម
  - របាយការណ៍វាយតម្លៃទ្រព្យដាក់បញ្ចាំ
  - រូបថតអតិថិជន
  - ឯកសារកំណត់អត្តសញ្ញាណ
  - ឯកសារកំណត់អាសយដ្ឋាន
  - ឯកសារកំណត់ប្រាក់ចំណូល
  - រូបថតនៃសកម្មភាពអាជីវកម្ម
  - វិក្កយបត្រដែលជាភស្តុតាងសកម្មភាពអាជីវកម្ម - វិក្កយបត្រខែចុងក្រោយ។
- ការរៀបចំឯកសារក្រោយពេលអនុម័តឥណទាន និងមុនពេលបញ្ចេញឥណទាន
  - កិច្ចសន្យាខ្ចីប្រាក់

- កិច្ចសន្យាដាក់បញ្ចាំ
- ហត្ថលេខាលើតារាងកាលវិភាគសងប្រាក់
- វិក្កយបត្រសាច់ប្រាក់សម្រាប់សោហ៊ុយឥណទាន និងសោហ៊ុយផ្សេងៗ (ដកចេញពីទឹកប្រាក់ខ្ចីដោយស្វ័យប្រវត្តិ)
- បង្កាន់ដៃតម្កល់ទ្រព្យដាក់បញ្ចាំ។

**៣.៣.៦.២.ភារទទួលខុសត្រូវ និងសិទ្ធិអនុម័តឥណទាន**

ក្នុងឯកសារឥណទាននីមួយៗដែលត្រួតពិនិត្យ ត្រូវពិនិត្យលើសិទ្ធិអនុម័តឥណទាន ដើម្បីរកកំហុសពីការបញ្ចេញឥណទាននីមួយៗរបស់សាខា។ ការអនុម័តត្រឹមត្រូវតាមការកំណត់របស់ធនាគារបានផ្តល់សិទ្ធិឱ្យដូចខាងក្រោម៖

- អនុប្រធានឥណទានសាខា អនុម័តឥណទានដែលមានទំហំរហូតដល់ ៧,៥០០ដុល្លារអាមេរិក ឬសមមូល។
- ប្រធានឥណទានសាខា អនុម័តឥណទានដែលមានទំហំរហូតដល់ ១៥,០០០ដុល្លារអាមេរិក ឬសមមូល។
- នាយកប្រតិបត្តិឥណទាន អនុម័តឥណទានដែលមានទំហំរហូតដល់ ២៥,០០០ដុល្លារអាមេរិក ឬសមមូល។
- ប្រធាននាយកប្រតិបត្តិ អនុម័តឥណទានដែលមានទំហំរហូតដល់ ៥០,០០០ដុល្លារអាមេរិក ឬសមមូល។
- គណៈកម្មាធិការឥណទាន អនុម័តឥណទានដែលមានទំហំរហូតដល់ ១០០,០០០ ដុល្លារអាមេរិក ឬសមមូល។
- គណៈកម្មាធិការឥណទាន និង Chairman អនុម័តឥណទានដែលមានទំហំធំជាង ១០០,០០០ រហូតដល់ ២៥០,០០០ដុល្លារអាមេរិក សមមូលរូបិយប័ណ្ណផ្សេងទៀត។

## ៣.៤.នីតិវិធីក្នុងការផ្តល់ឥណទានខ្នាតមធ្យម

នីតិវិធីក្នុងការផ្តល់ឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ មាន ១៥ ដំណាក់កាលដូចខាងក្រោម៖

➢ **ដំណាក់កាលទី១៖ ការចុះឈ្មោះខ្ចីប្រាក់**

- អតិថិជនដែលដាក់ពាក្យស្នើសុំ ត្រូវភ្ជាប់មកជាមួយនូវឯកសារដូចជា៖
  - ឯកសារកំណត់អត្តសញ្ញាណនានាដូចជាអត្តសញ្ញាណប័ណ្ណ និងប័ណ្ណគ្រួសារ ឬលិខិតឆ្លងដែនប្រសិនអតិថិជនជាជនជាតិបរទេស

- លិខិតសម្គាល់ពីការងារដែលអតិថិជនធ្វើ
- ប័ណ្ណសម្គាល់លិខិតកាន់កាប់អចលនវត្ថុរបស់អតិថិជន
- លិខិតបញ្ជាក់ពីការអនុញ្ញាតឱ្យប្រកបអាជីវកម្មពីក្រសួងពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រសិនបើអតិថិជនជាប្រភេទក្រុមហ៊ុន ឬសហគ្រាស
- របាយការណ៍ហិរញ្ញវត្ថុរបស់អាជីវកម្ម ប្រសិនបើអតិថិជនជាប្រភេទក្រុមហ៊ុន ឬសហគ្រាស
- ប័ណ្ណប៉ាតង់របស់ក្រុមហ៊ុននៅឆ្នាំថ្មីៗ ប្រសិនបើអតិថិជនជាប្រភេទក្រុមហ៊ុន ឬសហគ្រាស។

- អតិថិជនក៏ប្រគល់ផងដែរនូវឯកសារនានា ដែលទាក់ទងនឹងទ្រព្យដាក់បញ្ចាំជាច្បាប់ចម្លងប៉ុណ្ណោះ។
- អតិថិជនយល់ព្រមផងដែរក្នុងការចុះហត្ថលេខា ដើម្បីផ្តល់ព័ត៌មានឥណទានតាមរយៈក្រេឌីតប្យ៉ូរ៉ូ។
- ភ្នាក់ងារឥណទានត្រូវតែពន្យល់អតិថិជនអំពីប្រកាសរបស់ធនាគារជាតិនៃកម្ពុជា ស្តីពីការចែករំលែកព័ត៌មានតាមរយៈការិយាល័យឥណទានកម្ពុជា ក្នុងគោលបំណងដើម្បីត្រួតពិនិត្យពីសមត្ថភាពរបស់អ្នកខ្ចី មុនពេលផ្តល់ឥណទាន បន្ទាប់មកពន្យល់ពីសោហ៊ុយចំណាយសម្រាប់ក្រេឌីតប្យ៉ូរ៉ូកម្ពុជាដែលជាបន្ទុករបស់អតិថិជន។
- ភ្នាក់ងារឥណទាន ត្រូវតែពន្យល់ឱ្យបានច្បាស់លាស់ដល់អតិថិជននូវរាល់លក្ខខណ្ឌដែលបានចែងក្នុងពាក្យស្នើសុំខ្ចីឥណទាន ជាពិសេស អតិថិជនត្រូវយល់ព្រមជាមួយធនាគារ ក្នុងការផ្តល់ព័ត៌មានឥណទានរបស់ខ្លួនទៅកាន់ប្រព័ន្ធការិយាល័យឥណទានកម្ពុជាតាមដែលច្បាប់បានកំណត់។

**➢ ដំណាក់កាលទី២៖ ការត្រួតពិនិត្យការផ្តល់ឥណទានជាន់គ្នាផ្ទៃក្នុង**

- ការត្រួតពិនិត្យការផ្តល់ឥណទានជាន់គ្នា ត្រូវបានធ្វើឡើងតាមរយៈប្រព័ន្ធរបស់ធនាគារប្រែសណីយ៍កម្ពុជា ក.អ ដើម្បីកត់ត្រានូវពាក្យស្នើសុំរបស់អតិថិជន និងស្វែងរកថាតើអតិថិជននោះធ្លាប់បានដាក់ពាក្យស្នើសុំឥណទានពីមុនៗមក ឬក៏ជាអតិថិជនចាស់របស់ធនាគារ ប្រែសណីយ៍កម្ពុជា ក.អ។

- **ដំណាក់កាលទី៣៖ ការត្រួតពិនិត្យតាមរយៈការិយាល័យឥណទាន**
  - របាយការណ៍ប្រព័ន្ធការិយាល័យឥណទានរបស់អតិថិជន ត្រូវបានទាញយក និងទុកជាសំណុំឯកសារ។ បើបទដ្ឋាននៃការិយាល័យឥណទានមិនត្រូវបានបំពេញទេ នោះសំណុំឯកសារនេះត្រូវបានបដិសេដក្នុងប្រព័ន្ធ។
- **ដំណាក់កាលទី៤៖ ការចុះដល់ទីកន្លែង**
  - ការចុះដល់ទីកន្លែង ត្រូវបានធ្វើឡើង ដើម្បីឱ្យដឹងច្បាស់ទៅលើទំហំអាជីវកម្មរបស់អតិថិជន។ ការសម្ភាសន៍ផ្ទាល់ជាមួយអតិថិជន ក៏ត្រូវបានធ្វើផងដែរ ដើម្បីដឹងពីមូលហេតុនៃការស្នើសុំឥណទាន និងស្ថានភាពនៃអាជីវកម្ម។
  - រាល់ព័ត៌មានបន្ថែមនានាដែលបានពីការិយាល័យឥណទាន និងឯកសារដែលបានដាក់ជូនដោយអតិថិជនក៏ត្រូវបញ្ជាក់ជាមួយពួកគាត់ផងដែរ។
  - ការវាយតម្លៃចំណូលរបស់អតិថិជនក៏ត្រូវបានទាមទារឱ្យធ្វើផងដែរ។
- **ដំណាក់កាលទី៥៖ ការត្រួតពិនិត្យឯកសារច្បាប់ដើម**
  - ប្រធានភ្នាក់ងារឥណទានទទួលខុសត្រូវក្នុងការធ្វើឱ្យប្រាកដថា រាល់ឯកសារច្បាប់ដើមពិតជាបានឃើញ ហើយត្រូវចុះហត្ថលេខាមុននឹងការវាយតម្លៃឥណទាន។
- **ដំណាក់កាលទី៦៖ ការពិភាក្សាផ្ទាល់**
  - ភ្នាក់ងារឥណទានត្រូវយកចិត្តទុកដាក់ ផ្តោតអារម្មណ៍ សាកសួរប្រមូលព័ត៌មានពីអ្នកខ្ចីដែលទាក់ទងនឹងព័ត៌មានទូទៅ ព័ត៌មានហិរញ្ញវត្ថុ តម្រូវការឥណទាន ការប្រើប្រាស់ប្រាក់កម្ចី ព័ត៌មានអំពីទ្រព្យ ព្រមទាំងកត្តាទាំងឡាយដែលអាចជះឥទ្ធិពល និងបង្កជាហានិភ័យ។
  - ក្នុងដំណាក់កាលនេះ ភ្នាក់ងារឥណទានត្រូវតែធ្វើការពន្យល់អតិថិជនឱ្យបានច្បាស់លាស់ពីគោលការណ៍ និងនីតិវិធីឥណទានដោយរាប់បញ្ចូលទាំងលក្ខខណ្ឌនៃកិច្ចសន្យាខ្ចីប្រាក់ កិច្ចសន្យាដាក់បញ្ចាំ ឬកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ឬកិច្ចសន្យាធានា។ល។
  - ភ្នាក់ងារឥណទានត្រូវធ្វើការត្រិះរិះពិចារណា សិក្សា វិភាគ និងវាយតម្លៃព័ត៌មានដែលប្រមូលបានទាំងនោះ ថាតើពិតជាត្រឹមត្រូវសម្រាប់ធ្វើការវាយតម្លៃតម្រូវការឥណទានហើយឬនៅ។ ករណីខ្លះ អតិថិជនផ្តល់ព័ត៌មានមិនបានគ្រប់គ្រាន់ ភ្នាក់ងារឥណទានអាចចុះស្រាវជ្រាវ ប្រមូលព័ត៌មានបន្ថែមពីខាងក្រៅ ឬពីអាជ្ញាធរមូលដ្ឋាន ប៉ុន្តែត្រូវរក្សាអាថ៌កំបាំង វិជ្ជាជីវៈ ជៀសវាងការបង្កឱ្យកើតមានហេតុផលមិនល្អ។

- ក្រោយពីបានធ្វើការវាយតម្លៃលទ្ធភាពរបស់អ្នកខ្ចីរួចហើយ ភ្នាក់ងារឥណទានត្រូវបញ្ជាក់ជូនអតិថិជនអំពីលទ្ធភាពដែលអាចទទួលឥណទាន លក្ខខណ្ឌឥណទាន និងមិនត្រូវសន្យាផ្តល់ទំហំឥណទានឡើយ។

➢ **ដំណាក់កាលទី៧៖ ការផ្ទៀងផ្ទាត់អតិថិជន និងការត្រួតពិនិត្យពីអំណះអំណាងអាជីវកម្ម**

- ពិនិត្យមើលទៅលើ៖
  - លំនៅដ្ឋានរបស់អតិថិជន
  - អាជីវកម្មរបស់អតិថិជន
  - ពិនិត្យអំណះអំណាងជាមួយអ្នកផ្គត់ផ្គង់ និងអតិថិជនរបស់អ្នកស្នើសុំខ្ចីប្រាក់។

➢ **ដំណាក់កាលទី៨៖ ការវាយតម្លៃឥណទាន**

- ឥណទានត្រូវបានគណនា ដោយយោងលើព័ត៌មានដែលទទួលបានពី៖
  - ពាក្យស្នើសុំឥណទាន
  - ការិយាល័យឥណទាន
  - ការចុះដល់ទីកន្លែង
  - ការត្រួតពិនិត្យអំណះអំណាង
  - ការវាយតម្លៃប្រាក់ចំណេញ។

➢ **ដំណាក់កាលទី៩៖ ការវាយតម្លៃប្រាក់ចំណេញ**

- សម្រាប់អតិថិជនដែលប្រកបអាជីវកម្មផ្ទាល់ខ្លួន៖
  - ក្នុងករណីដែលរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានផ្តល់ជូន ភ្នាក់ងារឥណទានត្រូវយល់ដឹងពីចំណេញភាពរបស់អតិថិជនតាមរយៈរបាយការណ៍ហិរញ្ញវត្ថុ ដែលបានផ្តល់ជូនដើម្បីយល់ដឹងពីប្រាក់ចំនេញ ដែលនៅសល់ បន្ទាប់ពីការចំណាយរបស់អតិថិជន។
  - ក្នុងករណីដែលគ្មានរបាយការណ៍ហិរញ្ញវត្ថុ ការប៉ាន់ស្មានត្រូវតែធ្វើឡើងតាមរយៈការប៉ាន់ស្មានការលក់ប្រចាំឆ្នាំ និងប្រាក់ចំណេញជាក់ស្តែងរបស់អាជីវកម្មនោះអាស្រ័យលើការពិភាក្សាជាមួយអតិថិជន។
- សម្រាប់អតិថិជនដែលមានប្រាក់បៀវត្សរ៍៖ តួរលេខមធ្យមពីប្រាក់បៀវត្សរ៍ ត្រូវបានយកមកពីកិច្ចសន្យាការងារ ឬសក្ខីបត្រប្រាក់បៀវត្សរ៍។

- **ដំណាក់កាលទី១០៖ ការវាយតម្លៃពីចំណាយ**
  - មូលដ្ឋាននៃសមាជិកសរុបក្នុងគ្រួសារជាក់ស្តែងក្នុងកំឡុងពេលពិភាក្សាផ្ទាល់ និង ប្រភេទចំណាយប្រចាំខែ ត្រូវបានគណនាសម្រាប់គ្រួសារនោះ។
  - ចំណាយផ្សេងៗត្រូវបានបូកសរុប ដើម្បីទទួលបាននូវចំណាយសរុប។
- **ដំណាក់កាលទី១១៖ ការវាយតម្លៃទ្រព្យដាក់បញ្ចាំ**
  - វិធីសាស្ត្រនៃការវាយតម្លៃទ្រព្យដាក់បញ្ចាំដោយមន្ត្រីរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ត្រូវបានអនុវត្តដូចតទៅ៖
    - សម្រាប់ឥណទានដែលមានទំហំរហូតដល់ ៣,០០០ដុល្លារអាមេរិក ឬសមមូលជារូបិយប័ណ្ណផ្សេងៗ ត្រូវបានវាយតម្លៃដោយមន្ត្រីវាយតម្លៃទ្រព្យតែម្នាក់គត់ (ភ្នាក់ងារឥណទានទទួលខុសត្រូវ)។
    - សម្រាប់ឥណទានដែលមានទំហំធំជាង ៣,០០០ដុល្លារអាមេរិក រហូតដល់ក្រោម ១០០,០០០ដុល្លារអាមេរិក ឬសមមូលជារូបិយប័ណ្ណផ្សេងៗ ត្រូវបានវាយតម្លៃដោយមន្ត្រីវាយតម្លៃទ្រព្យយ៉ាងតិចចំនួនពីរនាក់ ដោយម្នាក់ជាភ្នាក់ងារឥណទានទទួលខុសត្រូវ និងម្នាក់ទៀតអាចជាប្រធានភ្នាក់ងារឥណទាន ឬប្រធានផ្នែកលក់សាខា ឬនាយក-នាយិកាសាខា។
    - សម្រាប់ឥណទានដែលមានទំហំចាប់ពី ១០០,០០០ដុល្លារអាមេរិក ឬសមមូលជារូបិយប័ណ្ណផ្សេងៗ ត្រូវបានវាយតម្លៃ ដោយក្រុមវាយតម្លៃទ្រព្យឯករាជ្យពីការិយាល័យកណ្ដាលរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ និងមួយទៀតពីក្រុមហ៊ុនវាយតម្លៃអចលនទ្រព្យខាងក្រៅ។
- **ដំណាក់កាលទី១២៖ ការអនុម័តឥណទាន**
  - លក្ខខណ្ឌចុងក្រោយនៃការផ្ដល់ឥណទាន ត្រូវបានផ្ដល់ជូនអតិថិជន។ ចំពោះការអនុម័តនេះ អតិថិជនត្រូវទាមទារឱ្យរត់ការឯកសារជូនធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ។
- **ដំណាក់កាលទី១៣៖ ការរៀបចំឯកសារកិច្ចសន្យា**
  - តាមការអនុម័តខាងលើ ប្រធានផ្នែកលក់សាខា នឹងរៀបចំលិខិតយល់ព្រមផ្ដល់ឥណទាន។
  - ភ្នាក់ងារឥណទានត្រូវទទួលខុសត្រូវរៀបចំរាល់ឯកសារឥណទាន និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ដោយធ្វើឱ្យប្រាកដថា រាល់ឯកសារមានភាពត្រឹមត្រូវ ច្បាស់លាស់ និង

គ្រប់គ្រាន់។ ពិសេសពិនិត្យដ៏ម៉ត់ចត់ត្រូវតែធ្វើឡើង សម្រាប់ការត្រួតពិនិត្យនូវការលួចបន្លំផ្សេងៗ។

- ភ្នាក់ងារឥណទានត្រូវតែរៀបចំរាល់ឯកសារកិច្ចសន្យា រួមទាំងកិច្ចសន្យាដាក់បញ្ចាំ ឬកិច្ចសន្យាបង្កើតហ៊ីប៉ូតែក និងឯកសារពាក់ព័ន្ធផ្សេងៗទៀត ព្រមទាំងកិច្ចសន្យាខ្ចីប្រាក់ផងដែរ។ លិខិតយល់ព្រមផ្តល់ឥណទាន និងឯកសារធានាសុវត្ថិភាព ត្រូវពិនិត្យ និងចុះហត្ថលេខាដោយនាយក-នាយិកាសាខា/អនុសាខា ឬប្រធានភ្នាក់ងារឥណទាន មុនពេលមន្ត្រីបម្រើអតិថិជនជួប និងឱ្យអតិថិជនចុះហត្ថលេខា/ផ្តិតមេដៃ។
- នៅពេលអ្នកខ្ចី និងអ្នកពាក់ព័ន្ធផ្សេងទៀតបានយល់ព្រម ភ្នាក់ងារឥណទានត្រូវឱ្យពួកគាត់ផ្តិតមេដៃ ឬចុះហត្ថលេខាចំពោះនីតិបុគ្គល នៅចំពោះមុខភ្នាក់ងារឥណទាន។ ភ្នាក់ងារឥណទានត្រូវតែធ្វើវឱ្យប្រាកដថា ស្នាមមេដៃ ឬហត្ថលេខារបស់អតិថិជនគឺពិតជាត្រឹមត្រូវ ច្បាស់លាស់ និងមិនក្លែងក្លាយ។ ប្រសិនបើរកឃើញថា មានការក្លែងបន្លំស្នាមមេដៃ ឬហត្ថលេខា ក្នុងហេតុផលណាក៏ដោយ វិធានការដ៏តឹងរឹងបំផុតនឹងត្រូវធ្វើឡើង។
- សម្រាប់ការបញ្ជាក់រាល់ឯកសារពីអាជ្ញាធរ ភ្នាក់ងារឥណទានត្រូវតែឱ្យអតិថិជនរត់ការឯកសារចុះហត្ថលេខា និងបោះត្រាពីអាជ្ញាធរមូលដ្ឋាន អាស្រ័យទៅតាមកម្រិតភ័យ និងចុះការីបន្ទុកលើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ (ប្លង់រឹង) ពីការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ ឬចុះការីបន្ទុកពីមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដីខេត្ត-រាជធានី ទៅតាមសភាពជាក់ស្តែង។
- បន្ទាប់មក ភ្នាក់ងារឥណទានត្រូវតែប្រគល់ឯកសារឥណទានទាំងអស់នោះទៅមន្ត្រីបម្រើអតិថិជន លើកលែងតែកិច្ចសន្យាដាក់បញ្ចាំ ឬកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ដែលអតិថិជនត្រូវយកមកតាមពួកគាត់ ដើម្បីទទួលឥណទាន បន្ទាប់ពីបានចុះហត្ថលេខា និងចុះការីបន្ទុករួចមក។ នៅពេលដែលអតិថិជនមកការិយាល័យធនាគារ ដើម្បីបើកប្រាក់ដោយយកមកជាមួយនូវកិច្ចសន្យាដាក់បញ្ចាំ ឬកិច្ចសន្យាបង្កើតហ៊ីប៉ូតែក ដែលត្រូវបានចុះហត្ថលេខា និងចុះបន្ទុករួច មន្ត្រីបម្រើអតិថិជនត្រូវតែទទួលឯកសារទាំងនោះយកមកពិនិត្យ បន្ទាប់មកបញ្ជាក់ផ្ទៀងផ្ទាត់ជាមួយឯកសារដែលបានទទួលពីភ្នាក់ងារឥណទាន (ឯកសារអនុម័ត)។

- ចំណុចដែលត្រូវពិនិត្យរួមមាន៖
  - ពិនិត្យមើលលើលេខចេញឯកសារ កាលបរិច្ឆេទ និងហត្ថលេខាអាជ្ញាធរមូលដ្ឋាន
  - ពិនិត្យមើលការចុះការីបន្ទុក និងកាលបរិច្ឆេទនៃការចុះការីបន្ទុករបស់ការិយាល័យរៀបចំដែនដីនគរូបនីយកម្មសំណង់ និងភូមិបាលក្រុង-ស្រុក-ខណ្ឌ ឬចុះការីបន្ទុកពីមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់និងសុរិយោដីខេត្ត-រាជធានី
  - ពិនិត្យមើលឡើងវិញនូវអត្តសញ្ញាណកម្មរបស់អ្នកដែលមកបើកប្រាក់ ដោយធ្វើការប្រៀបធៀបជាមួយឯកសារឥណទាន
  - ពិនិត្យមើលឡើងវិញនូវអត្តសញ្ញាណកម្មរបស់ទ្រព្យដាក់បញ្ចាំ ដោយប្រៀបធៀបជាមួយឯកសារឥណទាន។ល។
- ប្រសិនបើឃើញថា មានភាពមិនច្បាស់លាស់ ឬមិនត្រឹមត្រូវទេ មន្ត្រីបម្រើអតិថិជនត្រូវជម្រាបទៅថ្នាក់មានសមត្ថកិច្ច ដើម្បីដោះស្រាយបញ្ហាឱ្យបានទាន់ពេល និងត្រូវតែកត់ត្រាបញ្ហាទាំងនោះ ដើម្បីជាប្រយោជន៍ក្នុងការកែតម្រូវបច្ចេកទេសការងារទៅថ្ងៃអនាគត។

➢ **ដំណាក់កាលទី១៤៖ ការបញ្ចូលទិន្នន័យ**

- ពិនិត្យឯកសារឡើងវិញពីភាពត្រឹមត្រូវរបស់ឯកសារ ដែលបានដាក់ស្នើសុំមកដូចជាលិខិតដែលទទួលស្គាល់ឥណទាន អត្តសញ្ញាណកម្ម ឯកសារប្រាក់ចំណូល និងធានាសុវត្ថិភាពឥណទាន ដូចដែលបានពិពណ៌នាក្នុងលក្ខណៈសម្បត្តិក្នុងការជ្រើសរើសអតិថិជន និងក្នុងការទទួលយកអតិថិជនក្នុងគោលការណ៍ឥណទាន ព័ត៌មានស្ដីពីអតិថិជន។ ឧទាហរណ៍ ដូចជាឈ្មោះ លេខអត្តសញ្ញាណកម្ម/លេខលិខិតឆ្លងដែនសញ្ជាតិ អាសយដ្ឋាន អ៊ីម៉ែល ទូរស័ព្ទ (នៅផ្ទះ នៅកន្លែងធ្វើការ និងចល័ត) ព័ត៌មានលម្អិតស្ដីពីប្រាក់ចំណូល និងទ្រព្យដាក់បញ្ចាំ ត្រូវបានបញ្ចូលទៅក្នុងប្រព័ន្ធ/ចុះបញ្ជីយ៉ាងត្រឹមត្រូវ។
- បន្ទាប់ពីការអនុវត្តត្រឹមត្រូវរួចរាល់ថា ការរៀបចំឯកសារគឺត្រឹមត្រូវ និងគ្រប់គ្រាន់ និងទិន្នន័យត្រូវបញ្ចូលក្នុងប្រព័ន្ធបានយ៉ាងត្រឹមត្រូវរួចមក មន្ត្រីត្រួតពិនិត្យប្រតិបត្តិការសាខា និងអនុម័តនូវការបញ្ចេញឥណទានចូលក្នុងប្រព័ន្ធ T24 ទៅគណនីបង់ប្រាក់របស់អតិថិជន។

- បន្ទាប់ពីទិន្នន័យឥណទានត្រូវបានបញ្ចូលក្នុងប្រព័ន្ធចប់សព្វគ្រប់ មន្ត្រីប្រតិបត្តិការត្រូវបោះពុម្ពចេញនូវតារាងកាលវិភាគសងប្រាក់ និងបង្កាន់ដៃតម្កល់ទ្រព្យធានា ប័ណ្ណដកប្រាក់/ប័ណ្ណចំណាយឱ្យខ្ចី និងឯកសារពាក់ព័ន្ធនានា។
- ចុះហត្ថលេខាលើតារាងកាលវិភាគសងប្រាក់ ហើយបន្ទាប់មកផ្ញើឯកសារឥណទានរបស់អតិថិជននោះ ទៅកាន់បេឡាធិការសម្រាប់បញ្ចេញឥណទាន។

➢ **ដំណាក់កាលទី១៥៖ ការបញ្ចេញឥណទាន**

- បេឡាធិការ នឹងត្រួតពិនិត្យនូវឯកសារដែលបានត្រួតពិនិត្យរួចដោយមន្ត្រីប្រតិបត្តិការសាខា ឈ្មោះអតិថិជន បរិមាណទឹកប្រាក់ដែលបានបញ្ចេញ លេខគណនីប្រាក់បញ្ញើ-សន្សំ/គណនីសម្រាប់សងប្រាក់សំណង សម្រាប់ការដាក់ប្រាក់ចូលក្នុងគណនីនូវទំហំទឹកប្រាក់ដែលត្រូវបញ្ចេញ និងបន្ទាប់មកនឹងត្រូវបញ្ចេញឥណទានចូលទៅក្នុងគណនីប្រាក់បញ្ញើ-សន្សំ/គណនីសម្រាប់សងប្រាក់សំណង។
- បេឡាធិការនឹងត្រូវពិនិត្យឡើងវិញនូវគ្រប់លក្ខខណ្ឌនៃការផ្តល់ឥណទាន ដូចជារបៀបសងប្រាក់ បរិមាណដែលត្រូវសងត្រឡប់ ការពិន័យ និងលក្ខខណ្ឌនៃការទទួលឥណ ទាន។
- មុនពេលបើកប្រាក់ បេឡាធិការត្រូវឱ្យអតិថិជនផ្តិតមេដៃស្តាំលើប័ណ្ណចំណាយឱ្យខ្ចី ឬប័ណ្ណដកប្រាក់ (ករណីអតិថិជនបើកប្រាក់តាមគណនីធនាគារ) ហើយប្រាប់ពួកគាត់អំពីលក្ខខណ្ឌនៃការប្រគល់-ទទួលប្រាក់ ដូចជាពិនិត្យ និងរាប់ប្រាក់ មុនពេលចាកចេញពីបញ្ជរ។
- ព័ត៌មានលម្អិតស្តីពីការបញ្ចេញឥណទាន និងត្រូវបញ្ចូលទៅក្នុងប្រព័ន្ធ។

## ៣.៥.ការវាយតម្លៃប្រាក់កម្ចី

ការវាយតម្លៃប្រាក់កម្ចី គឺជាការប្រមូលព័ត៌មាននៅជុំវិញអ្នកខ្ចី អំពីមុខរបរ ចំណូល ចំណាយ ទ្រព្យសម្បត្តិដាក់បញ្ចាំ អ្នកធានា។ល។ ដោយយកមកពិចារណា និងប៉ាន់ស្មាន ដើម្បីធ្វើការសម្រេចចិត្ត ផ្តល់ ឬមិនផ្តល់ឥណទានជូនអតិថិជនឱ្យបានត្រឹមត្រូវស្របទៅតាមគោលការណ៍ ទាំងទំហំឥណទាន និងរយៈពេលនៃឥណទាន ដើម្បីប្រាកដថាឥណទាននឹងត្រូវបានប្រមូលមកវិញ ១០០%។ ម្យ៉ាងទៀត គេអាចនិយាយថាវាជាការសិក្សាដើម្បីធ្វើការព្យាករណ៍ទៅលើសមត្ថភាពសងរបស់អតិថិជនដោយផ្អែកទៅលើព័ត៌មាន និងទិន្នន័យដែលទទួលពីអតិថិជន។

ដើម្បីផ្តល់ឥណទានឱ្យអតិថិជន ប្រកបទៅដោយប្រសិទ្ធិភាព ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ធ្វើការសិក្សាលើ CAMPADRIC ដែលមាន៖

- Character: អត្តចរិក ជាលក្ខណៈវិនិច្ឆ័យមួយ ដោយការមើលលើសកម្មភាព អារម្មណ៍ និងការគិត។ អត្តចរិក និងភាពស្មោះត្រង់ បង្ហាញតាមរយៈឥរិយាបថ ការសន្ទនា គំនិត ទស្សនៈវិស័យ សីលធម៌ ការទទួលខុសត្រូវ និងការប្តេជ្ញាចិត្ត។
- Ability: សមត្ថភាព ចំណូលជាប្រភពចំបងសំខាន់បំផុត ក្នុងការសងត្រលប់មកវិញនៃឥណទាន។ ត្រូវធ្វើការសិក្សាលើកត្តាទាំងឡាយណា ដែលនាំឱ្យលំហូរសាច់ប្រាក់មានការរាំងស្ទះ នៅក្នុងដំណើរការអាជីវកម្ម។
- Margin: ផលចំណេញ សម្តៅលើអត្រាការប្រាក់ ដែលយកពីអតិថិជន សោហ៊ុយចំណាយ និងកម្រៃជើងសារ។ អត្រាការប្រាក់តាមទីផ្សារជាក់ស្តែង ការចំណាយលើ Loan Fee, Fee CBC, ការចុះហត្ថលេខាពីមេភូមិ ឃុំ ការចុះការីបន្ទុក លើកិច្ចសន្យាដាក់បញ្ចាំ និងប័ណ្ណកម្មសិទ្ធិជាដើម។
- Purpose: គោលបំណង ក្នុងការស្នើសុំឥណទាន ចំនួនដែលអតិថិជនត្រូវការខ្ចី យកទៅប្រើលើការវិនិយោគវិស័យណាមួយ។
- Amounts: ទំហំឥណទាន សមរម្យនឹងគោលបំណងនៃការខ្ចី រយៈពេលស្នើសុំស៊ីគ្នានឹងលំហូរសាច់ប្រាក់ចូលមកវិញ ប្រភពចំណូលដែលអតិថិជនទទួលបាន។
- Document: ផ្ទៀងផ្ទាត់ឯកសារដើម្បីបញ្ជាក់ពីភាពគ្រប់គ្រាន់ និងត្រឹមត្រូវដូចគ្នានឹងឯកសារផ្សេងទៀត។ ឧទាហរណ៍ ឈ្មោះអតិថិជននៅក្នុងប័ណ្ណសម្គាល់ខ្លួន និងឈ្មោះអតិថិជនក្នុងប័ណ្ណកម្មសិទ្ធិលើទ្រព្យធានាដូចគ្នា និងគ្មានកំហុសអក្ខរាវិរុទ្ធ។
- Repayment: ការសងត្រលប់មកវិញ គាត់យកប្រាក់មកពីណាដើម្បីធ្វើការសងធនាគារ និងមានប្រភពចំណូលមកពីណាខ្លះ។ ប្រភពចំណូលរបស់គាត់មាននិរន្តភាពប៉ុណ្ណា អាចរហូតដល់កាលអវសាននៃឥណទានឬទេ។
- Insurer: អ្នកធានា បើទ្រព្យធានាមិនអាចធ្វើការធានាលើឥណទានបាន ត្រូវធ្វើ និងដាក់លក្ខខណ្ឌបន្ថែមទៀត។
- Collateral: ទ្រព្យសម្បត្តិដាក់ធានា មានតម្លៃក្នុងកម្រិតណា វាអាចធានាលើបំណុលបានទេ ត្រូវគិតតម្លៃវានៅទីផ្សារ និងភាពងាយស្រួលក្នុងការជួញដូរ។

## ៣.៦.ទ្រព្យធានា

ទ្រព្យធានាជាកត្តាមួយ ដែលជម្រុញឱ្យអតិថិជនធ្វើការសងឥណទានបានគ្រប់ចំនួន និងទាន់ពេលដែលបានកំណត់។

### ៣.៦.១.កម្រិតសុវត្ថិភាព

ទំហំឥណទានដែលកំណត់តាមទ្រព្យធានា ឬបញ្ចាំត្រូវបានកំណត់ទៅតាមប្រភេទនៃទ្រព្យដាក់ធានា ដូចខាងក្រោម៖

- ករណីទ្រព្យធានាជាដី ផ្ទះ ឬអគារ៖
  - ទំហំឥណទានមិនត្រូវលើសពី ៧៥% នៃតម្លៃប៉ាន់ស្មានងាយលក់នៃទ្រព្យសម្បត្តិ (សម្រាប់ដីមានផ្ទះ) ដែលដាក់ធានាក្នុងករណីដែលអ្នកខ្ចីមានអត្តចរិតកេរ្តិ៍ឈ្មោះ មុខរបរ និងមានលទ្ធភាពហិរញ្ញវត្ថុគ្រប់គ្រាន់។
  - តម្រូវឱ្យមានឯកសារកម្មសិទ្ធ ជាប្លង់រឹង ឬប្លង់ទន់ ត្រូវចុះការីបន្ទុកដាក់បញ្ចាំពីមន្ទីរ ឬការិយាល័យរៀបចំដែនដីនគរូបនីកម្មសំណង់ និងសុរិយោដី រាជធានី/ខេត្ត, ក្រុង/ស្រុក/ខណ្ឌ។
- ករណីទ្រព្យធានាជាទឹកប្រាក់នៅក្នុងគណនីប្រាក់បញ្ញើ៖ ទំហំឥណទានត្រូវតិចជាង ១០០% នៃទឹកប្រាក់ក្នុងគណនី ដែលបានដាក់ជាទ្រព្យធានាក្នុងរយ:ពេលខ្ចី។ រយ:ពេលខ្ចីមិនត្រូវលើសពីរយ:ពេលរបស់គណនីប្រាក់បញ្ញើនោះទេ។

### ៣.៦.២.ការវាយតម្លៃទ្រព្យធានា

ធនាគារ ប្រៃសណីយ៍កម្ពុជា មានវិធីសាស្ត្រក្នុងការវាយតម្លៃទ្រព្យធានា ដើម្បីធ្វើឱ្យមានភាពជឿជាក់លើទ្រព្យបញ្ចាំ។ វិធីសាស្ត្រនោះ គឺធ្វើការសិក្សាលើ REALTOR ៖

- Right Collateral : ទ្រព្យសម្បត្តិស្របច្បាប់
- Estimate Value of Collateral : តម្លៃប៉ាន់ស្មាននៃទ្រព្យសម្បត្តិ
- Abilities to Sell Collateral : លទ្ធភាពដែលទ្រព្យធានាអាចធ្វើការលក់ដូរបាន
- Location of Collateral : ទីតាំងរបស់ទ្រព្យធានា
- Type of Collateral : ប្រភេទនៃទ្រព្យធានា
- Ownership of Collateral : ភាពជាម្ចាស់កម្មសិទ្ធរបស់ទ្រព្យធានា
- Risk of Collateral : ហានិភ័យរបស់ទ្រព្យធានា។

## ៣.៧.ការតាមដានត្រួតពិនិត្យឥណទាន

### ៣.៧.១.ដំណើរការត្រួតពិនិត្យ

ដំណើរការត្រួតពិនិត្យ ត្រូវបានកំណត់ដោយការចាប់ផ្តើមពីពេលដែលអតិថិជនដាក់ពាក្យចុះឈ្មោះសុំខ្ចីប្រាក់រហូតដល់ប្រាក់សំណងចុងក្រោយត្រូវបានប្រមូល។

កិច្ចការត្រួតពិនិត្យរួមមាន៖

- ការចុះបញ្ជីទទួលពាក្យសុំចុះឈ្មោះខ្ចីប្រាក់របស់អតិថិជន
- ការវាយតម្លៃឥណទាន
- ការបំពេញឯកសារឥណទាន
- ការអនុម័តឥណទាន
- ការបញ្ចេញឥណទាន
- ការរៀបចុះទុកដាក់គ្រប់គ្រងឯកសារ
- ការប្រមូលប្រាក់សំណាង និងតាមដានលើប្រាក់សំណាង
- ការវិភាគឡើងវិញអំពីស្ថានភាពអ្នកខ្ចី។

### ៣.៧.២.ប្រព័ន្ធត្រួតពិនិត្យឥណទាន

ប្រព័ន្ធត្រួតពិនិត្យឥណទានមានគ្រប់បណ្ដាផ្នែកពាក់ព័ន្ធ ត្រូវតែបំពេញភារកិច្ចឱ្យបានល្អិតល្អន់ និងម៉ឺងម៉ាត់ ដើម្បីមានលទ្ធភាពគ្រប់គ្រង និងកាត់បន្ថយហានិភ័យឥណទាន មិនតែប៉ុណ្ណោះវានឹងផ្ដល់អត្ថប្រយោជន៍ដទៃទៀតជាច្រើនក្នុងកិច្ចការធនាគារ។ ម៉្យាងទៀត ជាការចាំបាច់ដែលត្រូវតែដឹងនូវបម្រែបម្រួលនៃហានិភ័យ ដើម្បីឈានឆ្ពោះទៅការចាត់វិធានការបានទាន់ពេលវេលា និងមានប្រសិទ្ធិភាពក្នុងការងារគ្រប់គ្រង់ឥណទានរបស់ធនាគារ។

ប្រព័ន្ធត្រួតពិនិត្យឥណទានរួមមាន៖

- ប្រព័ន្ធ MIS (Management Information System)
- គោលនយោបាយ នីតិវិធី និងការណែនាំអំពីឥណទាន
- នាយកដ្ឋាន និងផ្នែកពាក់ព័ន្ធ រួមមាន នាយកដ្ឋានឥណទានខ្នាតតូច និងមធ្យម នាយកដ្ឋានហិរញ្ញវត្ថុ នាយកដ្ឋានសវនកម្មផ្ទៃក្នុង ផ្នែកនីតិកម្ម និងផ្នែកគ្រប់គ្រងហានិភ័យ និងប្រតិបត្តិការ
- ថ្នាក់មានសមត្ថកិច្ចគ្រប់គ្រងផ្ទាល់មាន នាយក-នាយិការសាខាធនាគារ ប្រធានមន្ត្រីឥណទានសាខា។

### ៣.៧.៣.ត្រួតពិនិត្យឥណទាន

➢ **ត្រួតពិនិត្យប្រចាំថ្ងៃ**

ប្រើប្រាស់ប្រព័ន្ធ MIS តាមដានត្រួតពិនិត្យសមតុល្យឥណទាន ដើម្បីគ្រប់គ្រងបរិមាណ និងគុណភាពឥណទានប្រចាំថ្ងៃ។

មន្ត្រីឥណទាន ត្រូវត្រួតពិនិត្យរបាយការណ៍សងប្រាក់ប្រចាំថ្ងៃចំពោះអតិថិជនដែលខ្លួនកំពុងទទួលខុសត្រូវ។ មន្ត្រីដោះស្រាយបំណុល ត្រូវត្រួតពិនិត្យតាមដានបញ្ជីខកខានសងប្រាក់ធ្ងន់ធ្ងរ បំណុលលុបចេញពីបញ្ជី មន្ត្រីឥណទានត្រូវចុះទៅដល់ទីកន្លែងមុខរបរ និងទីលំនៅអតិថិជន ដើម្បីត្រួតពិនិត្យដោយផ្តោតការយកចិត្តទុកដាក់លើ៖

- ការប្រើប្រាស់ប្រភពទុនសកម្ម ដំណើរការមុខរបរ និងទំនោរនៃមុខរបរ
- ស្ថានភាពហិរញ្ញវត្ថុ
- ស្ថានភាពទ្រព្យធានាដូចជា ការប្រែប្រួលតម្លៃ ទំហំ ឬភាពមិនប្រក្រតី ចំពោះកម្មសិទ្ធិប្រភេទទ្រព្យសម្បត្តិ
- ស្ថានភាពអាជីវកម្មដែលកំពុងដំណើរការ
- ស្ថានភាពទូទាត់របស់អតិថិជន
- រយៈពេលដែលអាជីវកម្មបានដំណើរការ។

ការត្រួតពិនិត្យឥណទានតាមពេលកំណត់នេះ មន្ត្រីឥណទានត្រូវរៀបចំរបាយការណ៍ ព្រមទាំងរក្សាទុកក្នុងសំណុំឯកសារឥណទានរបស់អតិថិជន (Client File)។

នាយកប្រតិបត្តិឥណទានខ្នាតមធ្យម ជាអ្នកកំណត់ទំហំឥណទាន សម្រាប់ធ្វើការត្រួតពិនិត្យតាមពេលកំណត់ (Periodic Control) ដោយផ្អែកលើការវាយតម្លៃកម្រិតហានិភ័យ។

## ៣.៨.គោលការណ៍នៃការសងត្រលប់

### ៣.៨.១.របៀបសងប្រាក់

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ អនុញ្ញាត្តិឱ្យអតិថិជនធ្វើការសងប្រាក់ត្រលប់មកវិញតាម ៤ របៀប៖

- ការសងរំលស់ប្រាក់ដើម និងការប្រាក់ថេរប្រចាំខែ៖ អតិថិជន ត្រូវសងប្រាក់ថេរប្រចាំខែ ដែលក្នុងនោះប្រាក់ដើម និងការប្រាក់ត្រូវបានបូកបញ្ចូលគ្នា។
- ការសងរំលស់ប្រាក់ដើមថយចុះ និងការប្រាក់ប្រចាំខែ៖ អតិថិជនអាចសងប្រាក់ដើមថេរ ប្រចាំខែ បូកនឹងការប្រាក់ជាក់ស្តែង ប្រចាំខែនីមួយៗ។ នេះមានន័យថា បរិមាណការសងនឹងខ្ពស់នៅដំណាក់កាលដំបូងនៃឥណទាន តែវានឹងថយចុះនៅដំណាក់កាលបន្ទាប់មកទៀត។
- ការសងបែបប៊ូឡេត៖ អតិថិជន នឹងមិនធ្វើការសងប្រាក់ដើមប្រចាំខែក្នុងកំឡុងពេលនៃឥណទានឡើយ។ អតិថិជន សងតែការប្រាក់ប្រចាំខែ ចំណែកឯប្រាក់ដើមនឹងត្រូវធ្វើការទូទាត់ នៅពេលចុងបញ្ចប់នៃឥណទាន។

- ការសងបែបសីមីប៊ូឡេតៈ អតិថិជនធ្វើការសងប្រាក់ដើម និងការប្រាក់ប្រចាំខែជាភាគរយ។ ការសងការប្រាក់ប្រចាំខែ និងសងប្រាក់ដើមរៀងរាល់ចន្លោះចាប់ពី ពីរខែ ដល់ប្រាំមួយខែម្តង។

### ៣.៨.២.ឥណទានបង់ផ្តាច់

អតិថិជន ដែលមានបំណងចង់បង់ផ្តាច់ឥណទាននឹងត្រូវគោរពតាមលក្ខខណ្ឌក្នុងកិច្ចសន្យានៅពេលខ្ចីប្រាក់។ ធនាគារ នឹងធ្វើការពិន័យសម្រាប់អតិថិជនដូចខាងក្រោមៈ

- ក្នុងរយៈពេលក្រោម១២ខែ អតិថិជនមិនអាចធ្វើការបង់ផ្តាច់ឥណទានបានទេ។
- ចាប់ពី១២ខែដល់២៤ខែ អតិថិជននឹងត្រូវពិន័យ៣% នៃប្រាក់ដែលនៅសល់។
- ចាប់ពី២៤ខែ ដល់៣៦ខែ អតិថិជននឹងត្រូវពិន័យ២%នៃប្រាក់នៅសល់។
- ចាប់ពី៣៦ខែឡើងទៅ អតិថិជននឹងមិនត្រូវបានពិន័យ និងគ្មានការគិតការប្រាក់លើឥណទានឡើយ។

### ៣.៨.៣.ការផ្តល់ឥណទានបន្ថែម

ការផ្តល់ឥណទានបន្ថែម ត្រូវបានកើតឡើងតាមពីរករណីៈ

- ករណីអតិថិជនធ្វើការបង់ផ្តាច់ហើយ ទើបធ្វើការខ្ចីបន្តៈ ធនាគារនឹងធ្វើការសិក្សាលើអតិថិជនឡើងវិញ ដើម្បីមើលលើលទ្ធភាពរបស់អតិថិជន ដោយធនាគារអាចនឹងធ្វើការអនុគ្រោះដល់អតិថិជនខ្លះៗ ទៅតាមការចរចាររវាងធនាគារ និងអតិថិជន។
- ករណីអតិថិជនមិនធ្វើការបង់ផ្តាច់ ហើយចង់ខ្ចីឥណទានបន្ថែមទៀតៈ ធនាគារនឹងសិក្សាលើអតិថិជន ទាំងគោលបំណងនៃការខ្ចីបន្ថែម ការប្រើប្រាស់ឥណទានកន្លងមក និងលទ្ធភាពក្នុងការសងប្រសិនបើធនាគារអនុញ្ញាត្តិឥណទានបន្ថែមទៀត។ ធនាគារតម្រូវឱ្យអតិថិជន មានទ្រព្យធានាផ្សេងទៀត ដើម្បីធ្វើការធានាលើឥណទានបន្ថែម។

## ៣.៩.ការខកខាន និងការពិន័យ

### ៣.៩.១.ការខកខាន

ឥណទាន ដែលអតិថិជនមិនបានសងតាមកិច្ចសន្យា ឬគារាងសងប្រាក់ ឥណទាននោះនឹងត្រូវបានចាត់ទុកថាជាឥណទានខកខាន។ កម្រិតនៃការខកខានអាស្រ័យទៅនឹងចំនួនថ្ងៃ ដែលអតិថិជនមិនបានធ្វើការទូទាត់ជូនធនាគារតាមពេលកំណត់។

- ការខកខានកម្រិតស្រាលៈ អតិថិជនដែលខកខានក្នុងការសងធនាគារ ឬសងប្រាក់មិនគ្រប់ចំនួនក្នុងរយៈពេលតិចជាង ៣០ថ្ងៃ ធនាគារនឹងចាត់ទុកឥណទាននោះជាឥណទានខកខានកម្រិតស្រាល។

- ការខកខានកម្រិតធ្ងន់៖ នៅពេលដែលអតិថិជនខកខានលើសពី៣០ថ្ងៃ ឬធ្វើការទូទាត់ទឹកប្រាក់មិនគ្រប់ចំនួន។

### ៣.៩.២.ការពិន័យ

#### ៣.៩.២.១.ការគណនាប្រាក់ពិន័យ

ការពិន័យនេះ នឹងធ្វើឡើងចំពោះអតិថិជន ដែលខកខានក្នុងការទូទាត់បំណុលតាមកិច្ចសន្យា។ អតិថិជន ដែលខកខានចាប់ពី៣ថ្ងៃឡើងទៅ ធនាគារនឹងធ្វើការពិន័យដោយគណនាតាមអត្រាពិន័យនៅក្នុងកិច្ចសន្យា លើចំនួនទឹកប្រាក់ដែលអតិថិជនខកខានមិនបានសងសមាមាត្រនឹងថ្ងៃដែលខកខានមិនបានសងនោះ ជាមួយនឹងអត្រាពិន័យ ២៤%ក្នុងមួយឆ្នាំ។

**រូបមន្តទី ៣.១ ៖ ការគណនាប្រាក់ពិន័យ**

$$F = (C \times t \times N) \div 360$$

ដែល៖ F : ជាប្រាក់ពិន័យ

C : ជាចំនួនទឹកប្រាក់ដែលខកខានមិនបានសងតាមកាលកំណត់

t : ជាអត្រាពិន័យ ២៤%ក្នុងមួយឆ្នាំ

N : ជាចំនួនថ្ងៃដែលខកខានមិនបានសង។

#### ៣.៩.២.២.ការលើកលែងប្រាក់ពិន័យ

នាយកសាខា មានសិទ្ធិសម្រេចលើការលុបចោលប្រាក់ពិន័យ ដោយពិចារណាលើផលប្រយោជន៍ និងផលប៉ះពាល់រយៈពេលវែង។ ក្នុងករណីដែលអតិថិជនមានហានិភ័យឥណទានខ្ពស់ ក្រុមដោះស្រាយបំណុលនឹងស្វែងរកដំណោះស្រាយណាដែលឆាប់រហ័ស និងមានប្រសិទ្ធិភាពខ្ពស់ ដោយការលុបចោលការពិន័យ។ មុនពេលជ្រើសរើសឥណទាន ដែលត្រូវធ្វើការលុបចោលការពិន័យ សាខាធនាគារត្រូវធ្វើការសិក្សាលើចំនុចដូចខាងក្រោម៖

- ឥណទានណាដែលមិនមានផលប៉ះពាល់ដល់ប្រាក់ចំណេញ-ខាតរបស់ធនាគារ នឹងអាចត្រូវបានលើកលែងការពិន័យ។
- ឥណទានដែលខកខានសងប្រាក់រយៈពេលខ្លី និងការចំណាយថ្លៃដើមទាប។
- ឥណទានដែលគ្មានដាន/រត់គេច ទាក់ទងតាមទូរស័ព្ទបាន ប៉ុន្តែពេលចុះជួបផ្ទាល់គ្មានប្រសិទ្ធិភាព មរណភាព ជាប់គុក ជួបវិបត្តិហិរញ្ញវត្ថុធ្ងន់ធ្ងរ ឈឺ/គ្រោះថ្នាក់ និង/ឬ ឥណទានដែលមានហានិភ័យខ្ពស់ នឹងទទួលបានអាទិភាពក្នុងការលុបចោលការពិន័យ។

## ៣.១០.ការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធន

ដើម្បីបង្ហាញពីគុណភាពទ្រព្យសកម្មរបស់ធនាគារ និងការពារវាពីឥណទានបាត់បង់នៅពេលអនាគត គ្រប់ធនាគារត្រូវតែធ្វើចំណាត់ថ្នាក់ឥណទាន និងរក្សានូវសំវិធានធនឥណទានបាត់បង់ ឱ្យស្របទៅនឹងតម្រូវការបទបញ្ញត្តិ។ គោលដៅចំបងនៃការធ្វើចំណាត់ថ្នាក់ឥណទាន និងសំវិធានធនគឺដើម្បីពង្រឹងវិន័យឥណទាន និងរចនាសម្ព័ន្ធដើមទុនរបស់ធនាគារ។

### ៣.១០.១.ការធ្វើចំណាត់ថ្នាក់ឥណទាន

គ្រប់ប្រភេទឥណទានទាំងអស់របស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ត្រូវបានធ្វើចំណាត់ថ្នាក់ដោយផ្អែកលើសមត្ថភាពសងរបស់អ្នកខ្ចី។ សមត្ថភាពសងនេះត្រូវបានវាយតម្លៃតាមរយៈលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ប្រវត្តិនៃការទូទាត់សង
- ស្ថានភាពហិរញ្ញវត្ថុរបស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងពេលអនាគត
- គម្រោងលំហូរសាច់ប្រាក់ និងអាជីវកម្មសម្រាប់អនាគត ដែលផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន
- លទ្ធភាព និងឆន្ទៈក្នុងការសងត្រឡប់មកវិញរបស់អ្នកខ្ចី
- បរិស្ថានហិរញ្ញវត្ថុ
- គុណភាពនៃការរៀបចំឯកសារ។

ករណីប្រភពដំបូងនៃការទូទាត់សងមិនអាចធានាបានចំពោះការទូទាត់សង ឥណទានអាចត្រូវបានធ្វើចំណាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬមិនដំណើរការ ទោះបីជាឥណទាននោះមានលក្ខណៈចរន្ត ឬអាចនឹងត្រូវទូទាត់ដោយវត្ថុធានាក៏ដោយ។ ការធ្វើចំណាត់ថ្នាក់ឥណទានឡើងវិញក៏អាចធ្វើផងដែរ ប្រសិនបើអ្នកខ្ចីមិនអាចបំពេញតាមលក្ខខណ្ឌដើមនៃការទូទាត់សង ឬបើឥណទានមិនដំណើរការនោះ ត្រូវបានដោះស្រាយ ដោយបច្ចេកទេសនៃការផ្លាស់ប្តូរលក្ខខណ្ឌបុនហិរញ្ញប្បទាន ឬបុរេប្រទានបន្ថែម (Refinancing or Additional Advance)។

ក្នុងករណីដែលការធ្វើចំណាត់ថ្នាក់នីមួយៗនៃឥណទាន ផ្អែកលើលក្ខណៈវិនិច្ឆ័យមិនច្បាស់លាស់ ការធ្វើចំណាត់ថ្នាក់ដ៏តឹងរឹងជាងនេះ ត្រូវតែអនុវត្ត។ ករណីដែលការវិភាគស្ថានភាពហិរញ្ញវត្ថុ សមត្ថភាព និងឆន្ទៈសងត្រឡប់មកវិញរបស់អ្នកខ្ចី បានបង្ហាញឱ្យឃើញថា មានស្ថានភាពធ្ងន់ធ្ងរ នោះចំណាត់ថ្នាក់ឥណទានត្រូវធ្វើឡើងឱ្យកាន់តែមានភាពតឹងរឹងបន្ថែមទៀត។

ចំណាត់ថ្នាក់ឥណទានត្រូវចែកជា ៥ប្រភេទដូចខាងក្រោម៖

**តារាងទី ៣.៤ ៖ ចំណាត់ថ្នាក់ឥណទាន**

| ចំណាត់ថ្នាក់/លក្ខណៈវិនិច្ឆ័យ | ដំណើរការសងប្រាក់ |
|---|---|
| **១. ធម្មតា (Normal)**<br>-ទ្រព្យសកម្មប្រភេទនេះ ត្រូវបានធានាទាំងស្រុងដោយទ្រព្យសម្បត្តិ និងសមត្ថភាពទូទាត់របស់អ្នកខ្ចីនាពេលបច្ចុប្បន្ន និងជាទ្រព្យសកម្មកំពុងដំណើរការ ដោយអនុលោមទៅតាមកិច្ចសន្យា និងរំពឹងទុកថា នៅតែបន្តដំណើរការបែបនេះ រហូតតទៅ។ | -ទៀងទាត់<br>-និង ហួសកាលកំណត់សងតិចជាង៣០ថ្ងៃ |
| **២. ឃ្លាំមើល (Special Mention)**<br>-ទ្រព្យសកម្មប្រភេទនេះ នឹងត្រូវបានធានា ប៉ុន្តែត្រូវមានចំណុចខ្សោយខ្លះ ដែលជាសក្តានុពល និងធ្វើឱ្យគុណភាពទ្រព្យសកម្មចុះខ្សោយ ឬនាំឱ្យស្ថានភាពធនាគារ មិនត្រូវបានការពារនៅពេលណាមួយខាងមុខ បើចំនុចខ្សោយទាំងនោះមិនត្រូវបានកែតម្រូវទេនោះ។<br>ឧទាហរណ៍ខ្លះៗនៃចំនុចខ្សោយទាំងនោះ រួមមាន ភាពគ្មានលទ្ធភាពត្រួតពិនិត្យឱ្យបានសមស្រប ដោយសារតែកិច្ចសន្យាខ្ចីប្រាក់ មានចន្លោះប្រហោង ភាពអន់ថយនៃស្ថានភាព ឬការគ្រប់គ្រងវត្ថុធានា ការធ្លាក់ចុះនៃស្ថានភាពសេដ្ឋកិច្ច ឬនិន្នាការចុះខ្សោយនៃស្ថានភាពហិរញ្ញវត្ថុ របស់អ្នកខ្ចី ហើយបើមិនបានត្រួតពិនិត្យទេ នឹងនាំឱ្យខូចខាតដល់សមត្ថភាពទូទាត់សង រួមទាំងហានិភ័យដែលអាចកើតមានឡើង ធំជាងហានិភ័យដែលបានគិតនាពេលចាប់ផ្តើមផ្តល់ឥណទាន។ ឥណទាន | -ឥណទានដែលហួសកាលកំណត់សង ចាប់ពី៣០ថ្ងៃ ឬលើសពីនេះ ប៉ុន្តែតិចជាង៩០ថ្ងៃ ត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬអន់ជាងនេះ។<br>-នៅពេលដែល ការទូទាត់សង ការប្រាក់សម្រាប់រយៈពេលពី៣០ថ្ងៃ ទៅ៩០ថ្ងៃ ត្រូវបានបញ្ចូលជាប្រាក់ដើមធ្វើ បុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (Rolled over loans) ឥណទាននេះ ត្រូវចាត់ថ្នាក់ជាឥណទានឃ្លាំមើល ឬអន់ជាងនេះ។ |

| | |
|---|---|
| ប្រភេទនេះ មិនគួរប្រើប្រាស់ជាការសម្របសម្រួល នៅពេលចាត់ថ្នាក់ឥណទានធម្មតា និងឥណទានក្រោមស្តង់ដារទេ។ | |
| **៣. ក្រោមស្តង់ដារ (Sub-Standard)**<br>-ទ្រព្យសកម្មប្រភេទនេះ មិនត្រូវបានការពារគ្រប់គ្រាន់ដោយទ្រព្យសម្បត្តិ និងសមត្ថភាពសងបំណុលរបស់អ្នកខ្ចីឡើយ។ ជាពិសេសប្រភពធនធានចំបង សម្រាប់សងបំណុលមានមិនគ្រប់គ្រាន់ ដើម្បីសងបំណុលដែលធនាគារត្រូវតែសំឡឹងមើលទៅប្រភពធនធានបន្ទាប់ ដូចជាវត្ថុធានា ការលក់អចលនទ្រព្យបុនហិរញ្ញប្បទាន ឬការបំពេញទុនបន្ថែម សម្រាប់ទូទាត់បំណុល។ ឥណទានក្រោមស្តង់ដារ បានបង្ហាញយ៉ាងច្បាស់នូវចំណុចខ្សោយ ដែលធ្វើឱ្យប៉ះពាល់ដល់ ការទូទាត់បំណុលត្រឹមត្រូវតាមលំដាប់លំដោយ។ | -ឥណទានដែលហួសកាលកំណត់សង ចំនួន ៩០ថ្ងៃ ឬលើសពីនេះ ប៉ុន្តែតិចជាង១៨០ថ្ងៃ ត្រូវចាត់ថ្នាក់យ៉ាងទាបបំផុត ក្រោមស្តង់ដារ។<br>-នៅពេលដែល ការទូទាត់សង ការប្រាក់សម្រាប់រយៈពេលពី៩០ថ្ងៃ ទៅ១៨០ថ្ងៃ ត្រូវបានបញ្ចូលជាប្រាក់ដើមធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (Rolled over loans) ឥណទាននេះ ត្រូវចាត់ថ្នាក់ជាឥណទានក្រោមស្តង់ដារ ឬអន់ជាងនេះ។ |
| **៤. សង្ស័យ (Doubtful)**<br>-ទ្រព្យសកម្មប្រភេទនេះ មានចំណុចខ្សោយដូចឥណទានក្រោមស្តង់ដារ ដោយបូកបន្ថែមលក្ខខណ្ឌដែលឥណទាន មិនមានការធានាបានល្អ។ យោងតាមហេតុការណ៍ជាក់ស្តែងស្ថានភាព និងតម្លៃចំណុចខ្សោយទាំងនោះ បាននាំឱ្យមានការសង្ស័យថា ឥណទានមិនអាចប្រមូលបានមកវិញទាំងស្រុងទេ។ លទ្ធភាពបាត់បង់មានកម្រិតខ្ពស់ ប៉ុន្តែដោយសារតែមានការរង់ចាំលើព្រឹត្តិការណ៍ជាក់ស្តែង និងសមស្របណាមួយ ដែលនឹងកាត់បន្ថយកម្រិត | -ឥណទានដែលហួសកាលកំណត់សង ចំនួន ១៨០ថ្ងៃ ឬលើសពីនេះ ត្រូវចាត់ថ្នាក់យ៉ាងទាបបំផុតជាបំណុលសង្ស័យ ឬអន់ជាងនេះ។<br>-នៅពេលដែល ការទូទាត់សង ការប្រាក់សម្រាប់រយៈពេលពី១៨០ថ្ងៃ ទៅ៣៦០ថ្ងៃ ត្រូវបានបញ្ចូលជាប្រាក់ដើមធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (Rolled over loans) ឥណទាននេះ ត្រូវចាត់ថ្នាក់ជាឥណទានសង្ស័យ ឬអន់ជាងនេះ។ |

| | |
|---|---|
| បាត់បង់ នោះបរិមាណពិតប្រាកដនៃបំណុលដែលត្រូវបានបាត់បង់មិនអាចកំណត់បានទាំងស្រុង។ បើព្រឹត្តិការណ៍ដែលរង់ចាំនោះ មិនបានកើតឡើង ក្នុងរយៈពេល១៨០ថ្ងៃ ហើយការទូទាត់សងត្រូវបានពន្យារពេលបន្ថែមទៀតនោះ ការចាត់ថ្នាក់ជាឥណទានបាត់បង់ត្រូវបានអនុវត្ត។ | |
| **៥. បាត់បង់ (Loss)**<br>-ទ្រព្យសកម្មទាំងឡាយណា ដែលត្រូវបានចាត់ទុកថាមិនអាចប្រមូលមកវិញបាន ឬនៅមានតម្លៃតិចតួច ត្រូវចាត់ថ្នាក់ជាបំណុលបាត់បង់។ ការខាតបង់ ត្រូវទទួលស្គាល់ ក្នុងកំឡុងពេលដែលឥណទានទាំងនោះ ត្រូវបានរកឃើញថាមិនអាចប្រមូលបាន។ | -ឥណទានដែលហួសកាលកំណត់សង ចំនួន ៣៦០ថ្ងៃ ឬលើសពីនេះ ត្រូវចាត់ថ្នាក់យ៉ាងទាបបំផុតជាឥណទានបាត់បង់។<br>-នៅពេលដែល ការទូទាត់សង ការប្រាក់សម្រាប់រយៈពេលពី៣៦០ថ្ងៃ ឬលើសពីនេះ ត្រូវបានបញ្ចូល ជាប្រាក់ដើម ធ្វើបុនហិរញ្ញប្បទាន ឬបង្វិលជាឥណទានថ្មី (Rolled over loans) ឥណទាននេះ ត្រូវចាត់ថ្នាក់ជាឥណទានបាត់បង់។ |

- **ឥណទានរៀបចំឡើងវិញ (Restructured Loans)**
  - ការរៀបចំឥណទានឡើងវិញ អាចត្រូវបានធ្វើចំពោះតែអ្នកខ្ចីណា ដែលមានដំណើរការអាជីវកម្មល្អនាពេលខាងមុខ ហើយដែលកំពុងជួប ឬរំពឹងថានឹងជួបការលំបាកជាបណ្តោះអាសន្នក្នុងការសងត្រឡប់មកវិញនូវប្រាក់ដើម និង/ឬ ការប្រាក់។
  - ត្រូវបានហាមឃាត់ចំពោះការអនុវត្តរៀបចំឥណទានឡើងវិញ ដោយគ្រាន់តែក្នុងគោលបំណងជៀសវាង៖
    - ការធ្លាក់ចំណាត់ថ្នាក់របស់ខ្លួនព្រោះតែចំណាត់ថ្នាក់ឥណទាន ឬ
    - ការកើនឡើងនូវសំវិធានធនលើឥណទានបាត់បង់ ឬ
    - បឈ្សប់ការទទួលស្គាល់ចំណូលការប្រាក់លើមូលដ្ឋានបង្គរ។

- ឥណទានដែលនឹងត្រូវរៀបចំឡើងវិញ ត្រូវវិភាគលើមូលដ្ឋានទិសដៅអាជីវកម្ម និងសមត្ថភាពសងប្រាក់ត្រឡប់វិញរបស់អ្នកខ្ចី តាមការព្យាករណ៍លំហូរសាច់ប្រាក់ថ្មី ដែលស្របតាមស្ថានភាពទីផ្សារ និងបច្ចុប្បន្នកម្មនៃទស្សនៈវិស័យអាជីវកម្ម ដោយផ្អែកលើសម្មតិកម្មជាក់ស្តែង និងប្រុងប្រយ័ត្ន។
- ការរៀបចំឥណទានឡើងវិញ ត្រូវធ្វើឡើងដោយក្រុមការងារឯករាជ្យមួយ ដាច់ដោយឡែកពីសាខាដែលពាក់ព័ន្ធនឹងការផ្តល់ឥណទាន។
- បន្ទាប់ពីឥណទានបានរៀបចំឡើងវិញ ធនាគារត្រូវធ្វើចំណាត់ថ្នាក់ឥណទាននោះដូចខាងក្រោម៖
  - មិនល្អជាងក្រោមស្តង់ដារ សម្រាប់ឥណទានដែលពីមុនត្រូវបានចាត់ថ្នាក់ជាសង្ស័យ ឬបាត់បង់
  - មិនផ្លាស់ប្តូរ សម្រាប់ឥណទានដែលពីមុនមក ត្រូវបានចាត់ថ្នាក់ជាឥណទានធម្មតា ឃ្លាំមើល ឬក្រោមស្តង់ដារ។

ការធ្វើចំណាត់ថ្នាក់នេះ មិនត្រូវឱ្យល្អជាងមុនឡើយ លុះត្រាតែការប្រាក់ និងប្រាក់ដើមត្រូវបានសងមកវិញក្នុងអំឡុងបីគ្រាសងរំលស់ និងក្នុងរយៈពេលមិនតិចជាងបីខែ។ បន្ទាប់ពីរយៈពេលនេះ ឥណទានដែលត្រូវបានរៀបចំឡើងវិញ អាចត្រូវបានចាត់ថ្នាក់ទៅតាមប្រភេទចំណាត់ថ្នាក់ឥណទាន។

ការរៀបចំឯកសារសម្រាប់ឥណទានមាន៖

១. លិខិតសំណើសុំពីអតិថិជន

២. ទម្រង់ពាក្យស្នើសុំខ្ចីឥណទានដែលបានបំពេញរួចរាល់

៣. កំណត់ហេតុវាយតម្លៃទ្រព្យធានា ក្នុងករណីការផ្លាស់ប្តូរអ្នកធានា និង/ឬ អាសយដ្ឋាន

៤. របាយការណ៍ការិយាល័យឥណទានកម្ពុជាដែលបានធ្វើបច្ចុប្បន្នកម្ម

៥. របាយការណ៍ធនាគារសម្រាប់រយៈពេល ១២ខែចុងក្រោយ

៦. ឯកសារភស្តុតាងពីកំរៃសេវា (Fresh Charge Documents)។

### ៣.១០.២.ការធ្វើសំវិធានធន

ធនាគារត្រូវរក្សាសំវិធានធនសម្រាប់ឥណទានបាត់បង់ឱ្យបានគ្រប់គ្រាន់ ដើម្បីទូទាត់ការខាតបង់ក្នុងសម្ពៀតឥណទានដែលអាចកើតឡើង។

សំវិធានធនមានពីរប្រភេទគឺ សំវិធានធនទូទៅ និងសំវិធានធនជាក់លាក់។

**សំវិធានធនសរុប = សំវិធានធនទូទៅ + សំវិធានធនជាក់លាក់**

➢ សំវិធានធនទូទៅ (General Provision)

– សម្រាប់ឥណទានថ្នាក់ "ធម្មតា" (Normal) : ១% នៃឥណទានដុល។

➢ សំវិធានធនជាក់លាក់ (Specific Provision)

– សម្រាប់ឥណទានថ្នាក់ "ឃ្លាំមើល" (Special Mention) : ៣% នៃឥណទានដុល

– សម្រាប់ឥណទានថ្នាក់ "ក្រោមស្តង់ដារ" (Sub-Standard) : ២០% នៃឥណទានដុល

– សម្រាប់ឥណទានថ្នាក់ "សង្ស័យ" (Doubtful) : ៥០% នៃឥណទានដុល

– សម្រាប់ឥណទានថ្នាក់ "បាត់បង់" (Loss) : ១០០% នៃឥណទានដុល។

ធនាគារត្រូវរក្សាការកត់ត្រាឱ្យបានត្រឹមត្រូវ ដើម្បីជាការគាំទ្រដល់ការវាយតម្លៃឥណទានដែលអាចបាត់បង់ និងធ្វើសំវិធានធនឱ្យបានគ្រប់គ្រាន់សម្រាប់ឥណទានបាត់បង់។

សំវិធានធនជាក់លាក់ ត្រូវកត់ត្រានៅក្នុងគណនីរបស់ធនាគារ ហើយចាត់ទុកជាចំណាយនៅក្នុងរបាយការណ៍ចំណេញ-ខាត នៅក្នុងគ្រាដែលត្រូវធ្វើសំវិធានធននោះ។ សំវិធានធនមិនត្រូវធ្វើរំលស់នៅតាមគ្រានោះទេ។ នៅពេលដែលសមតុល្យគណនីរបស់អតិថិជនមានបញ្ចូលមូលធនកម្មការប្រាក់ (Capitalized Interest) ដែលបានកត់ត្រា បដិភាគជាមួយការប្រាក់ព្យួរទុក មូលធនកម្មការប្រាក់នេះ មិនត្រូវយកមកគិតសម្រាប់គណនីសំវិធានធនទេ។

## ៣.១១.វិធីសាស្ត្រដោះស្រាយឥណទានមានបញ្ហា

មានឧបករណ៍ដែលជាមធ្យោបាយក្នុងការដោះស្រាយបំណុលជាច្រើន ដែលធនាគារបានប្រើប្រាស់ក្នុងការប្រមូលបំណុលដែលយឺតយ៉ាវ។ ការប្រើប្រាស់ឧបករណ៍មធ្យោបាយទាំងនោះមានលក្ខណៈខុសប្លែកគ្នា អាស្រ័យតាមកម្រិតនៃការខកខានសងប្រាក់ ឬអាកប្បកិរិយារបស់អតិថិជន។ ជាទូទៅ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ប្រើប្រាស់ឧបករណ៍មធ្យោបាយសំខាន់ៗក្នុងការដោះស្រាយបំណុល ដែលឧបករណ៍ទាំងនោះមានដូចតទៅ៖

- លិខិតកើនរំលឹកឱ្យសងប្រាក់
- ការទាក់ទងអតិថិជនខកខានសងប្រាក់តាមរយៈការហៅទូរស័ព្ទ
- ការផ្ញើសារតាមទូរស័ព្ទ
- ជំនួយតាមរយៈអន្តរការី
- ការចុះដល់ទីកន្លែងតែឯង/ជាក្រុម
- ការជ្រើសតាំងភ្នាក់ងារដោះស្រាយបំណុលខាងក្រៅ
- លិខិតជូនដំណឹងស្តីពីការបង់ផ្តាច់ឥណទាន
- លិខិតជូនដំណឹងតាមផ្លូវច្បាប់ចំពោះអ្នកខ្ចី និងអ្នកធានា

- ការរាយការណ៍ទៅកាន់ការិយាល័យឥណទានកម្ពុជា
- វិធានការផ្លូវច្បាប់ និងការគ្រប់គ្រងទ្រព្យដាក់បញ្ចាំ
- ការលុបបំណុលចេញពីបញ្ជី និងការដោះស្រាយ។

### ៣.១១.១.ផែនការសកម្មភាពដោះស្រាយបំណុល

ការដោះស្រាយបំណុលត្រូវអនុវត្តនូវផែនការសកម្មភាពដូចខាងក្រោម តាមលក្ខណៈទៀងទាត់។ ការអនុវត្តដែលខុសពីទម្រង់ខាងក្រោមនេះ មិនត្រូវបានអនុញ្ញាតឡើយ លុះត្រាតែការអនុវត្តប្រាសចាកនោះ ត្រូវបានអនុម័តដោយប្រធានភ្នាក់ងារឥណទាន ឬនាយកសាខា និងនាយកប្រតិបត្តិឥណទាន ប្រធានផ្នែកត្រួតពិនិត្យឥណទាន/ប្រធាននាយកប្រតិបត្តិ នៅលំដាប់ការិយាល័យកណ្តាល។

**តារាងទី ៣.៥ ៖ ផែនការសកម្មភាពដោះស្រាយបំណុល**

| ថ្ងៃខកខានសងប្រាក់ | ជំហាននៃការដោះស្រាយបំណុលសម្រាប់ឥណទានគ្មានទ្រព្យដាក់ធានា/ឥណទានវិបារូបរ៍ | សកម្មភាពតាមប្រតិទិន | ឥណទានដែលមានទ្រព្យដាក់ធានា |
|---|---|---|---|
| ពី ១-២៩ ថ្ងៃ | ការហៅទូរស័ព្ទដោយប្រើប្រាស់វាចារល្អៗ/ការផ្ញើសារ | គ្រប់ថ្ងៃក្នុងខែ | លិខិតក្រើនរំលឹកលើកទីមួយ |
| | ការក្រើនរំលឹកលើកទីមួយ (លិខិត/សារ/ការហៅទូរស័ព្ទ។ល។) ការចុះជួបផ្ទាល់តែម្នាក់ឯងអាចធ្វើឡើង (ច្រើនបំផុត២ដង) | ការខកខានសងប្រាក់ពី ១-២៩ ថ្ងៃ | |
| ពី ៣០-៥៩ ថ្ងៃ | ការហៅទូរស័ព្ទ | គ្រប់ថ្ងៃក្នុងខែ | លិខិតក្រើនរំលឹកលើកទីពីរ |
| | លិខិតក្រើនរំលឹកលើកទីពីរ | ការខកខានសងប្រាក់ពី ៣០-៥៩ ថ្ងៃ | |
| | ការចុះជួបផ្ទាល់តែម្នាក់ឯង ដោយភ្នាក់ងារដោយស្រាយបំណុល | ពេលដែលត្រូវការ | |
| | ការហៅទូរស័ព្ទទៅកាន់សាក្សី/អ្នកធានាបំណុល ដើម្បីឱ្យពួកគាត់ជួយ | ពេលដែលត្រូវការ | |
| ពី ៦០-៨៩ ថ្ងៃ | លិខិតក្រើនរំលឹកលើកចុងក្រោយ | ការខកខានសងប្រាក់ពី ៦០-៨៩ ថ្ងៃ | លិខិតក្រើនរំលឹកលើកចុងក្រោយ ឱ្យធ្វើការទូទាត់ឥណ |
| | បន្តការចុះជួបផ្ទាល់/ចុះជាក្រុម | ពេលដែលត្រូវការ | |

| | | | |
|---|---|---|---|
| | ចាត់ចែងភ្នាក់ងារដោះស្រាយបំណុលឱ្យទទួលខុសត្រូវលើឥណទានដែលមានសញ្ញាព្រមានដំបូង | ពេលដែលត្រូវការ | ទាន ដោយទ្រព្យដាក់បញ្ចាំ |
| ពី ៩០-១១៩ ថ្ងៃ | លិខិតសុំជំនួយពីនយោជិក (ប្រសិនបើមាន) | ពេលដែលត្រូវការ | ជម្រុញនូវការសងប្រាក់ ដោយទ្រព្យដែលបានដាក់បញ្ចាំ |
| | លិខិតស្តីពីការតម្រូវ ឱ្យសងត្រឡប់នូវសមតុល្យឥណទានទាំងអស់ | ពេលដែលត្រូវការ | |
| | ការទូទាត់ឥណទាន ដោយសមតុល្យសាច់ប្រាក់សន្សំ (ប្រសិនបើមាន) និងអនុវត្តនូវសិទ្ធិទូទៅ ស្តីពីការទូទាត់ឥណទានដែលនៅជំពាក់ ដោយទ្រព្យសម្បត្តិ សមតុល្យប្រាក់សន្សំ ឬគណនីត្រូវទទួលផ្សេងៗទៀត របស់អតិថិជន។ | ពេលដែលត្រូវការ | |
| | ការហៅទូរស័ព្ទដោយប្រើប្រាស់វាចារគត់មត់ | គ្រប់ថ្ងៃក្នុងខែ | |
| | ការចុះជួបផ្ទាល់តែម្នាក់ឯង/ដោយក្រុមនៅការិយាល័យ/ទីតាំងអាជីវកម្ម និងលំនៅដ្ឋាន | ពេលដែលត្រូវការ | |
| | ចាត់ចែងភ្នាក់ងារដោះស្រាយបំណុលជាមួយនឹងការអនុម័តផ្តល់សិទ្ធិ | ពេលដែលត្រូវការ | |
| ពី ១២០-៣៥៩ ថ្ងៃ | ការហៅទូរស័ព្ទដោយប្រើប្រាស់វាចារគត់មត់ | គ្រប់ថ្ងៃក្នុងខែ | ការខកខានសងប្រាក់ពី ១២០-៣៥៩ ថ្ងៃ |
| | ការចុះជួបផ្ទាល់តែម្នាក់ឯង/ដោយក្រុម | ពេលដែលត្រូវការ | |
| | ដំណើរការពាក្យបណ្តឹងទៅតុលាការ (តាមករណីដែលបានកើតឡើងជាក់ស្តែង) | ការខកខានសងប្រាក់ពី ១២០ ថ្ងៃឡើងទៅ | |
| | ការរៀបចំពាក្យបណ្តឹងតាមផ្លូវតុលាការ (តាមករណីដែលបានកើតឡើងជាក់ | ពេលដែលត្រូវការ | |

| | | | |
|---|---|---|---|
| | ស្តែង) | | |
| ពី ៣៦០ ថ្ងៃ រហូតដល់ បំណុលលុប ចេញពីបញ្ជី | ការដំណើរការពាក្យបណ្តឹងទៅតុលាការ | គ្រប់ពេលក្នុងដំណាក់កាលនេះ | ការខកខានសង ប្រាក់ពី ៣៦០ ថ្ងៃ រហូតដល់បំណុល លុបចេញពីបញ្ជី |
| | ឱ្យប៉ូលីសឃាត់ខ្លួនអតិថិជនដែលឃើត យ៉ាវ ប្រសិនបើមានដីការឃាត់ខ្លួន | ករណីអាចអនុវត្តបាន | |
| | ក្នុងពេលជាមួយគ្នា ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ/ដំណោះស្រាយបញ្ហាតាមមធ្យោបាយផ្សេងទៀត ក៏ត្រូវធ្វើដំណាលគ្នាដែរ។ សកម្មភាពរបស់ភ្នាក់ងារដោះស្រាយបំណុល និងភ្នាក់ងារដោះស្រាយបំណុលខាងក្រៅ ក៏ត្រូវបន្តធ្វើផងដែរ។ | បន្តដំណើរការ | |
| បំណុលលុប ចេញពីបញ្ជី | ក្នុងពេលជាមួយគ្នា ដំណោះស្រាយក្រៅប្រព័ន្ធតុលាការ/ដំណោះស្រាយបញ្ហាតាមមធ្យោបាយផ្សេងទៀត ក៏ត្រូវធ្វើដំណាលគ្នា។ សកម្មភាពរបស់ភ្នាក់ងារដោះស្រាយបំណុល និងភ្នាក់ងារដោះស្រាយបំណុលខាងក្រៅ ក៏ត្រូវធ្វើផងដែរ។ ក្នុងករណីបំណុលលុបចេញពីបញ្ជីទាមទារឱ្យ ទាក់ទងជាមួយអតិថិជននោះ តាមរយៈទំនាក់ទនងល្អជាមួយអ្នកជិតខាង ឬសាច់ញាតិរបស់អតិថិជននោះ ឬតាមរយៈមធ្យោបាយណាក៏ដោយ ចូរធ្វើឱ្យប្រាកដថា គណនីបំណុលលុបចេញពីបញ្ជីនេះ មិនត្រូវបានព្រងើយកន្តើយឡើយ។ | បន្តដំណើរការ | បំណុលលុបចេញពីបញ្ជី |

### ៣.១១.២.ដោះស្រាយតាមប្រព័ន្ធតុលាការ

ការដោះស្រាយបំណុលអាក្រក់ តាមរយៈប្រព័ន្ធតុលាការ គឺជាដំណាក់កាលចុងក្រោយសម្រាប់ធនាគារ ដែលដំណោះស្រាយផ្សេងៗមិនទទួលបានលទ្ធផល។ ក្នុងករណីខ្លះ ប្រសិនបើរកឃើញថា អតិថិជនខកខានសងប្រាក់ណាមួយ ដែលមានលទ្ធភាពសងប្រាក់ ប៉ុន្តែមិនមានឆន្ទៈក្នុងការសងត្រឡប់ នោះការរៀបចំឥណទានឡើងវិញនឹងត្រូវបានពិចារណា។

មាននីតិវិធីខាងផ្លូវច្បាប់ផ្សេងៗគ្នា ពីដំណាក់កាលមួយទៅដំណាក់កាលមួយ ដែលទាមទារឱ្យចំណាយទាំងពេលវេលា និងថវិការ។ ដូច្នេះ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ត្រូវតែពិចារណាពីចំណាយ ដោយប្រៀបធៀបជាមួយនឹងលទ្ធផលទទួលពីប្រព័ន្ធតុលាការ មុននឹងធ្វើការរៀបចំសំណុំរឿងក្តី ប្តឹងអតិថិជនខកខានសងប្រាក់របស់ខ្លួន។ ថ្នាក់គ្រប់គ្រងរបស់ធនាគារ ត្រូវតែត្រួតពិនិត្យ និងព្យាករណ៍ពីលទ្ធភាពវិជ្ជមានដែលទទួលបានពីអតិថិជនយឺតយ៉ាវនោះ ពិចារណាពីទ្រព្យសម្បត្តិដែលបានដាក់ធានាបំណុល ទ្រព្យសម្បត្តិដទៃទៀត និងចំណូលរបស់កូនបំណុលនោះ។

ចំពោះដំណោះស្រាយតាមរយៈប្រព័ន្ធតុលាការ ធនាគារមានជម្រើសពីរ ក្នុងការប្តឹងកូនបំណុលទៅកាន់តុលាការដូចខាងក្រោម៖

- **តាមរយៈមេធាវីខាងក្នុងរបស់ធនាគារ៖** ប្រសិនបើមានពាក្យបណ្តឹងទៅកាន់តុលាការ សាខាត្រូវតែរៀបចំនូវសំណើទៅកាន់ការិយាល័យកណ្តាល ដើម្បីស្នើសុំការអនុម័ត។ ពាក្យបណ្តឹងនេះត្រូវតែធ្វើឡើងដោយនាយកដ្ឋាននីតិកម្ម និងមេធាវីខាងក្នុងរបស់ធនាគារ គឺជាបុគ្គលតែម្នាក់គត់ ដែលតំណាងធនាគារក្នុងការប្តឹងអតិថិជន។ មេធាវីរបស់ធនាគារ ត្រូវតែតាមដាននូវរឿងក្តីនីមួយៗនៅតុលាការ ចាប់ពីតុលាការដំបូង រហូតដល់តុលាការកំពូល និងត្រូវតែធ្វើបច្ចុប្បន្នកម្មរឿងក្តីទាំងនេះចំពោះសាខាតាមមូលដ្ឋានប្រចាំថ្ងៃ។
- **តាមរយៈមេធាវីខាងក្រៅ (ក្រុមហ៊ុនឯកជន)៖** ជម្រើសផ្សេងទៀតគឺ សាខាអាចទាក់ទងជាមួយនឹងមេធាវីខាងក្រៅ ក្នុងរង្វង់តំបន់ប្រតិបត្តិការរបស់ខ្លួន ប៉ុន្តែការអនុញ្ញាតក្នុងការប្រើប្រាស់មេធាវីខាងក្រៅ ត្រូវតែទទួលបានការអនុញ្ញាតពីនាយកដ្ឋាននីតិកម្មនៃការិយាល័យកណ្តាលជាមុនសិន។ ដើម្បីធ្វើដូច្នេះបាន សាខាអាចស្នើសុំឱ្យមេធាវីក្នុងតំបន់ ទៅកាន់នាយកដ្ឋាននីតិកម្ម ដើម្បីដាក់គាត់ចូលក្នុងបញ្ជីមេធាវីរបស់ធនាគារ។ នាយកដ្ឋាននីតិកម្ម នឹងធ្វើការត្រួតពិនិត្យលើការអនុវត្តរបស់មេធាវីនោះ តាមមូលដ្ឋានប្រចាំត្រីមាសនិងបម្រុងនៃសំណុំរឿងក្តី គឺអាស្រ័យតាមការកំណត់កម្រិត និងការអនុវត្តរបស់មេធាវី។ សាខាត្រូវតែពិនិត្យនូវរឿងក្តីនីមួយៗ ដែលប្តឹងទៅតុលាការ ចាប់ពីតុលាការដំបូង រហូតដល់តុលាការកំពូល និងត្រូវជម្រាបជូននាយកដ្ឋាននីតិកម្ម អំពីការវិវឌ្ឍន៍របស់

រឿងក្តី តាមមូលដ្ឋានប្រចាំខែ។ ការប្រើប្រាស់មេធាវីខាងក្រៅ សាខាត្រូវតែធ្វើឱ្យប្រាកដថា មេធាវីនោះគឺកាន់តែរឿងក្តីរបស់ធនាគារតែប៉ុណ្ណោះ ហើយមិនកាន់រឿងក្តីរបស់អតិថិជននោះឡើយ។

ការដោះស្រាយដំបូង ត្រូវតែធ្វើនៅតុលាការដំបូង ឬតុលាការថ្នាក់ខេត្ត/រាជធានី និងប្រសិនលើភាគីណាមួយមិនសុខចិត្តនឹងលទ្ធផលនៃការកាត់ក្តីទេ ភាគីនោះអាចបន្តរឿងក្តីដដែលនេះទៅកាន់តុលាការឧទ្ធរណ៍ និងអាចបន្តរហូតដល់តុលាការកំពូលផងដែរ។

**៣.១១.២.១.ដំណាក់កាលដោះស្រាយនៅសាលាដំបូង ឬតុលាការខេត្ត/រាជធានី**

នេះគឺជាដំណាក់កាលដំបូងនៃការដោះស្រាយតាមផ្លូវតុលាការ។ ធនាគារ ឬសាខា ត្រូវពិនិត្យឡើងវិញពីភាពត្រឹមត្រូវ ភាពច្បាស់លាស់ សុពលភាពនៃឯកសារឥណទាន និងឯកសារដែលពាក់ព័ន្ធផ្សេងៗទៀត និងរៀបចំសំណើសុំសម្រាប់ការអនុម័តដោយថ្នាក់មានសមត្ថកិច្ចរបស់ធនាគារ ដើម្បីរៀបចំពាក្យបណ្តឹង។ សំណើទាំងអស់ត្រូវភ្ជាប់មកជាមួយនឹងព័ត៌មានស្តីពីការចំណាយដែលពាក់ព័ន្ធទាំងអស់ រួមជាមួយនឹងព័ត៌មានទាំងឡាយស្តីពីទ្រព្យសម្បត្តិរបស់អតិថិជន។ ប្រវត្តិនៃការដោះស្រាយបំណុលលើកមុនៗ ត្រូវតែភ្ជាប់មកជាមួយផងដែរ។ សាខាអាចស្នើសុំឱ្យធ្វើជាដើមបណ្តឹង ដោយចាត់តាំងអ្នកតំណាងដែលមានការយល់ដឹងផ្លូវច្បាប់ច្បាស់លាស់ មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានពេលវេលាគ្រប់គ្រាន់សម្រាប់ទទួលការអញ្ជើញរបស់តុលាការឱ្យចូលមកបំភ្លឺ ឬក៏សាកសួរទៅតាមនីតិវិធីសម្រាប់ចេញសាលក្រម។ ជាជម្រើស សាខាអាចស្នើសុំឱ្យមេធាវីធនាគារជាតំណាងភាគីដើមបណ្តឹង។ ដើមបណ្តឹង ជាចាំបាច់ ត្រូវស្គាល់ស្ថានភាពរបស់អតិថិជនឱ្យបានច្បាស់លាស់ រួមទាំងប្រវត្តិនៃការដោះស្រាយបំណុលរបស់អតិថិជនផងដែរ។

មុននឹងចេញសាលក្រមសម្រេចរបស់តុលាការ គឺមាន ២ដំណាក់កាល។ ដំណាក់កាលទាំងពីររួមមានដូចខាងក្រោម៖

- **ដំណាក់កាលត្រៀមទាញហេតុផល**

នីតិវិធីរបស់តុលាការ ដើម្បីបញ្ជាក់ពីការទទួលខុសត្រូវរបស់តុលាការ គេត្រូវប្រមូល និងរៀបចំនូវសេចក្តីអះអាង ភស្តុតាងទាំងអស់របស់ភាគីគូវិវាទ។ នេះជាដំណាក់កាលសំខាន់មួយដែលធនាគារត្រូវតែប្រមូលឯកសារដែលជាភស្តុតាងបញ្ជាក់ពីការខ្ចីប្រាក់ វត្ថុបញ្ចាំ កិច្ចសន្យាបន្ថែមទៀតរបស់អតិថិជន ដែលជាការអះអាងពីអតិថិជនដោយស្ម័គ្រចិត្តលើការសង ប៉ុន្តែមិនបានអនុវត្តតាមការសន្យារបស់ខ្លួន។ គ្រប់ឯកសារដែលបានដាក់ជូនតុលាការនាពេលនេះ ត្រូវធានាលើភាពត្រឹមត្រូវ ច្បាស់លាស់ គ្រប់គ្រាន់ គ្មានការកោសលប់ ការសរសេរបន្ថែម ពោលគឺមានសុពលភាពពេញលេញ ដូច្នេះត្រូវ៖

- ត្រួតពិនិត្យឯកសារតណទានឡើងវិញឱ្យបានហ្មត់ចត់ ត្រូវប្រឹក្សាយោបល់ជាមួយមេធាវី និងក្រុមកិច្ចការច្បាប់របស់ធនាគារ មុនបញ្ជូនទៅតុលាការ
- ចាត់ចែងឱ្យមានអ្នកទទួលខុសត្រូវលើការតាមដានស្ថានភាពរឿងក្តី
- ការដាក់ឯកសារភស្តុតាងត្រូវអនុលោមតាមនីតិវិធី និងការណែនាំរបស់ក្រុមការងាររបស់តុលាការ។

➢ **ការទាញហេតុផលដោយផ្ទាល់មាត់**

ក្រោយពីការពិនិត្យលើឯកសារភស្តុតាង និងការអះអាងជាបឋមដែលបានមកពីដំណាក់កាលត្រៀមទាញហេតុផល តុលាការត្រូវកោះហៅគូវិវាទមកបំភ្លឺចំពោះមុខតុលាការទៅតាមកាលបរិច្ឆេទច្បាស់លាស់មួយ។ ការទាញហេតុផលដោយផ្ទាល់មាត់ គឺត្រូវធ្វើឡើងនៅសាលសវនការជាសាធារណៈ ក្នុងករណីដែលពិនិត្យឃើញថា អាចប៉ះពាល់ខូចសណ្តាប់ធ្នាប់ ឬក៏ខុសច្បាប់ ការទាញហេតុផលដោយផ្ទាល់មាត់អាចពិនិត្យលើលទ្ធភាពធ្វើជាអសាធារណៈ។

ស្ថិតក្នុងដំណាក់កាលនេះ គូវិវាទអាចធ្វើការអះអាងលម្អិត ការបង្ហាញភស្តុតាងថ្មីៗ ដើម្បីបន្ថែមទម្ងន់បន្ទុក ក្រឡាបញ្ជីមាននាទីធ្វើកំណត់ហេតុស្តីពីការទាញហេតុផលដោយផ្ទាល់មាត់។ ការទាញហេតុផលដោយផ្ទាល់មាត់ អាចធ្វើឡើងជាច្រើនដង ក្នុងករណីដែលតុលាការពិនិត្យឃើញថា សំណុំរឿងមានភាពស្មុគស្មាញខ្លាំង តុលាការអាចបង្វិលទៅនីតិវិធីត្រៀមទាញហេតុផលឡើងវិញម្តងទៀត។

➢ **ការចេញសាលក្រម**

ការសម្រេចរបស់តុលាការទៅតាមការទាមទាររបស់គូភាគី ដោយផ្អែកលើភស្តុតាង ការអះអាង កំណត់ហេតុ ដែលទទួលបានមកពីការត្រៀមហេតុផល និងការទាញហេតុផលដោយផ្ទាល់មាត់។ ប្រសិនបើគូភាគីណាមួយមិនសុខចិត្ត ឬមិនយល់ព្រមអនុវត្តទៅតាមខ្លឹមសារនានាដែលចែងក្នុងសាលក្រមនោះ ភាគីដែលជំទាស់មានរយៈពេល១ខែ ឬ៣០ថ្ងៃ ក្រោយពេលចេញសាលក្រមសម្រាប់ធ្វើការប្តឹងឧទ្ធរណ៍បាន ដោយធ្វើលិខិតស្នើសុំប្តឹងឧទ្ធរណ៍ តាមរយៈតុលាការដំបូងដែលបានចេញសាលក្រមនេះតែម្តង។

តុលាការដំបូងបានទទួលលិខិតស្នើសុំប្តឹងឧទ្ធរណ៍ពីភាគីជំទាស់នេះរួច ត្រូវបញ្ជូនសុំណុំរឿង និងឯកសារ ភស្តុតាងនានាដែលពាក់ព័ន្ធទាំងអស់ទៅសាលាឧទ្ធរណ៍ជាការស្រេច។

**៣.១១.២.២.ដំណាក់កាលដោះស្រាយនៅសាលាឧទ្ធរណ៍**

សាលាឧទ្ធរណ៍ ជាតុលាការលំដាប់ធំទី២ បន្ទាប់ពីតុលាការដំបូង។ តុលាការនេះ មានភារៈសើរើ និងចេញសេចក្តីសម្រេចទៅតាមឆន្ទៈច្បាប់។ សេចក្តីសម្រេចនេះ អាចមានខ្លឹមសារស្របតាម

សាលក្រមរបស់សាលាដំបូង ឬអាចជំទាស់ក៏ថាបាន។ ក្នុងករណី យល់ស្របតាមខ្លឹមសារនៃសាលក្រមរបស់សាលាដំបូង សាលាឧទ្ធរណ៍ប្រកាសសាលក្រមរបស់ខ្លួន និងបញ្ជាក់បន្ថែមអំពីគូភាគីបើកសិទ្ធិតវ៉ា ឬក៏បិទការតវ៉ា ក្នុងករណីបើកសិទ្ធិតវ៉ា ភាគីជំទាស់អាចដាក់បណ្ដឹងទៅតុលាការកំពូល ដោយមានរវេលាកំណត់យ៉ាងយូរ ១ខែ ឬ៣០ថ្ងៃ ក្នុងការដាក់សារណានៅតុលាការកំពូល។

កាលបរិច្ឆេទនៃការបើកសវនការជម្រះក្ដី គឺអាស្រ័យទៅតាមការសម្រេចរបស់សាលាឧទ្ធរណ៍ បន្ទាប់ពីបានទទួលសុំណុំឯកសារទាំងអស់ពីសាលាដំបូង អាចប្រើពេល ១ខែ រហូតដល់ ៥ខែ ឬ ១០ឆ្នាំ។ មុននឹងចេញសេចក្ដីសម្រេចរបស់ខ្លួន សាលាឧទ្ធរណ៍ត្រូវពិនិត្យឯកសារពាក់ព័ន្ធទាំងអស់ និងសាលក្រមរបស់សាលាដំបូង ដោយចាប់ផ្ដើមអនុវត្តការទាញយកហេតុផលផ្ទាល់មាត់តែម្ដង។

ប្រសិនសាលាឧទ្ធរណ៍យល់ឃើញថា មិនស្របតាមសេចក្ដីសម្រេចរបស់សាលាដំបូង ខ្លួនបង្គាប់ឱ្យសាលាដំបូងធ្វើការជម្រះសារជាថ្មីឡើងវិញ ដោយអនុវត្តតាមនីតិវិធីរបស់ខ្លួន គឺដំណាក់កាលត្រៀមទាញហេតុផលផ្ទាល់មាត់ និងការចេញសាលក្រមដដែល។

#### ៣.១១.២.៣.ដំណាក់កាលដោះស្រាយនៅតុលាការកំពូល

តុលាការកំពូល ជាតុលាការលំដាប់កំពូលបំផុតដែលមានភារៈត្រួតពិនិត្យ និងសើរើលើសេចក្ដីសម្រេចរបស់សាលាឧទ្ធរណ៍ ដោយមានបណ្ដឹងពីភាគីជំទាស់ និងការសម្រេចរបស់សាលាឧទ្ធរណ៍ ក្នុងរយៈពេល ៣០ថ្ងៃ ឬ១ខែ បន្ទាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេច។

ភាគីវិវាទត្រូវរៀបចំសារណាដាក់ចូលតុលាការកំពូល ឱ្យបានត្រឹមត្រូវ ច្បាស់លាស់ ដើម្បីទុកលទ្ធភាពឱ្យតុលាការកំពូលពិនិត្យ និងកំណត់ពេលជម្រះក្ដី នៅពេលវេលាណាមួយដែលតុលាការកំពូលនេះយល់ថាសមស្រប។ មុននឹងចេញសាលក្រមស្ថាពរ តុលាការកំពូលធ្វើការទាញយកហេតុផលផ្ទាល់មាត់មកធ្វើជាមូលដ្ឋានផលដែរ ថេរៈវេលានៃការដោះស្រាយ ឬអាចទទួលបាននូវសាលក្រមស្ថាពរ គឺអាចរហូតដល់១០ឆ្នាំ។

## ៣.១២.ការវាស់វែងគុណភាពឥណទាន

គុណភាពឥណទានត្រូវបានវាស់វែងដោយប្រើអត្រានៃហានិភ័យឥណទាន និងអត្រានៃការសងមកវិញនៃឥណទាន។

### ៣.១២.១.អត្រាហានិភ័យឥណទាន

ចំពោះហានិភ័យឥណទាន (Portfolio at Risk) ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោមៈ

**រូបមន្តទី ៣.២ ៖ ការគណនាអត្រាហានិភ័យ**

$$PAR\ (\%) = \frac{\text{សមតុល្យឥណទានដែលបានខកខានមិនបានសងតាមកិច្ចសន្យា (ប្រាក់ដើម)}}{\text{សមតុល្យឥណទានសរុប (ប្រាក់ដើម)}} \times ១០០$$

ដោយការកំណត់បទដ្ឋានហានិភ័យសម្រាប់វាយតម្លៃគុណភាពឥណទានដូចខាងក្រោម៖

- ០% ≤ PAR ≤ ១% ៖ ការអនុវត្តត្រូវបានចាត់ទុកថា ល្អណាស់
- ១% ≤ PAR ≤ ២% ៖ ការអនុវត្តត្រូវបានចាត់ទុកថា ល្អ
- ២% ≤ PAR ≤ ៥% ៖ ការអនុវត្តត្រូវបានចាត់ទុកថា មធ្យម
- ៥% ≤ PAR ៖ ការអនុវត្តត្រូវបានចាត់ទុកថាខ្សោយនិងត្រូវបានធ្វើការកែលម្អ។

### ៣.១២.២.អត្រានៃការសងត្រឡប់មកវិញនៃឥណទាន

ឥណទានដែលខកខានមិនបានសងតាមកិច្ចសន្យា ត្រូវបានវាស់វែងគុណភាពនៃការសងត្រឡប់មកវិញតាមអត្រាដូចបានគណនាដោយរូបមន្តដូចខាងក្រោម៖

**រូបមន្តទី ៣.៣ ៖ ការគណនាអត្រានៃការសងត្រលប់មកវិញ**

$$\text{អត្រានៃការសងត្រឡប់មកវិញ} = \frac{\text{សរុបទឹកប្រាក់ដែលត្រូវសងហើយបានសង}}{\text{សរុបទឹកប្រាក់ដែលត្រូវសង}} \times ១០០$$

### ៣.១២.៣.បំណុលលុបចេញពីបញ្ជី (Write-off)

បំណុលត្រូវបានលុបចេញពីបញ្ជីដោយស្វ័យប្រវត្តិ បន្ទាប់ពីបំណុលនោះបានផ្ទៀតផ្ទាត់លក្ខខណ្ឌ៖

- បំណុលដែលបានធ្វើសំវិធានធនជាក់លាក់ ១០០% (បំណុលបាត់បង់)
- បំណុលដែលយឺតយ៉ាវហួសរយៈពេល ៣៦០ថ្ងៃនៃកាលបរិច្ឆេទសងប្រាក់ចុងបញ្ចប់។

ទោះជាយ៉ាងណា បំណុលត្រូវបានលុបចេញពីបញ្ជី ក្រោមការវិនិច្ឆ័យរបស់គណៈកម្មាធិការឥណទានក្នុងករណីដែលធនាគារបាត់សិទ្ធិតាមកិច្ចសន្យាលើការគ្រប់គ្រងឥណទាន នៅពេលដែលរកឃើញថាឥណទានមួយផ្នែក ឬទាំងមូលមិនអាចប្រមូលវិញបាន ឬគ្មានសង្ឃឹមថាឥណទាននោះអាចប្រមូលបានមកវិញទេ។ ជាទូទៅ ករណីដូចខាងក្រោមជាសញ្ញាណអាចនាំទៅដល់ការលុបចោលនូវបំណុល៖

- ធនាគារបាត់សិទ្ធិតាមកិច្ចសន្យា ក្នុងការគ្រប់គ្រងឥណទានទាំងស្រុង ឬមួយផ្នែកដូចដែលបានសម្រេចតាមតុលាការ។
- គ្រប់ប្រភេទនៃទ្រព្យធានាដែលត្រូវបានរឹបអូស នឹងលក់បញ្ចេញ ប៉ុន្តែមិនគ្រប់គ្រាន់សម្រាប់ទូទាត់ឥណទានទាំងមូល។
- ធនាគារមិនអាចប្រមូល ឬលែងមានមូលហេតុសមស្របក្នុងការធានាបានថានឹងប្រមូលឥណទានគ្រប់ចំនួនដែលត្រូវទារ ស្របតាមលក្ខខណ្ឌនៃកិច្ចសន្យាឥណទាន និងបុរេប្រទាន។

- អ្នកខ្ចីប្រាក់បានក្ស័យធន ឬកំពុងស្ថិតនៅក្នុងដំណាក់កាលស្តារនីតិសម្បទានផ្នែកហិរញ្ញវត្ថុ និងកំពុងតែជួបការលំបាកក្នុងការសងបំណុល។

អត្រាបំណុលលុបចេញពីបញ្ជី (WOR) ត្រូវបានគណនាតាមរូបមន្តដូចខាងក្រោម៖

**រូបមន្តទី ៣.៤ ៖ ការគណនាអត្រាបំណុលលុបចេញពីបញ្ជី**

$$WOR\,(\%) = \frac{\text{សរុបបំណុលលុបចេញក្នុងគ្រា} - \text{ការប្រមូលបំណុលចេញពីបញ្ជីក្នុងគ្រា}}{\text{សមតុល្យមធ្យមនៃឥណទានក្នុងគ្រា}} \times ១០០$$

បទដ្ឋានហានិភ័យបំណុលលុបចេញពីបញ្ជី សម្រាប់វាយតម្លៃគុណភាពឥណទានដូចខាងក្រោម៖

- WOR = 0% ៖ ការអនុវត្តត្រូវបានចាត់ទុកថា ល្អណាស់
- 0% ≤ WOR ≤ 0.៥% ៖ ការអនុវត្តត្រូវបានចាត់ទុកថា ល្អ
- 0.៥% ≤ WOR ≤ ១% ៖ ការអនុវត្តត្រូវបានចាត់ទុកថា បង្គួរ
- ១% ≤ WOR ≤ ១.៥% ៖ ការអនុវត្តត្រូវបានចាត់ទុកថា មធ្យម
- ១.៥% ≤ WOR ≤ ២% ៖ ការអនុវត្តត្រូវបានចាត់ទុកថា ខ្សោយ ត្រូវមានការកែលម្អ
- ២% < WOR ៖ ការអនុវត្តត្រូវបានចាត់ទុកថា ខ្សោយ ត្រូវមានវិធានការជាបន្ទាន់។

## ៣.១៣.លទ្ធផលនៃការស្រាវជ្រាវ

### ៣.១៣.១.សមតុល្យសរុបរបស់ធនាគារប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ចាប់ពីឆ្នាំ ២០១៥ ដល់ ២០១៦

តារាងខាងក្រោមនេះ គឺជាទិន្នន័យដែលបង្ហាញពីការបញ្ចេញឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ចាប់ពីឆ្នាំ ២០១៥ រហូតដល់ឆ្នាំ ២០១៦។

**តារាងទី ៣.៦ ៖ ការបញ្ចេញឥណទានខ្នាតមធ្យមក្នុងឆ្នាំ ២០១៥-២០១៦**

| ២០១៥-២០១៦ | បរិមាណឥណទានខ្នាតមធ្យមដែលបានបញ្ចេញ (គិតជា$) | កំណើនសមតុល្យឥណទាន (គិតជា$) | កំណើនសមតុល្យឥណទាន (គិតជា%) |
|---|---|---|---|
| ត្រីមាសទី១ | ១,២២០,០០០ | - | - |
| ត្រីមាសទី២ | ១,៥៦០,០០០ | ៣៤០,០០០ | ២៧.៨៧% |
| ត្រីមាសទី៣ | ១,៧៧០,០០០ | ២១០,០០០ | ១៣.៤៦% |
| ត្រីមាសទី៤ | ១,៩៧០,០០០ | ២០០,០០០ | ១១.៣% |

| | | | |
|---|---|---|---|
| ត្រីមាសទី៥ | ២,៩២១,០០០ | ៩៥១,០០០ | ៤៨.២៧% |
| ត្រីមាសទី៦ | ៣,២០៩,០០០ | ២៨៨,០០០ | ៩.៨៥% |
| ត្រីមាសទី៧ | ៣,៥៦០,០០០ | ៣៥១,០០០ | ១០.៩៤% |
| ត្រីមាសទី៨ | ៤,០៧៤,០០០ | ៥១៤,០០០ | ១៤.៤៤% |

**ក្រាបទី ៣.១ ៖ ការបញ្ចេញឥណទានខ្នាតមធ្យមក្នុងឆ្នាំ ២០១៥-២០១៦**




**បកស្រាយ៖**

យោងតាមតារាងសមតុល្យឥណទាន និងក្រាបខាងលើនេះ យើងសង្កេតថា៖ ការបញ្ចេញឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក នៅក្នុងត្រីមាសទី១ នៃឆ្នាំ២០១៥ មានចំនួន ១,២២០,០០០ដុល្លារសហរដ្ឋអាមេរិក និងនៅក្នុងត្រីមាសទី២ មានចំនួន ១,៥៦០,០០០ដុល្លារសហរដ្ឋអាមរិក ដែលចំនួននេះមានការកើនឡើង ៣៤០,០០០ដុល្លារសហរដ្ឋអាមរិក ដែលស្មើនឹង ២៧.៨៧% បើធៀបនឹងត្រីមាសទី១។ ដោយឡែកយើងសង្កេតឃើញថា ពីត្រីមាសមួយទៅត្រីមាសមួយ ការបញ្ចេញឥណទានខ្នាតមធ្យមមានការកើនឡើងជាលំដាប់ ជាពិសេសគឺនៅត្រីមាសទី៤នៃឆ្នាំ២០១៥ ការបញ្ចេញឥណទានខ្នាតមធ្យមមានចំនួន ១,៩៧០,០០០ ដុល្លារសហរដ្ឋអាមរិក និងនៅក្នុងត្រីមាសទី៥ដែលជាដើមត្រីមាសនៃឆ្នាំ២០១៦ មានចំនួន ២,៩២១,០០០ដុល្លារសហរដ្ឋអាមរិក ដែលចំនួននេះដែរ បានកើនឡើងរហូតដល់ ៩៥១,០០០ ដុល្លារសហរដ្ឋអាមរិក គឺស្មើនឹង ៤៨.២៧% បើធៀបនឹងត្រីមាសទី៤នៃឆ្នាំ២០១៥។ ដូចគ្នានេះដែរ

ការបញ្ចេញឥណទានខ្នាតមធ្យមនៅតែបន្តកើនឡើង ដែលក្នុងនោះរហូតមកដល់ត្រីមាសទី៧ មានចំនួន ៣,៥៦០,០០០ដុល្លារសហរដ្ឋអាមេរិក និងត្រីមាសទី៨មានចំនួន ៤,០៧៤,០០០ដុល្លារសហរដ្ឋអាមេរិក ដែលកើនឡើងចំនួន ៥១៤,០០០ដុល្លារសហរដ្ឋអាមេរិក គឺស្មើនឹង ១៤.៤៤% បើធៀបនឹងត្រីមាសទី៧។

**តារាងទី ៣.៧ ៖ ចំនួនអតិថិជននៃឥណទានខ្នាតមធ្យមក្នុងឆ្នាំ ២០១៥-២០១៦**

| ២០១៥-២០១៦ | ចំនួនអតិថិជននៃឥណទានខ្នាតមធ្យម | កំណើនចំនួនអតិថិជន (គិតជានាក់) | កំណើនចំនួនអតិថិជន (គិតជា%) |
|---|---|---|---|
| ត្រីមាសទី១ | ១៧ | - | - |
| ត្រីមាសទី២ | ២២ | ៥ | ២៩.៤១% |
| ត្រីមាសទី៣ | ២៦ | ៤ | ១៨.១៨% |
| ត្រីមាសទី៤ | ៣០ | ៤ | ១៥.៣៨% |
| ត្រីមាសទី៥ | ៤១ | ១១ | ៣៦.៦៦% |
| ត្រីមាសទី៦ | ៤៦ | ៥ | ១២.១៩% |
| ត្រីមាសទី៧ | ៥០ | ៤ | ៨.៧% |
| ត្រីមាសទី៨ | ៥៥ | ៥ | ១០% |

**ក្រាបទី ៣.២ ៖ ចំនួនអតិថិជននៃឥណទានខ្នាតមធ្យមក្នុងឆ្នាំ ២០១៥-២០១៦**



**បកស្រាយ៖**

យោងតាមតារាងសមតុល្យឥណទាន និងក្រាបខាងលើនេះ យើងសង្កេតថា៖ ការបញ្ចេញឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក នៅក្នុងត្រីមាសទី១ មានអតិថិជនចំនួន ១៧នាក់ និងនៅក្នុងត្រីមាសទី២ មានចំនួន ២២នាក់ ដែលចំនួននេះមានការកើនឡើង ៥នាក់ ដែលស្មើនឹង ២៩.៤១% បើធៀបនឹងត្រីមាសទី១។ ដូចគ្នានឹងបរិមាណឥណទានដែលបានបញ្ចេញដែរ អតិថិជនដែលធនាគារបានបញ្ចេញឥណទានខ្នាតមធ្យមជូនមានការកើនឡើងជាលំដាប់ពីត្រីមាសមួយទៅត្រីមាសមួយ។ ដោយឡែក រហូតមកដល់ត្រីមាសទី៧ អតិថិជនមានចំនួន ៥០នាក់ និងត្រីមាសទី៨មានចំនួន ៥៥នាក់ ដែលកើនឡើងចំនួន ៥នាក់ គឺស្មើនឹង ១០% បើធៀបនឹងត្រីមាសទី៧។

សរុបសេចក្តីមក តាមរយៈបរិមាណឥណទានខ្នាតមធ្យមដែលបានបញ្ចេញ និងអតិថិជនដែលធនាគារបានបញ្ចេញឥណទានជូនមានការកើនឡើងពីត្រីមាសមួយទៅត្រីមាសមួយ បានបញ្ជាក់ឱ្យឃើញថា ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិកពិតជាមានភាពល្អប្រសើរ និងពិតជាទទួលបានភាពជឿជាក់ និងទាក់ទាញអតិថិជនបន្ថែមបានយ៉ាងគួរឱ្យកត់សម្គាល់។

### ៣.១៣.២.ឥណទានដែលបានលុបចេញពីបញ្ជីរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ចាប់ពីឆ្នាំ២០១៥ ដល់ ២០១៧

ចាប់តាំងពីការកកើតរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិកមក ធនាគារមិនធ្លាប់មានការលុបឥណទានចេញពីបញ្ជីឡើយ។ ក៏ប៉ុន្តែ នៅដើមឆ្នាំ២០១៧ នេះធនាគារបានជួបប្រទះនឹងបំណុលឃ្លាំចាំមើល ដែលមូលហេតុបណ្តាលមកពីដំណើរការអាជីវកម្មរបស់អតិថិជនមានបញ្ហា។ អតិថិជនបានខ្ចីប្រាក់ពីធនាគារចំនួន $៨០,០០០ ក្នុងរយៈពេល៦០ខែ ក្នុងនោះអតិថិជនបានធ្វើការទូទាត់ឥណទានបានរយៈពេល១២ខែ ដែលត្រូវនឹង $១៦,០០០។ ក្រោយពីអតិថិជនខកខានក្នុងការទូទាត់បំណុលជូនធនាគារចំនួន ២ខែមក ធនាគារបានធ្វើការស្វែងរកដំណោះស្រាយជូនអតិថិជន ដោយសិក្សាលើលទ្ធភាពសងបំណុលរបស់អតិថិជន ក្នុងករណីធនាគារអនុញ្ញាត្តិឱ្យអតិថិជនធ្វើការបង់ផ្តាច់ និងខ្ចីឥណទានបន្ថែម ហើយនិងការចរចារពីរបៀបសងប្រាក់។ ចំណែកឯការសងត្រលប់របស់អតិថិជន ពុំមានចោទជាបញ្ហានោះទេ ដោយសារតែអតិថិជនបានសងត្រលប់តាមកាលកំណត់ និងអាចមានការយឺតយ៉ាវខ្លះប៉ុន្តែក្នុងរយៈពេលខ្លីប៉ុណ្ណោះ។

### ៣.១៣.៣.ការវិភាគចំណុចខ្លាំង និងចំណុចខ្សោយ

ឆ្លងតាមការសិក្សាស្រាវជ្រាវ និងការចុះកម្មសិក្សាផ្ទាល់នៅធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក យើងខ្ញុំបានសង្កេតឃើញថា ធនាគារមានចំណុចខ្លាំង និងចំណុចខ្សោយដូចខាងក្រោមៈ

#### ៣.១៣.៣.១.ចំណុចខ្លាំង

- បុគ្គលិកមានភាពរួសរាយរាក់ទាក់ និងមានការគោរពចំពោះគ្នាទៅវិញទៅមក
- ធនាគារបានធ្វើការបន្ថែមប្រភេទផលិតផលឥណទាន ដើម្បីជួយសម្រួលតាមតម្រូវការរបស់អតិថិជន
- គោលការណ៍ និងនីតិវិធីក្នុងការផ្តល់ឥណទានរបស់ធនាគារមានលក្ខណៈច្បាស់លាស់
- មន្ត្រីឥណទានមានសមត្ថភាព និងបទពិសោធន៍ខ្ពស់ក្នុងការស្វែងរកអតិថិជន
- ធនាគារមានវិធីសាស្ត្រយ៉ាងត្រឹមត្រូវដើម្បីដោះស្រាយឥណទានមានបញ្ហា
- ហិរញ្ញវត្ថុរបស់ធនាគារ មានភាពរឹងមាំនៅក្នុងការផ្តល់ឥណទាន ទៅតាមតម្រូវការអតិថិជន
- ធនាគារមានសវនកម្មផ្ទៃក្នុង និងខាងក្រៅ ដើម្បីធានាភាពត្រឹមត្រូវលើការគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន។

#### ៣.១៣.៣.២.ចំណុចខ្សោយ

- នីតិវិធីនៃការផ្តល់ឥណទាន គឺភាគច្រើនមិនបានអនុវត្តទៅតាមដំណាក់កាលដែលបានចែងក្នុងគោលការណ៍
- សំនុំបែបបទនៃឯកសារក្នុងការស្នើសុំកម្ចីមានលក្ខណៈស្មុគស្មាញ។

# សេចក្តីសន្និដ្ឋាន និងការផ្តល់អនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ឆ្លងកាត់តាមការចុះកម្មសិក្សានៅធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ក្រោមប្រធានបទ "ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក" យើងខ្ញុំអាចធ្វើការសន្និដ្ឋានបានថា៖

ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ផ្តល់ជូននូវសេវាកម្ម និងផលិតផលហិរញ្ញវត្ថុជាច្រើនដើម្បីបំពេញតម្រូវការអតិថិជន។ ដើម្បីផ្តល់ភាពងាយស្រួលជូនអតិថិជន ធនាគារថែមទាំងបានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនជាច្រើនទៀតផងនៅតាមបណ្តាខេត្ត ក្រុងទូទាំងព្រះរាជាណាចក្រកម្ពុជា។ លើសពីនេះទៅទៀត ធនាគារបានចូលរួមចំណែកក្នុងការជួយដល់ប្រជាជនក្នុងស្រុកដើម្បីពង្រីកអាជីវកម្មរបស់ពួកគេ បង្កើនប្រាក់ចំណូល និងជីវភាពរស់នៅ ដោយបម្រើសេវាហិរញ្ញវត្ថុដែលមានតម្លៃសមរម្យ និងអាចជឿទុកចិត្តបាន។

រាល់សកម្មភាពរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក ពិតជាបានបង្ហាញពីគោលបំណងបម្រើដល់អតិថិជន ដែលមិនទាន់ទទួលបាននូវសេវាហិរញ្ញវត្ថុគ្រប់គ្រាន់ និងចូលរួមបង្កើតការរីកលូតលាស់ និងការអភិវឌ្ឍ នាពេលអនាគតរបស់ប្រទេសកម្ពុជា។ ជាក់ស្តែងរាល់ការបញ្ចេញឥណទាននីមួយៗ ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិកតែងតែប្រកាន់ខ្ជាប់នូវគោលការណ៍ផ្ទៃក្នុងរបស់អង្គភាពទាំងមូល ដោយឆ្លងកាត់ការត្រួតពិនិត្យ និងវាយតម្លៃលើភាពត្រឹមត្រូវលើឯកសារឥណទាន និងភាពជាក់ស្តែងរបស់អតិថិជន។ មួយវិញទៀត ធនាគារតែងតែធ្វើការបណ្តុះបណ្តាលមន្ត្រីឥណទានរបស់ខ្លួនលើ ក្រមសីលធម៌ និងវិជ្ជាជីវៈ ជាមួយនឹងទំនួលខុសត្រូវលើការងារ ដែលកាន់តែធ្វើឱ្យធនាគារអាចអនុវត្តនូវគោលនយោបាយឥណទានកាន់តែមានប្រសិទ្ធិភាពជាងមុន។ លើសពីនេះទៅទៀត ដើម្បីកាត់បន្ថយហានិភ័យឥណទាន និងសម្រេចគោលដៅក្នុងការលើកកម្ពស់ជីវភាពប្រជាជន ធនាគារតែងតែធ្វើការចុះជួបអតិថិជនដល់ទីកន្លែងដើម្បីតាមដានពីលទ្ធផលនៃការប្រើប្រាស់ឥណទានរបស់អតិថិជនខ្លួន និងដើម្បីចង់ដឹងពី ភាពប្រែប្រួលជីវភាពមុន និងក្រោយពេលទទួលបានឥណទានពីធនាគារ។ ជាលទ្ធផលដែលទទួលបាន ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក នៅក្នុងឆ្នាំ២០១៥ បានធ្វើការផ្តល់ឥណទានជូនអតិថិជនចំនួន ៥៨៥នាក់ ដែលស្មើនឹងឥណទានសរុបចំនួន ៩,០៩២,១៥៥ដុល្លារអាមេរិក ដែលនៅក្នុងនោះមានឥណទានខ្នាតមធ្យមចំនួន ១,៩៧០,០០០ដុល្លារអាមេរិក ស្មើនឹងចំនួនអតិថិជន ៣០នាក់ និងនៅក្នុងឆ្នាំ២០១៦ មានអតិថិជនសរុបចំនួន ៩៣៦នាក់ ដែលសមមូលនឹងទំហំឥណទានសរុបចំនួន ១៥,៨៨០,០០០ដុល្លារអាមេរិក ដែលក្នុងនោះមានឥណទានខ្នាតមធ្យមចំនួន ៥,០៧៥,០០០ ស្មើ

នឹងចំនួនអតិថិជន ៥៥នាក់ គឺមានការកើនឡើង ០.៨៣ដងច្រើនជាងឆ្នាំកន្លងទៅ ដោយសារតែអតិថិជនមានភាពជឿជាក់លើធនាគារ និងមានបំណងបន្ថែមដើមទុន ដើម្បីពង្រីកអាជីវកម្មរបស់ខ្លួន។

សរុបសេចក្តីមក ឥណទានពិតជាមានសារៈសំខាន់ណាស់ នៅក្នុងការផ្តល់ជាដើមទុនក្នុងការបង្កើតមុខរបរថ្មី និងពង្រីកអាជីវកម្មដែលមានស្រាប់ដើម្បីធ្វើឱ្យជីវភាពកាន់តែមានភាពប្រសើរឡើងថែមមួយកម្រិតទៀត។ ផ្អែកលើទិន្នន័យនៃការផ្តល់ឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក កាន់តែសបញ្ជាក់ឱ្យឃើញច្បាស់ថែមទៀតពីបម្រែបម្រួលនៃធនាគារ ហើយការប្រែប្រួលនេះបានជម្រុញឱ្យធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ ក្លាយជាធនាគារធំបំផុតទីបួន ក្នុងចំណោមធនាគារពាណិជ្ជនៅក្នុងប្រទេសកម្ពុជា។

## ២.ការផ្តល់អនុសាសន៍

យោងតាមលទ្ធផលស្រាវជ្រាវ ក៏ដូចជាការសន្និដ្ឋានពីចំណុចខាងលើមក ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិកគឺមានលក្ខណៈល្អប្រសើរ។ បន្ទាប់ពីធ្វើការសិក្សាទៅលើចំណុចខ្លាំង និងខ្សោយមួយចំនួននៃការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគាររួចមក យើងខ្ញុំសូមធ្វើការផ្តល់ជាមតិយោបល់ និងគំនិតបន្តិចបន្តួចដើម្បីចូលរួមកែលម្អលើចំណុចអវិជ្ជមានមួយចំនួនតូច ដែលត្រូវបានសង្កេតឃើញក្នុងអំឡុងពេលចុះកម្មសិក្សាដោយផ្ទាល់កន្លងមក ដូចជា៖

- ធនាគារគួរតែកាត់បន្ថយភាពស្មុគស្មាញនៃការរៀបចំឯកសារស្នើសុំកម្ចី
- មន្ត្រីឥណទាន គួរតែបង្កើនការប្រុងប្រយ័ត្ន នៅពេលធ្វើការស៊ើបអង្កេតប្រាក់កម្ចី ដោយសារតែការប្រាក់ដែលទទួលបានមកពីការផ្តល់ឥណទាន គឺជាប្រភពចំណូលចម្បងរបស់ធនាគារ។

# ឯកសារយោង


១. ធនាគារជាតិនៃកម្ពុជា, កម្រងច្បាប់ និងបទបញ្ញត្តិអនុវត្តចំពោះគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ

២. Robert Core & Lon Mishler, 1998, Consumer and Business Credit Management

៣. លោកងួន ហេង, រូបិយវត្ថុ និងធនាគារ,សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (២០១៤)

៤. អ្នកស្រីទេព ធីតា, ទស្សនៈទូទៅស្តីអំពីវិស័យធនាគារ និងសេវាហិរញ្ញវត្ថុ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (២០១៦)

៥. លោកទុំ សុវណ្ណ, គ្រប់គ្រងឥណទាន, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (២០១៥)

៦. ជុន ចាន់ណែត, គណិតវិទ្យាហិរញ្ញវត្ថុ, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (២០១៥)

៧. លោកព្រំ សុគុណ, មូលដ្ឋានគ្រឹះនៃហិរញ្ញវត្ថុសាជីវកម្ម១, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច (២០១៥)

៨. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, Credit Control Procedure (២០១៥)

៩. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, គោលការណ៍សុជីវធម៌ក្នុងការបម្រើអតិថិជន (២០១៥)

១០. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, គោលការណ៍ឥណទានសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន/អាជីវកម្ម (២០១៤)

១១. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, គោលការណ៍ណែនាំស្តីពីការដោះស្រាយបំណុល (២០១៥)

១២. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, Internal Control Policy

១៣. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, ការវាយតម្លៃប្រាក់កម្ចី និងទ្រព្យបញ្ចាំ (២០១៧)

១៤. ធនាគារជាតិនៃកម្ពុជា, របាយការណ៍ប្រចាំឆ្នាំ២០១៦

១៥. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, របាយការណ៍ប្រចាំឆ្នាំ២០១៦

១៦. ង៉ែត ស៊ីនួន និងផល ចឺរ៉ាត់, ការគ្រប់គ្រងឥណទានខ្នាតមធ្យមរបស់ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា (២០១៦)

១៧. ឌី ភារៈ និងចិន លក្ខិនី, ការគ្រប់គ្រងឥណទានខ្នាតតូច និងមធ្យម, របាយការណ៍កម្មសិក្សាបញ្ចប់ការសិក្សា (២០១៦)

១៨. ធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ, ព្រឹត្តិបត្រផ្ទៃក្នុង (២០១៦)
១៩. បទសម្ភាសន៍ផ្ទាល់ជាមួយលោក កាន ស៊ីវ ដែលជានាយកគ្រប់គ្រងនៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក
២០. បទសម្ភាសន៍ផ្ទាល់ជាមួយលោក កូវ ធីរ៉ា ដែលជាប្រធានភ្នាក់ងារឥណទាននៃធនាគារ ប្រៃសណីយ៍កម្ពុជា ក.អ សាខាអូឡាំពិក
២១. http://www.imf.org/en/News/Articles/2017/06/06/sp060717-the-cambodian-economy-outlook-risks-and-reforms
២២. http://www.vtb.com/business/lending/lending_kind/
២៣. http://www.gbrw.com/_literature_129465/Preventing_and_Resolving_Non-Performing_Loans
២៤. https://en.wikipedia.org/wiki/History_of_banking
២៥. http://www.investopedia.com/terms/l/loan.asp
២៦. https://www.linkedin.com/pulse/major-gift-asks-right-place-time-person-amount-why-mena-gainpaulsingh?articleId=6118402803741310976
២៧. http://www.investopedia.com/terms/c/creditrisk.asp
២៨. http://thismatter.com/money/banking/bank-risks.htm
២៩. https://en.wikipedia.org/wiki/Reputational_risk
៣០. http://searchcompliance.techtarget.com/definition/compliance-risk
៣១. https://en.wikipedia.org/wiki/Market_risk
៣២. http://www.cambodiapostbank.com/Default/kh

# ឧបសម្ព័ន្ធ